ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ធនាគារជាតិ នៃ កម្ពុជា
NATIONAL BANK OF CAMBODIA

# របាយការណ៍ប្រចាំឆ្នាំ២០០៧

# និង

# ទិសដៅការងារឆ្នាំ២០០៨

# អារម្ភកថា

ឆ្នាំ២០០៧ ជាឆ្នាំដែលសេដ្ឋកិច្ចសកលលោកជួបនឹងបញ្ហាប្រឈមធំៗជាថ្មីម្តងទៀត ជាពិសេសចំពោះមជ្ឈដ្ឋានធនាគារលើពិភពលោកដែលកំពុងត្រូវតទល់នឹងវិបត្តិឥណទាននិក្ខេប (Suprime mortgage lending) និងភាពរឹតត្បិតលើការផ្តល់ឥណទានជាសកល ដែលតម្រូវឱ្យធនាគារកណ្តាលធំៗមួយចំនួនអនុវត្តគោលនយោបាយរូបិយវត្ថុមានលក្ខណៈបន្ធូរបន្ថយ ព្រមទាំងធ្វើអន្តរាគមន៍ក្នុងទីផ្សារដើម្បីបំពេញតម្រូវការសាច់ប្រាក់ងាយស្រួល ។ ប៉ុន្តែ ដោយសារប្រទេសជាច្រើនមានមូលដ្ឋានសេដ្ឋកិច្ចរឹងមាំ ផលប៉ះពាល់នៃឥទ្ធិពលនេះត្រូវបានរំពឹងថា មានកម្រិតអប្បបរមាប៉ុណ្ណោះ ។ យោងតាមរបាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ កំណើនសេដ្ឋកិច្ចពិភពលោកគ្រោងថានឹងមានល្បឿនធ្លាក់ចុះបន្តិច មកនៅត្រឹមប្រមាណ ៥,២% ក្នុងឆ្នាំ២០០៧ ធៀបជាមួយអត្រាកំណើន ៥,៤% ក្នុងឆ្នាំ២០០៦ ។ ខណៈដែលសកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជឿនលឿនបានបង្ហាញឱ្យឃើញនូវនិន្នាការថយចុះនោះ ប្រទេសដែលមានសេដ្ឋកិច្ចកំពុងលេចឡើង ព្រមទាំងសេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានរំពឹងថាបន្តមានកំណើនសេដ្ឋកិច្ចខ្លាំងក្លា ហើយដូច្នេះ អាចក្លាយទៅជាកម្លាំងចលករសម្រាប់កំណើនសេដ្ឋកិច្ចសកលលោក ។ ទន្ទឹមនោះ កំណើនសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិកគ្រោងថានឹងមានកម្រិត ១,៩% ក្នុងឆ្នាំ២០០៧ នេះ ចំណែកឯកំណើនសេដ្ឋកិច្ចនៅតំបន់អឺរ៉ុបត្រូវបានព្យាករថា នឹងមានកម្រិតត្រឹម ២,៥% ។ ជាមួយគ្នានេះដែរ កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងបណ្តាប្រទេសអាស៊ីត្រូវបានរំពឹងថា នឹងជំរុញដោយសន្ទុះកំណើនដ៏ប្រសើររបស់ប្រទេសចិន និងឥណ្ឌា ក្នុងអត្រាកំណើនផលិតផលក្នុងស្រុកសរុបពិតប្រចាំឆ្នាំប្រមាណ ១០% ។ ដោយឡែក សេដ្ឋកិច្ចជប៉ុនគ្រោងថានឹងមានកំណើន ២% ។ ចំណែកឯប្រទេសអាស៊ានទាំង១០ សកម្មភាពសេដ្ឋកិច្ចត្រូវបានរំពឹងថា មានសភាពខ្លាំងក្លាដដែល ខណៈដែលកំណើនសេដ្ឋកិច្ចត្រូវបានព្យាករថា នឹងមានកម្រិត ៧% ក្នុងឆ្នាំ២០០៧ ។

ចំពោះប្រទេសកម្ពុជាវិញ សេដ្ឋកិច្ចគ្រោងថានឹងទទួលបានលទ្ធផលជាទីមោទនៈ ។ ផលិតផលក្នុងស្រុកសរុបត្រូវបានប៉ាន់ស្មានថានឹងកើនដល់ ២៦.៦៨៤,៧ពាន់លានរៀល ស្មើនឹង ៦,៥ពាន់លានដុល្លារ គិតតាមថ្លៃស្ថិរភាព ពោលគឺមានកំណើន៩,៥% ។ វិស័យកសិកម្មត្រូវបានរំពឹងថានឹងបន្តមានកំណើន ដោយសារការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល រួមផ្សំនឹងអំណោយផលនៃអាកាសធាតុមកលើវិស័យដ៏សំខាន់នេះ ។ វិស័យឧស្សាហកម្មនឹងនៅតែបង្ហាញលទ្ធផលវិជ្ជមាន ប៉ុន្តែក្នុងកំណើនមួយទាបជាងឆ្នាំមុន ដែលអាចបណ្តាលជាបឋមពីការកើនឡើងនៃការប្រកួតប្រជែងក្នុងវិស័យកាត់ដេរ ដែលបច្ចុប្បន្នកាន់តែទាមទារច្រើនឡើងៗនូវប្រសិទ្ធភាពផលិតកម្មខ្ពស់ ។ រីឯវិស័យសេវាកម្មវិញ ត្រូវបានគ្រោងថានឹងមានកំណើនក្នុងល្បឿនប្រហាក់ប្រហែលគ្នានឹងល្បឿននាឆ្នាំមុន ប៉ុន្តែតម្លៃបន្ថែមក្នុងវិស័យហិរញ្ញវត្ថុត្រូវបានប៉ាន់ស្មានថាមានកំណើនដល់ ២៨,៨% ពោលគឺខ្ពស់ជាងកំណើននាឆ្នាំមុនប្រមាណ ៥% ។

ដោយយល់ដល់សារៈសំខាន់ចាំបាច់នៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចចំពោះកំណើនសេដ្ឋកិច្ចជាតិ ធនាគារជាតិនៃកម្ពុជាបន្តប្រតិបត្តិការយ៉ាងសកម្ម និងប្រុងប្រយ័ត្ន ក្នុងការបំពេញនូវភារកិច្ចរបស់ខ្លួន ។ រហូតមកទល់បច្ចុប្បន្ននេះ គោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្ន គួបផ្សំជាមួយរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ព្រមទាំងស្ថានភាព

សារពើពន្ធដែលត្រូវបានរក្សា និងត្រួតពិនិត្យយ៉ាងហ្មត់ចត់ បានទទួលជោគជ័យយ៉ាងល្អក្នុងការនាំមកនូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចសម្រាប់ប្រទេស ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ក្នុងឆ្នាំ២០០៧ នេះ សម្ពាធអតិផរណាបានបង្ហាញរូបរាងច្បាស់ជាងមុន ដែលជាលទ្ធផលនៃការទទួលរងនូវឥទ្ធិពលអវិជ្ជមានពីកត្តាគួបផ្សំផ្សេងៗ រួមមានការកើនឡើងថ្លៃប្រេងឥន្ធនៈលើទីផ្សារសកលលោក ការឡើងថ្លៃទំនិញនៅបណ្តាប្រទេសដែលនាំទំនិញចូលមកប្រទេសកម្ពុជា និងបញ្ហាផ្គត់ផ្គង់ក្នុងស្រុកផ្សេងៗទៀត ។ អតិផរណាគិតតាមអត្រាមធ្យមរំកិល៣ខែបានកើនដល់ ៦.៨% នាដំណាច់ឆ្នាំ២០០៧ ។ ស្របពេលជាមួយគ្នានេះដែរ រូបិយវត្ថុក្រៅធនាគារមានការកើនឡើងជាបង្គួរប៉ុណ្ណោះ ដែលបញ្ជាក់ថាកម្រិតអតិផរណាខ្ពស់កន្លងមកនេះ ពុំមែនមានមូលហេតុពីកំណើនរូបិយវត្ថុឡើយ ។ ដោយឡែក អត្រាប្តូរប្រាក់រៀលនៅតែមានស្ថិរភាពយ៉ាងល្អ ខណៈដែលការពូនបង្គរទុនបម្រុងអន្តរជាតិរហូតដល់ ១,៦ពាន់លានដុល្លារនៅចុងឆ្នាំ២០០៧ នេះ មានទំនោរយ៉ាងសមស្របទៅនឹងសន្ទុះនៃកំណើនសេដ្ឋកិច្ច ហើយដែលអាចធានាការនាំចូលបានប្រហែល ៣ខែ ។

ធនាគារជាតិនៃកម្ពុជា បន្តប្តេជ្ញាខិតខំរក្សាស្ថិរភាពថ្លៃដែលជាគោលដៅចម្បងនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ ។ ដោយសារកម្រិតដ៏ខ្ពស់នៃដុល្លារូបនីយកម្ម និងការអភិវឌ្ឍរចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុក្នុងស្រុកពុំទាន់មានភាពស៊ីជម្រៅ ក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុកំពុងអនុវត្តនាបច្ចុប្បន្ន ដែលផ្អែកលើកម្មវិធីរូបិយវត្ថុសមស្រប គួបផ្សំជាមួយនឹងការធ្វើអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់ ត្រូវបានទទួលស្គាល់ថាជាក្របខ័ណ្ឌសមស្របសម្រាប់ទ្រទ្រង់ការសម្រេចគោលដៅនយោបាយរូបិយវត្ថុ ។ ទោះបីស្ថិរភាពអត្រាប្តូរប្រាក់ដើរតួនាទីដ៏សំខាន់ក្នុងការរក្សាស្ថិរភាពថ្លៃក្តី ក៏អាជ្ញាធររូបិយវត្ថុនឹងមិនអនុវត្តក្របខ័ណ្ឌកំណត់អត្រាប្តូរប្រាក់ជាគោលដៅ[១] ឡើយ នៅក្នុងបរិបទបច្ចុប្បន្ននេះ ពោលគឺមានបំណងត្រឹមទប់ទល់បម្រែបម្រួលមិនសមស្របនៃអត្រាប្តូរប្រាក់ប៉ុណ្ណោះ ដោយមិនជំនះនឹងទំនោរប្រែប្រួលជាមូលដ្ឋាននៃខឿនសេដ្ឋកិច្ចឡើយ ហើយដូចនេះ នឹងទ្រទ្រង់ឱ្យមានអត្រាប្តូរប្រាក់រៀលមួយដែលមានលក្ខណៈជាក់ស្តែង ។

ចំពោះការអនុវត្តទៅអនាគតនៃគោលនយោបាយរូបិយវត្ថុដ៏ប្រុងប្រយ័ត្ន ធនាគារជាតិនៃកម្ពុជានឹងបន្តខិតខំថែមទៀត ដើម្បីជំរុញការប្រើប្រាស់រូបិយវត្ថុជាតិតាមរយៈការលើកកម្ពស់ទំនុកចិត្តលើប្រព័ន្ធធនាគារ ក៏ដូចជាលើប្រាក់រៀល ។ ទន្ទឹមនោះដែរ យើងនឹងបន្តរក្សាជំហរបច្ចុប្បន្នដោយមិនប្រើប្រាស់វិធានការរឹតបន្តឹងលើការប្រើប្រាស់រូបិយប័ណ្ណបរទេសឡើយ ។ ម្យ៉ាងវិញទៀត យើងនឹងពិចារណាលើយុទ្ធសាស្ត្រផ្សេងៗ ព្រមទាំងបន្តអភិវឌ្ឍក្របខ័ណ្ឌសម្រាប់ការប្រើប្រាស់ឧបករណ៍នយោបាយរូបិយវត្ថុ និងនយោបាយប្តូរប្រាក់ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត សម្រាប់រយៈកាលមធ្យមនិងវែងខាងមុខ ។

តួនាទីសំខាន់ទីពីររបស់ធនាគារជាតិនៃកម្ពុជា គឺការលើកកម្ពស់ប្រព័ន្ធធនាគារ ។ វិស័យធនាគារកាន់តែមានភាពរឹងមាំអាស្រ័យដោយការធ្វើកំណែទម្រង់វិស័យធនាគារ អនុលោមតាមចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យ

---

[១] Exchange rate targeting framework

ហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ របស់រាជរដ្ឋាភិបាល ដែលថ្មីៗនេះត្រូវបានធ្វើបច្ចុប្បន្នកម្ម និងពង្រីកវិសាលភាពរហូតដល់ឆ្នាំ២០១៥ ។ វិស័យហិរញ្ញវត្ថុកាន់តែមានភាពស៊ីជម្រៅនិងប្រសើរ ដែលឆ្លុះបញ្ចាំងដោយកំណើននៃអនុបាតរូបិយវត្ថុទូទៅ ធៀបនឹងផលិតផលក្នុងស្រុករហូតជិតដល់ ២៥% នាខែធ្នូ ឆ្នាំ២០០៧ ពី ២០% នាឆ្នាំ២០០៦ ។ ចំណែកឯទ្រព្យសកម្មមិនដំណើរការមានកម្រិតទាបជាបង្គួរ គឺប្រមាណ ៥.៧% ប៉ុណ្ណោះ ទោះបីជាឥណទានធនាគារចំពោះវិស័យឯកជនមានការកើនឡើងយ៉ាងលឿនក្តី ។

ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ឱ្យមានប្រព័ន្ធត្រួតពិនិត្យកាន់តែទូលំទូលាយ ព្រមទាំងមានការអនុវត្តបទប្បញ្ញត្តិប្រុងប្រយ័ត្នកាន់តែរឹងមាំជាងមុន ដើម្បីជំរុញអន្តរការិយកម្មធនាគារ និងកាត់បន្ថយហានិភ័យប្រព័ន្ធទូទាត់ក្នុងវិស័យហិរញ្ញវត្ថុ ដោយផ្អែកលើគោលការណ៍មូលដ្ឋានរបស់គណៈកម្មការធនាគារទូទាត់អន្តរជាតិទីក្រុងបាសែល ។ នៅចំពោះមុខកំណើនដ៏លឿននៃការផ្តល់ឥណទានរបស់ធនាគារចំពោះវិស័យឯកជន យើងនឹងបន្តការប្រុងប្រយ័ត្នទៅលើហានិភ័យជាសក្តានុពលនានា ហើយក៏នឹងខិតខំពង្រឹងការគោរពតាមបទប្បញ្ញត្តិប្រុងប្រយត្ន័ពាក់ព័ន្ធទាំងឡាយផងដែរ ។ ការដាក់ឱ្យប្រើប្រាស់នាពេលថ្មីៗនេះនូវប្រព័ន្ធចែករំលែកព័ត៌មានឥណទានក៏បានផ្តល់លទ្ធភាពថ្មីមួយទៀតដែរ សម្រាប់ពង្រឹងវិន័យក្នុងទីផ្សារឥណទាននាពេលអនាគត ។ ទិសដៅខាងមុខ យើងមានគម្រោងពង្រីកវិសាលភាពរបស់ប្រព័ន្ធនេះ ដើម្បីផ្តល់ឱកាសដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឱ្យអាចទទួលផលប្រយោជន៍ពីហេដ្ឋារចនាសម្ព័ន្ធនេះផងដែរ ។ ធនាគារជាតិនៃកម្ពុជាក៏បានគិតគូរដែរថា នៅពេលស្ថានភាពអំណោយផលសមស្រប ប្រព័ន្ធចែករំលែកព័ត៌មានឥណទាននឹងត្រូវទទួលការលើកកម្ពស់បន្ថែម ហើយត្រូវប្រែក្លាយទៅជាការិយាល័យព័ត៌មានឥណទានពេញលក្ខណៈ ដែលនឹងដើរតួនាទីជាកតាលីករដ៏ប្រសើរមួយក្នុងការពង្រឹងគុណភាពវិស័យហិរញ្ញ-វត្ថុរបស់កម្ពុជា ។

ចំពោះបញ្ហាក្របខ័ណ្ឌច្បាប់វិញ បន្ទាប់ពីច្បាប់ស្តីពីការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មត្រូវបានប្រកាសឱ្យប្រើប្រាស់ក្នុងឆ្នាំនេះ ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំលក្ខណៈជាបណ្តើរៗ ដើម្បីធានាការអនុវត្តច្បាប់នេះឱ្យបានជោគជ័យ ។ ក្នុងនោះរួមមាន ការរៀបចំសេចក្តីព្រាងអនុក្រឹត និងបទប្បញ្ញត្តិចាំបាច់នានា ការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និងការអប់រំសាធារណជនជាដើម ។ ដោយឡែក សេចក្តីព្រាងច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុត្រូវបានផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ ។

ធនាគារជាតិនៃកម្ពុជាកំពុងយកចិត្តទុកដាក់ជាខ្លាំងផងដែរទៅលើការអភិវឌ្ឍប្រព័ន្ធទូទាត់ជាតិ ដោយផ្តោតជាសំខាន់ទៅលើភាពចាំបាច់នៃការបង្កើតហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការទូទាត់សងប្រាក់មួយប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងគួរឱ្យជឿជាក់បាន ។

ទន្ទឹមនឹងនេះ ខ្ញុំសូមបញ្ជាក់នៅក្នុងរបាយការណ៍ដ៏សំខាន់នេះផងដែរថា ទោះបីជាយើងកំពុងប្រឹងប្រែងជំរុញបង្កើតនូវប្រព័ន្ធហិរញ្ញវត្ថុដ៏ទំនើប និងប្រកបដោយប្រសិទ្ធភាពក្តី ក៏ការបង្កលក្ខណៈងាយស្រួលចំពោះប្រជាជនក្រីក្រ

ឱ្យមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ នៅតែជាការងារអាទិភាពរបស់យើងដដែល ។ ជាការពិត ជោគជ័យនៃវិស័យមីក្រូហិរញ្ញវត្ថុរហូតមកទល់ពេលនេះ គឺជាមោទនភាពរបស់រាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធររូបិយវត្ថុ ក៏ដូចជារបស់ស្ថាប័នពាក់ព័ន្ធទាំងឡាយ ។ ដូច្នេះ យើងនឹងបន្តពង្រឹងការត្រួតពិនិត្យ និងការធ្វើបញ្ញត្តិកម្មនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជំរុញឱ្យមានការអនុវត្តដ៏ល្អក្នុងប្រតិបត្តិការរបស់គ្រឹះស្ថានទាំងនោះ គាំទ្របន្ថែមទៀតដល់ការកសាងសមត្ថភាពស្ថាប័នរបស់គេ ព្រមទាំងជំរុញឱ្យមានចំណងទាក់ទងជិតស្និទ្ធរវាងធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

លើសពីនេះទៀត ការកសាងសមត្ថភាពនៅក្នុងធនាគារជាតិនៃកម្ពុជាផ្ទាល់ ក៏ត្រូវបានពង្រឹងបន្ថែមជាប្រចាំដែរ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការរបស់ធនាគារកណ្តាល ។

នៅទីបញ្ចប់នេះ ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល ក្រសួង និងស្ថាប័នរដ្ឋទាំងអស់ ដែលបានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងចំពោះធនាគារជាតិនៃកម្ពុជារហូតមកដល់សព្វថ្ងៃនេះ និងសូមអរគុណចំពោះដៃគូអភិវឌ្ឍន៍ទាំងឡាយដល់ការចូលរួមយ៉ាងសកម្ម ដែលអនុញ្ញាតឱ្យវិស័យហិរញ្ញវត្ថុកម្ពុជាអាចទទួលបានអត្ថប្រយោជន៍នានា ជាពិសេសពីការផ្ទេរបច្ចេកវិទ្យាពីបរទេស ព្រមទាំងជំនួយបច្ចេកទេសផ្សេងៗទៀត ។ ធនាគារជាតិនៃកម្ពុជាសង្ឃឹមយ៉ាងមុតមាំថា នឹងអាចទទួលការជួយទ្រទ្រង់ទាំងនោះជាបន្តទៀត ក្នុងរយៈពេលអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមសម្តែងការកោតសរសើរចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ព្រមទាំងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលដ៏ល្អ ដូចបានរៀបរាប់ក្នុងរបាយការណ៍នេះ ។

**ទេសាភិបាល**

# មាតិកា


| | ទំព័រ |
|---|---|
| **ក. របាយការណ៍ប្រចាំឆ្នាំ២០០៧** | ១ |
| **សេចក្តីផ្តើម** | ២ |
| **I. ការវិវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា** | ៣ |
| **១. ស្ថានភាពតម្លៃប្រាក់រៀល** | ៣ |
| **១.១. ការវិវត្តសន្ទស្សន៍ថ្លៃទំនិញ និងសេវា (CPI)** | ៣ |
| **១.២. ស្ថានភាពអត្រាប្តូរប្រាក់** | ៥ |
| **១.២.១. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក** | ៥ |
| **១.២.២. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗ** | ៦ |
| **២. ការវិវត្តរូបិយវត្ថុ** | ៧ |
| **២.១. ការផ្គត់ផ្គង់រូបិយវត្ថុ** | ៨ |
| **២.២. កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ** | ៩ |
| **២.២.១. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា** | ១០ |
| **២.២.២. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ** | ១០ |
| **២.២.៣. អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ** | ១១ |
| **៣. ជញ្ជីងទូទាត់** | ១២ |
| **៣.១. គណនីចរន្ត** (មិនរាប់បញ្ចូលបង្វែរផ្លូវការ) | ១២ |
| **៣.២. គណនីដើមទុន និងហិរញ្ញវត្ថុ** | ១៤ |
| **៤. ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ** | ១៥ |
| **៤.១. ការវិនិយោគទុនបម្រុងអន្តរជាតិ** | ១៥ |
| **៤.២. អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់** | ១៦ |
| **៤.៣. ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់** | ១៦ |
| **៥. សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ** | ១៦ |
| **៥.១. ការត្រួតពិនិត្យធនាគារពាណិជ្ជ** | ១៦ |
| **៥.១.១. ការត្រួតពិនិត្យលើឯកសារ** | ១៧ |
| **៥.១.២. ការត្រួតពិនិត្យដល់ទីកន្លែង** | ១៨ |
| **៥.២. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** | ១៨ |

៥.៣. ការជម្រះបញ្ជីធនាគារ ១៩

៥.៤. ការងាររៀបចំបទបញ្ញា ១៩

៥.៥. អាជ្ញាប័ណ្ណ និងការចុះបញ្ជី ១៩

៥.៦. ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ២០

៥.៦.១. សមាជិកភាព និងការវាយតម្លៃអញ្ញមញ្ញ ២០

៥.៦.២. ច្បាប់ និងបទប្បញ្ញត្តិ ២០

៦. ការផ្តល់ផ្គង់សេវាធនាគារកណ្តាល ២១

៦.១. សេវាផ្នែកគណនី ២១

៦.១.១. សេវាផ្នែកគណនីចំពោះស្ថាប័នរដ្ឋ ២១

៦.១.២. សេវាផ្នែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ២១

៦.២. សេវាផាត់ទាត់ ២១

៦.២.១. ការផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់រៀល ២១

៦.២.២. ការផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់ដុល្លារអាមេរិក ២២

៦.៣. ការងារឥណទាន ២២

៦.៤. ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរាជរដ្ឋាភិបាល ២២

៧. ការគ្រប់គ្រងចរាចរណ៍ធនប័ត្រ ២៤

II. ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ២៥

១. សកម្មភាពក្រុមប្រឹក្សាភិបាល ២៥

២. ការអភិវឌ្ឍធនធានមនុស្ស ២៦

២.១. ស្ថិតិមន្ត្រីបុគ្គលិក ២៦

២.២. ការងារបណ្តុះបណ្តាល ២៦

៣. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ២៧

៤. ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា ២៨

៥. ការងារគណនេយ្យធនាគារជាតិនៃកម្ពុជា ២៨

III. ទំនាក់ទំនងអន្តរជាតិ ៣០

១. ទំនាក់ទំនងពហុភាគី ៣០

១.១. ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ ៣០

១.២. ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ៣១

| | |
|---|---|
| ១.៣~ ទំនាក់ទំនងជាមួយអាស៊ាន | ៣២ |
| ១.៤~ ទំនាក់ទំនងជាមួយ SEACEN | ៣២ |
| ១.៥~ ទំនាក់ទំនងជាមួយក្រុមអាស៊ីប៉ាស៊ីហ្វិក (APG) | ៣៣ |
| ១.៦~ ទំនាក់ទំនងជាមួយសមាគមឥណទានកសិកម្ម និងឥណទានជនបទតំបន់អាស៊ីប៉ាស៊ីហ្វិក (APRACA) | ៣៤ |
| ២~ ទំនាក់ទំនងទ្វេភាគី | ៣៥ |
| សន្និដ្ឋាន | ៣៦ |
| **ខ~ ទិសដៅការងារឆ្នាំ២០០៨** | ៣៨ |
| ទិសដៅការងារឆ្នាំ២០០៨ | ៣៩ |
| ១~ ការងាររូបិយវត្ថុ | ៣៩ |
| ២~ ការងារប្តូរប្រាក់ | ៣៩ |
| ៣~ ការអភិវឌ្ឍប្រព័ន្ធទូទាត់ | ៤០ |
| ៤~ ការងារត្រួតពិនិត្យ និងការងារប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | ៤០ |
| ៥~ ការងារគណនេយ្យ | ៤០ |
| ៦~ ការងារប្រតិបត្តិការ | ៤០ |
| ៧~ ការងារបោះផ្សាយ និងឃ្លាំងបេឡា | ៤១ |
| ៨~ ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច | ៤១ |
| ៩~ ការបណ្តុះបណ្តាល | ៤១ |
| **ឧបសម្ព័ន្ធ** | ៤២ |
| ឧបសម្ព័ន្ធ ១ : ការវិវត្តសន្ទស្សន៍ថ្លៃទំនិញ និងសេវា ឆ្នាំ២០០៧ | ៤៣ |
| ឧបសម្ព័ន្ធ ២ : សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវា ឆ្នាំ២០០៣~២០០៧ | ៤៤ |
| ឧបសម្ព័ន្ធ ៣ : ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ | ៤៥ |
| ឧបសម្ព័ន្ធ ៤ : ស្ថានភាពរូបិយវត្ថុ (គិតជាពាន់លានរៀល) | ៤៦ |
| ឧបសម្ព័ន្ធ ៥ : ស្ថានភាពរូបិយវត្ថុ (បម្រែបម្រួលប្រចាំខែជាភាគរយ) | ៤៧ |
| ឧបសម្ព័ន្ធ ៦ : តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា | ៤៨ |
| ឧបសម្ព័ន្ធ ៧ : តារាងគណនីវិភាគធនាគារពាណិជ្ជ | ៤៩ |
| ឧបសម្ព័ន្ធ ៨ : ឥណទានចំណាត់ថ្នាក់តាមមុខរបរ និងសរុបប្រតិបត្តិការប្រាក់បញ្ញើធនាគារពាណិជ្ជ | ៥០ |
| ឧបសម្ព័ន្ធ ៩ : ជញ្ជីងទូទាត់ប្រទេសកម្ពុជា ឆ្នាំ២០០៤~ឆ្នាំ២០០៧ | ៥១ |

# ក. របាយការណ៍ប្រចាំឆ្នាំ២០០៧

## សេចក្ដីផ្ដើម

ខណៈដែលទីផ្សារហិរញ្ញវត្ថុនៃសេដ្ឋកិច្ចប្រទេសជឿនលឿនចម្បងៗត្រូវរងភាពរង្គោះរង្គើ ដោយសារស្ថានភាពច្របូកច្របល់ និងដោយហានិភ័យនៃការប្រែប្រួលថ្លៃអចលនទ្រព្យ ហើយដែលទំនងអាចបណ្ដាលឱ្យមានការធ្លាក់ចុះជាយថាហេតុនៃសេដ្ឋកិច្ចសកលលោក ក៏មានសេចក្ដីព្រួយបារម្ភខ្លះដែរថា សភាពនេះអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់សេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈការធ្លាក់ចុះនៃទីផ្សារនាំចេញរបស់ប្រទេសទាំងនោះ ។

ប៉ុន្តែទោះជាមានហេតុការណ៍នេះ និងបញ្ហាប្រឈមតឹងតែងឯទៀតក៏ដោយ កម្ពុជាអាចរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០០៧ ក្នុងកម្រិតមួយសមរម្យ ។ ពិនិត្យលើទិន្នន័យថ្មីៗ កំណើនសេដ្ឋកិច្ចកម្ពុជានឹងមាន ៩,៦% សម្រាប់ឆ្នាំនេះ ។ ទុនបម្រុងអន្តរជាតិមានកំណើនប្រហែល ៣៣,៣% ហើយទាំងការនាំចេញ ការនាំចូល ព្រមទាំងវិនិយោគផ្ទាល់បរទេសក៏មានសន្ទុះគួរឱ្យកត់សម្គាល់ និងដែលនាំទៅដល់ការបន្តរក្សាបាននូវសមតុល្យវិជ្ជមានសម្រាប់ជញ្ជីងទូទាត់របស់ប្រទេសទៀតផង ។ ការផ្ទេរប្រាក់ចូលមកក្នុងប្រទេសដោយជនជាតិកម្ពុជាដែលធ្វើការនៅក្រៅប្រទេសបានកើនឡើងដល់ ៣៣២លានដុល្លារអាមេរិក ដែលជាកម្រិតដ៏ខ្ពស់ជាងឆ្នាំនានា ហើយខ្ទង់នេះបានវិវឌ្ឍបន្តិចម្តងៗជាប្រភពសំខាន់មួយនៃចំណូលរូបិយប័ណ្ណរបស់ប្រទេស ។ សមិទ្ធផលទាំងឡាយនេះពិតជាមានកម្រិតជាទីមោទនៈ បើធៀបទៅនឹងបរិដ្ឋាននិងបញ្ហាប្រឈមដ៏តឹងតែងនានាក្នុងឆ្នាំ២០០៧នេះ ។ ការបន្តកើនឡើងដល់កម្រិតខ្ពស់បំផុតពុំធ្លាប់មាននៃថ្លៃប្រេងឥន្ធនៈ និន្នាការធ្លាក់ចុះនៃប្រាក់ដុល្លារនៅលើទីផ្សារអន្តរជាតិ អត្រាអតិផរណានៃប្រទេសនាំចូលទំនិញមកកម្ពុជា និងភាពមិនអំណោយផលគ្រប់គ្រាន់នៃការផ្គត់ផ្គង់ទំនិញរបស់ទីផ្សារក្នុងស្រុក កត្តាទាំងនេះសុទ្ធតែមានឥទ្ធិពលមកលើសេដ្ឋកិច្ចកម្ពុជានាឆ្នាំនេះ ។ ក្នុងការទប់ទល់ជាមួយបញ្ហាប្រឈមទាំងនោះ ធនាគារជាតិនៃកម្ពុជាប្រកាន់ជំហរប្រុងប្រយ័ត្នខ្ពស់ ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចទៅតាមសមត្ថកិច្ចរបស់ខ្លួន ដោយព្យាយាមរក្សាគត់មត់នូវតុល្យភាពរវាងការជួយជំរុញឱ្យមាន កំណើនសេដ្ឋកិច្ចរយៈកាលខ្លី តាមរយៈការបង្កើនបរិមាណរូបិយវត្ថុនិងឥណទាន ជាមួយនឹងការរក្សាស្ថិរភាពថ្លៃទំនិញប្រើប្រាស់ ។ អាស្រ័យហេតុនេះ ការអនុវត្តគោលនយោបាយរូបិយវត្ថុបន្ធូរបន្ថយណាក្តីរបស់ធនាគារកណ្តាល តែងតែត្រូវបានគិតគូរយ៉ាងហ្មត់ចត់ទៅដល់ផលប៉ះពាល់ទៅលើស្ថិរភាពថ្លៃ ។

ទន្ទឹមនោះ ភាពកាន់តែរឹងមាំនៃម៉ាក្រូសេដ្ឋកិច្ច គួបផ្សំជាមួយសកម្មភាពត្រួតពិនិត្យដ៏សមស្រប ព្រមទាំងការបន្តរក្សាសុវត្ថិភាពប្រព័ន្ធទូទាត់និងផាត់ទាត់ ដែលទោះបីជាស្ថិតក្នុងដំណាក់កាលទើបកសាងក្តី បានរួមចំណែកពង្រឹងប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែមានភាពប្រសើរឡើង ។ រហូតមកទល់បច្ចុប្បន្ននេះ គឺពុំមានការគំរាមកំហែងធ្ងន់ធ្ងរណាមួយដែលអាចបង្កជាគ្រោះថ្នាក់ដល់ស្ថិរភាពរបស់ប្រព័ន្ធឡើយ ហើយអាជ្ញាធររូបិយវត្ថុនៅតែរវាសរវៃក្នុងការទប់ទល់នឹងហានិភ័យជាយថាហេតុនានា តាមរយៈការពង្រឹងជាប្រចាំនូវក្របខ័ណ្ឌនិងសមត្ថភាពត្រួតពិនិត្យ ។ លើសពីនេះទៀត គ្រឹះស្ថានធនាគារទាំងឡាយ ជាពិសេសធនាគារធំៗនៅក្នុងប្រព័ន្ធក៏ត្រូវបានជំរុញឱ្យលើកកម្ពស់ការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិ ដោយរួមទាំងការគោរពតាមកាតព្វកិច្ចបើកចំហផ្សព្វផ្សាយព័ត៌មាន និងការពង្រឹងការគ្រប់គ្រងហានិភ័យរបស់ខ្លួនផងដែរ ។

# I. ការវិវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា

## ១. ស្ថានភាពតម្លៃប្រាក់រៀល

### ១.១. ការវិវត្តសន្ទស្សន៍ថ្លៃទំនិញ និងសេវា (CPI)

ក្នុងឆ្នាំ២០០៧ ការវិវត្តសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំខែ (CPI) បានបង្ហាញនិន្នាការកើនឡើងជាបន្តបន្ទាប់ ចាប់តាំងពីដើមឆ្នាំរហូតដល់ដំណាច់ឆ្នាំ លើកលែងតែខែវិច្ឆិកាដែលមានការថយចុះបន្តិចបន្តួច ។ បើប្រៀបធៀបនឹងឆ្នាំ២០០៦ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ក្នុងឆ្នាំនេះមានការកើនឡើងខ្ពស់ ដែលការកើនឡើងនេះ ជាចម្បងបណ្តាលមកពីឥទ្ធិពលនៃកំណើនថ្លៃប្រេងឥន្ធនៈ គ្រឿងឧបភោគបរិភោគ សម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់មួយចំនួន ។




សន្ទស្សន៍ថ្លៃទំនិញបានកើនជាបណ្តើរៗ ចាប់តាំងពីខែមករាមក ហើយអត្រាអតិផរណាគិតតាមបម្រែបម្រួលមធ្យមរំកិលបីខែស្មើនឹង ៩,៧% ធៀបនឹង ៣,៤% ក្នុងឆ្នាំ២០០៦ និង ៦,៦% ក្នុងឆ្នាំ២០០៥ ។ កំណើនអតិផរណានៅឆ្នាំ២០០៧ នេះ បណ្តាលមកពីការកើនឡើងយ៉ាងខ្លាំងនៃសន្ទស្សន៍ក្រុមធំម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ ចំនួន ១៩,៨% សន្ទស្សន៍ក្រុមធំផ្ទះសម្បែង និងការប្រើប្រាស់ចំនួន ០,៧០% សន្ទស្សន៍ក្រុមធំដឹកជញ្ជូននិងទូរគមនាគមន៍ចំនួន ១៣,៩% និងសន្ទស្សន៍ក្រុមធំ ការថែរក្សាសុខភាពចំនួន ៥,៥% សន្ទស្សន៍ក្រុមធំគ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ចំនួន ៨,៤% រួមផ្សំនឹងកំណើនសន្ទស្សន៍ក្រុមធំដទៃទៀតដែលបានកើនឡើងក្នុងរង្វង់ពី ០,៤% ដល់ ៤,៦% ។ គួរបញ្ជាក់ដែរថា ថ្លៃប្រេងឥន្ធនៈគ្រប់ប្រភេទនៅលើទីផ្សារក្នុងស្រុកបានបន្តកើនឡើង ក្នុងនោះ ថ្លៃប្រេងសាំងមានកំណើន ១០,១% ប្រេងម៉ាស៊ូតមានកំណើន ១៨,២% និងប្រេងម៉ាស៊ីនមានកំណើន ២៦,៩% ។

តែបើពិនិត្យលើអត្រាបម្រែបម្រួលមធ្យមរំកិល ១២ខែវិញ ស្ថានភាពអតិផរណាឆ្នាំ២០០៧ មានលក្ខណៈប្រសើរជាងឆ្នាំ២០០៦ ដោយបានប្រែប្រួលក្នុងរង្វង់ ៣,៨% ដល់ ៥,៨% ប៉ុណ្ណោះ ខណៈដែលក្នុងរយៈពេលដូចគ្នានៃឆ្នាំកន្លងទៅ អតិផរណាប្រែប្រួលពី ៤,៧% ដល់ ៥,៩% ។

## ក្រាហ្វស្ថិតិ ២ : ការវិវត្តនៃអតិផរណាមធ្យមប្រចាំឆ្នាំ

(បម្រែបម្រួលជាភាគរយ មធ្យមរំកិល ១២ខែ)




## ក្រាហ្វស្ថិតិ ៣ : ការប្រៀបធៀបចលនាអតិផរណា ផ្អែកលើរង្វាស់ផ្សេងៗ

(ឆ្នាំ២០០៤-ឆ្នាំ២០០៧)




## ក្រាហ្វស្ថិតិ ៤ : បម្រែបម្រួលសន្ទស្សន៍រងថ្លៃទំនិញប្រើប្រាស់ និងសេវា

(បម្រែបម្រួលជាភាគរយ ខែលើខែ)




* ទិន្នន័យព្យាករណ៍

## ១.២. ស្ថានភាពអត្រាប្តូរប្រាក់

### ១.២.១. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក

នៅក្នុងឆ្នាំ២០០៧ នេះ ប្រាក់រៀលធៀបជាមួយនឹងប្រាក់ដុល្លារអាមេរិកបានឡើងថ្លៃជាបន្តុរ ។ ជារួម តម្លៃប្រាក់រៀលដែលគណនាដោយអត្រាទិញទីផ្សារនៅតែរក្សាបាននូវស្ថិរភាពជាទូទៅចាប់តាំងពីដើមឆ្នាំមក ក្នុងចន្លោះ ៤.០៥០រៀល ទៅ ៤.១០០រៀល ក្នុងមួយដុល្លារអាមេរិក ហើយបានទាំងបង្ហាញនូវនិន្នាការឡើងថ្លៃជាបន្តបន្ទាប់នាចុងឆ្នាំនេះទៀតផង ។ ប្រាក់រៀលត្រូវបានជួញដូរជាមធ្យមក្នុងកម្រិត ៤.០៦៩រៀល ក្នុងមួយដុល្លារអាមេរិក ក្នុងឆមាសទីពីរនៃឆ្នាំនេះ ពោលគឺប្រសើរជាងកម្រិតមធ្យម ៤.១៣៤រៀល នារយៈពេលដូចគ្នានៃឆ្នាំមុន ។ ផ្អែកលើមូលដ្ឋានឆ្នាំលើឆ្នាំ ប្រាក់រៀលមានការឡើងថ្លៃប្រមាណ ១% ធៀបនឹងប្រាក់ដុល្លារអាមេរិក ដោយអត្រាប្តូរលើទីផ្សារបានថយចុះពី ៤.០៥៨រៀល ក្នុងឆ្នាំ២០០៦ មកត្រឹម ៤.០៥៥រៀល ក្នុងមួយដុល្លារអាមេរិក នាដំណាច់ឆ្នាំ ២០០៧ ។ ការឡើងថ្លៃនៃប្រាក់រៀលនេះ ជាការឡើងថ្លៃតាមរដូវកាលដោយសារឈ្មួញទាំងឡាយត្រូវការរូបិយវត្ថុជាតិដើម្បីប្រមូលទិញកសិផលផ្សេងៗក្នុងរដូវច្រូតកាត់ពីប្រជាកសិករ ហើយក្រុមហ៊ុនអាជីវកម្មឯកជននានាក៏មានតម្រូវការប្រាក់រៀលដើម្បីបង់ពន្ធផងដែរ ។ ទន្ទឹមនោះកត្តាគួបផ្សំមួយទៀត គឺការមានពិធីបុណ្យប្រពៃណីជាហូរហែនារដូវចុងឆ្នាំ ។ តែគួរកត់សម្គាល់ផងដែរថា នាអំឡុងឆ្នាំកន្លងមកនេះ ប្រាក់ដុល្លារអាមេរិកបានទទួលរងនូវសម្ពាធចុះខ្សោយជាច្រើនធៀបនឹងរូបិយប័ណ្ណមួយចំនួននៅទូទាំងពិភពលោក រួមទាំងតំបន់អាស៊ីផងដែរ ។

ក្រាហ្វិកទី ៥ : ការវិវត្តនៃអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក

( ឆ្នាំ២០០៥-ឆ្នាំ២០០៧)



## តារាងអត្រាប្តូរប្រាក់រៀល ធៀបនឹងប្រាក់ដុល្លារអាមេរិក

(រៀលក្នុងមួយដុល្លារអាមេរិក)

| | អត្រាប្តូរប្រាក់ប្រចាំខែ ( ចុងខែ) | | | | | |
|---|---|---|---|---|---|---|
| | អត្រាទីផ្សារ | | | អត្រាផ្លូវការ | | |
| | ទិញ | លក់ | មធ្យម | ទិញ | លក់ | មធ្យម |
| មិថុនា-០៦ | ៤.១១៨ | ៤.១២៦ | ៤.១២២ | ៤.១១០ | ៤.១១៨ | ៤.១១៤ |
| ធ្នូ-០៦ | ៤.០៥៨ | ៤.០៧២ | ៤.០៦៥ | ៤.០៥៧ | ៤.០៦៥ | ៤.០៦១ |
| មករា-០៧ | ៤.០៦៥ | ៤.០៧៥ | ៤.០៧០ | ៤.០៦៤ | ៤.០៧២ | ៤.០៦៨ |
| កុម្ភៈ-០៧ | ៤.០៥៩ | ៤.០៦៨ | ៤.០៦៤ | ៤.០៥៧ | ៤.០៦៥ | ៤.០៦១ |
| មីនា-០៧ | ៤.០៥៧ | ៤.០៦៥ | ៤.០៦១ | ៤.០៥៥ | ៤.០៦៣ | ៤.០៥៩ |
| មេសា-០៧ | ៤.០៦៩ | ៤.០៧៧ | ៤.០៧៣ | ៤.០៦២ | ៤.០៧០ | ៤.០៦៦ |
| ឧសភា-០៧ | ៤.០៩១ | ៤.០៩៩ | ៤.០៩៥ | ៤.០៧៧ | ៤.០៨៥ | ៤.០៨១ |
| មិថុនា-០៧ | ៤.០៩៦ | ៤.១០៧ | ៤.១០២ | ៤.០៨២ | ៤.០៩០ | ៤.០៨៦ |
| កក្កដា-០៧ | ៤.០៩២ | ៤.១០១ | ៤.០៩៧ | ៤.០៧៧ | ៤.០៨៥ | ៤.០៨១ |
| សីហា-០៧ | ៤.០៨៤ | ៤.០៩៣ | ៤.០៨៩ | ៤.០៨០ | ៤.០៨៨ | ៤.០៨៤ |
| កញ្ញា-០៧ | ៤.០៧៨ | ៤.០៨៦ | ៤.០៨២ | ៤.០៧៥ | ៤.០៨៣ | ៤.០៧៩ |
| តុលា-០៧ | ៤.០៥២ | ៤.០៥៤ | ៤.០៥៦ | ៤.០៤៨ | ៤.០៥៦ | ៤.០៥២ |
| វិច្ឆិកា-០៧ | ៤.០១៣ | ៤.០២២ | ៤.០១៨ | ៤.០០២ | ៤.០១០ | ៤.០០៦ |
| ធ្នូ-០៧ | ៤.០០០ | ៤.០០៨ | ៤.០០៤ | ៣.៩៩៩ | ៤.០០៧ | ៤.០០៣ |

### ១.២.២~ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗ

ការប្រៀបធៀបអត្រាប្តូរប្រាក់រៀលជាមួយរូបិយប័ណ្ណផ្សេងៗមួយចំនួន ជាពិសេសរូបិយប័ណ្ណនៃប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា ដោយផ្អែកលើអត្រាប្តូរប្រាក់ខ្វែង បានបង្ហាញឱ្យឃើញថា ក្នុងឆ្នាំ២០០៧ ប្រាក់រៀលបានចុះថ្លៃជាងប្រាក់ដុល្លារកាណាដា ១៧,៨៩% ប្រាក់បាតថៃ ១២,៣៩% ប្រាក់ប៉េសូហ្វីលីពីន ១២,០៥% ប្រាក់អឺរ៉ូ ៨,២៤% ប្រាក់រីងហ្គីតម៉ាឡេស៊ី ៧,៣៦% និងប្រាក់ដុល្លារសិង្ហបុរី ៥,០៩% ។ ទន្ទឹមនេះដែរ ប្រាក់រៀលបានឡើងថ្លៃធៀបនឹងប្រាក់ដុងវៀតណាម ១,១៨% និងប្រាក់ដុល្លារហុងកុង ០,៩៥% ។ ការវិវត្តនេះមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលឡើយនៅចំពោះមុខកម្រិតដ៏ខ្ពស់នៃដុល្លារូបនីយកម្មសេដ្ឋកិច្ចរបស់កម្ពុជា ព្រមទាំងការចុះទន់ខ្សោយដ៏គួរឱ្យកត់សម្គាល់នៃប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារប្តូរប្រាក់លើពិភពលោក ។ ជាពិសេស ក្នុងអំឡុងពេលចុងឆ្នាំនេះ ប្រាក់ដុល្លារអាមេរិកបានរងសម្ពាធចុះថ្លៃយ៉ាងច្រើនធៀបនឹងប្រាក់អឺរ៉ូ និងបានធ្លាក់ថ្លៃក្នុងកម្រិតខ្ពស់មធ្យមផងដែរ

ធៀបនឹងប្រាក់បាតថៃ ប្រាក់ដុល្លារអូស្ត្រាលី ប្រាក់យ៉ន់ចិន ប្រាក់ដុល្លារសិង្ហបុរី ប្រាក់យ៉េនជប៉ុន និងដុល្លារហុងកុង ទោះបីជាធនាគារកណ្តាលធំៗមួយចំនួនបានចូលរួមធ្វើអន្តរាគមន៍យ៉ាងសកម្ម ដើម្បីរារាំងការឡើងថ្លៃដ៏លឿននៃរូបិយវត្ថុជាតិរបស់ខ្លួនក្តី ។

ក្រាហ្វិកទី ៦ : ការវិវត្តនៃតម្លៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន




* ខ្សែគំនូសឡើងលើបង្ហាញអំពីការចុះថ្លៃនៃប្រាក់រៀល

## ២. ការវិវត្តរូបិយវត្ថុ

ទ្រព្យសកម្មក្នុងស្រុកសុទ្ធក្នុងអំឡុងឆ្នាំ២០០៧ នេះ បានបន្តកើនឡើងក្នុងអត្រាកំណើន ៥ដង ច្រើនជាងឆ្នាំមុន ខណៈដែលរូបិយវត្ថុទូទៅ (M2) និងទ្រព្យសកម្មបរទេសសុទ្ធក៏មានកំណើនខ្ពស់ជាងឆ្នាំមុនៗដែរ ។ ការកើនឡើងខ្ពស់នៃទ្រព្យសកម្មក្នុងស្រុកសុទ្ធដែលមានសញ្ញាអវិជ្ជមានជាច្រើនឆ្នាំមកហើយ បានប្រែប្រួលមកជាសញ្ញាវិជ្ជមានវិញក្នុងឆ្នាំនេះ ដែលជាចម្បងបណ្តាលមកពីការកើនឡើងដ៏គួរកត់សម្គាល់នៃឥណទានចំពោះវិស័យឯកជន ខណៈដែលអត្រាប្តូរប្រាក់រៀលមានការវិវត្តដ៏ប្រសើរ ដែលជាកត្តាមួយឆ្លុះបញ្ចាំងនូវកំណើននៃតម្រូវការប្រាក់រៀលនៅក្នុងសេដ្ឋកិច្ច ។ ជាមួយគ្នានេះ អត្រាកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណ និងទ្រព្យសកម្មបរទេសរបស់ធនាគារជាតិនៃកម្ពុជាក៏បានបង្ហាញកម្រិតមួយខ្ពស់ជាងឆ្នាំ២០០៦ ដែរ ។




## ២.១_ ការផ្គត់ផ្គង់រូបិយវត្ថុ

ក្នុងឆ្នាំ២០០៧នេះ រូបិយវត្ថុទូទៅ (M2) បានកើនឡើងចំនួន ៣.៨៦២ពាន់លានរៀល (៥៥,៦%) ពោលគឺកើនពី ៦.៩៤២,៣ពាន់លានរៀលក្នុងខែធ្នូ ឆ្នាំ២០០៦ ទៅ ១០.៨០៤,៣ពាន់លានរៀលក្នុងខែធ្នូ ឆ្នាំ២០០៧ ។ ការកើនឡើងនៃរូបិយវត្ថុទូទៅ ជាចម្បងបណ្តាលមកពីកំណើននៃប្រាក់បញ្ញើជារូបិយប័ណ្ណរបស់និវាសជនចំនួន ៣.៦២៤,៩ពាន់លានរៀល (៦៩,៨%) គួបផ្សំជាមួយនឹងការកើនឡើងនៃរូបិយវត្ថុក្នុងចរាចរណ៍ចំនួន ២០២,៧ពាន់លានរៀល (១២,៧%) ខណៈដែលប្រាក់បញ្ញើចរន្ត និងប្រាក់បញ្ញើមានកាលកំណត់ និងសន្សំមានការកើនឡើងបន្តិចបន្តួចចំនួន ១៧,៩ពាន់លានរៀល (៣០,៨%) និង ១៦,៩ពាន់លានរៀល (១៨,៦%) រៀងគ្នា ។ កំណើនដ៏ខ្ពស់នៃប្រាក់បញ្ញើជារូបិយប័ណ្ណនេះ ឆ្លុះបញ្ចាំងនូវការកើនឡើងនៃប្រាក់បញ្ញើសន្សំចំនួន ១.២៥៤,៩ពាន់លានរៀល (៥៦,៤%) ប្រាក់បញ្ញើមានកាលកំណត់ចំនួន ៩៦៦,៩ពាន់លានរៀល (៥៣,៣%) និងប្រាក់បញ្ញើចរន្តចំនួន ៧៣៨,៥ពាន់លានរៀល (៥៣,០%) ។ ផ្អែកលើទិន្នន័យប្រចាំខែបានបង្ហាញឱ្យឃើញថា ប្រាក់បញ្ញើជារូបិយប័ណ្ណបានកើនឡើងជារៀងរាល់ខែ ក្នុងអំឡុងឆ្នាំ២០០៧ នេះ ។ ការវិវត្តរូបិយវត្ថុក្នុងឆ្នាំនេះ បានឆ្លុះបញ្ចាំងឱ្យឃើញនូវកំណើនយ៉ាងខ្ពស់គួរឱ្យកត់សម្គាល់នៃការប្រើប្រាស់សេវាធនាគារ បន្ទាប់ពីមានធនាគារចំណូលថ្មី ការបន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់របស់ធនាគារពាណិជ្ជធំៗមួយចំនួន និងការជំរុញឱ្យប្រើប្រាស់សេវាកម្មធនាគារដោយរាជរដ្ឋាភិបាល ក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមក ។

ក្រាហ្វិកទី ៨ : សមាសធាតុនៃការផ្គត់ផ្គង់រូបិយវត្ថុ




## តារាងបម្រែបម្រួលជាភាគរយនៃស្ថិតិរូបិយវត្ថុសំខាន់ៗ និងសន្ទស្សន៍ថ្លៃទំនិញនិងសេវា

(បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ)

| | ២00២ | ២00៣ | ២00៤ | ២00៥ | ២00៦ | ២00៧ * |
|---|---|---|---|---|---|---|
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | -៥៨,៨% | -៧,៤% | -៦៣,១% | -១0១,៨% | -១២៦,៤% | -៨0,៩% |
| ឥណទានចំពោះផ្នែកឯកជន | ១៣,១% | ២៦,២% | ៣៥,៩% | ៣១,៨% | ៥១,៦% | ៥៩,៩% |
| រូបិយវត្ថុទូទៅ (M2) | ៣១,១% | ១៥,៣% | ៣0,0% | ១៦,១% | ៣៨,២% | ៥៥,៦% |
| រូបិយវត្ថុក្នុងចរាចរណ៍ | ៣២,៦% | ១៨,៦% | ២២,៧% | ១៥,0% | ២៤,៨% | ១២,៧% |
| អតិផរណាប្រចាំឆ្នាំ | ៣,៨១% | 0,៤៦% | ៥,៦២% | ៦,៦៦% | ២,៨១% | ៨,0៦% |

* ទិន្នន័យព្យាករណ៍

## ២.២_ កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ

ក្នុងឆ្នាំ២00៧ រូបិយវត្ថុទូទៅមានកំណើនច្រើនជាងឆ្នាំមុន គឺដោយសារការកើនឡើងយ៉ាងខ្ពស់នៃកត្តាគូបផ្សំទាំងពីរ គឺទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារ ។ ទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងចំនួន ៥៧២,១ពាន់លានរៀល (២0២,៨%) និងទ្រព្យសកម្មបរទេសសុទ្ធបានកើនឡើងចំនួន ៣.២៨៩,៩ពាន់លានរៀល (៤៥,៥%) ។ កំណើនខ្ពស់នៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ បណ្តាលមកពីកំណើនគួរឱ្យកត់សម្គាល់នៃឥណទានចំពោះផ្នែកឯកជនចំនួន ២.១៧១,៣ពាន់លានរៀល (៥៩,៩%) ដែលជាអត្រាកំណើនខ្ពស់

ជាងឆ្នាំមុនៗទាំងអស់ ។ ប៉ុន្តែកំណើននៃឥណទានចំពោះផ្នែកឯកជននេះនៅក្នុងទ្រព្យសកម្មក្នុងស្រុកសុទ្ធត្រូវបានផាត់ទាត់មកវិញដោយការកើនឡើងនៃដើមទុនរបស់ប្រព័ន្ធធនាគារចំនួន ៨២៧,២ពាន់លានរៀល (២៥,៥%) ។ កត្តាសំខាន់ៗនៃកំណើនឥណទានចំពោះផ្នែកឯកជនគឺ : កំណើនឥណទានចំពោះវិស័យសេវាកម្មចំនួន ៤០២ពាន់លានរៀល (៣៥,១%) វិស័យលក់ដុំនិងលក់រាយចំនួន ៣៨២,៦ពាន់លានរៀល (៤៣,៧%) វិស័យសំណង់ចំនួន ២៥៧,២ពាន់លានរៀល (៩៥,៣%) វិស័យអចលនវត្ថុនិងការប្រើប្រាស់សាធារណៈចំនួន ១២៧,៣ពាន់លានរៀល (៤២,៦%) វិស័យកសិកម្មចំនួន ១០០ពាន់លានរៀល (៦៧,៣%) និងវិស័យកម្មន្តសាលចំនួន ៨០,៩ពាន់លានរៀល (១៩,៧%) ។

## ២.២.១. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា

ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាក្នុងអំឡុងឆ្នាំ២០០៧ បានថយចុះចំនួន ១.០៧៩,៦ ពាន់លានរៀល (៤៦%) ពោលគឺថយចុះពី -២.៣៤៥,៩ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៦ មក -៣.៤២៥,៥ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៧ នេះ បន្ទាប់ពីបានថយចុះចំនួន ៥៤៩,៤ពាន់លានរៀល (៣០,៦%) ក្នុងឆ្នាំ២០០៦ ។ ការថយចុះនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ ជាចម្បងគឺបណ្តាលមកពីការថយចុះនៃឥណទេយ្យសុទ្ធរាជរដ្ឋាភិបាលចំនួន ៧២៧,៩ពាន់លានរៀល (៩០,២%) និងការថយចុះនៃខ្ទង់ផ្សេងៗ(សុទ្ធ)ចំនួន ៣៥១,៤ពាន់លានរៀល (២៤,៣%) ។ ការថយចុះនៃឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល បណ្តាលមកពីការកើនឡើងប្រាក់បញ្ញើរាជរដ្ឋាភិបាលចំនួន ៧៤៤,៤ពាន់លានរៀល (៦៨,១%) ខណៈដែលឥណទានចំពោះរាជរដ្ឋាភិបាលបានកើនតែ ១៦,៥ពាន់លានរៀល (៥,៨%) ប៉ុណ្ណោះ ។

ក្នុងអំឡុងឆ្នាំ២០០៧ នេះដែរ ទ្រព្យសកម្មបរទេសសុទ្ធបានកើនឡើងខ្ពស់ចំនួន ២.២២១,៩ពាន់លានរៀល (៣៨,៨%) ។ កំណើនទាំងអស់នេះ បណ្តាលមកពីការកើនឡើងទាំងស្រុងនៃទ្រព្យសកម្មបរទេសចំនួន ២.២២១,៩ ពាន់លានរៀល (៣៨,៨%) ខណៈដែលទ្រព្យអកម្មបរទេសពុំមានការប្រែប្រួល ។ គួរកត់សម្គាល់ថា ថ្លៃមាសដែលជាធាតុផ្សំមួយនៃទ្រព្យសកម្មបរទេសបានបន្តកើនឡើងយ៉ាងលឿនក្នុងឆ្នាំ២០០៧ នេះ ។

## ២.២.២. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ

ក្នុងឆ្នាំ២០០៧ ទ្រព្យសកម្មសរុបរបស់បណ្តាធនាគារពាណិជ្ជបានកើនឡើងចំនួន ៤.៧៦៣,០ពាន់លានរៀល (៥៩,៨%) ក្នុងខណៈទ្រព្យអកម្មក្នុងស្រុកក្នុងរូបភាពជាប្រាក់បញ្ញើបានកើនឡើងចំនួន ៣.៦៩២,៨ពាន់លានរៀល (៦៨,៦%) និងទ្រព្យសកម្មបរទេសសុទ្ធបានកើនឡើងចំនួន ១.០៦៨,១ពាន់លានរៀល (៧១,៤%) ។

ទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងចំនួន ១.៥៤៧,៨ពាន់លានរៀល (៧៨,៩%) នៅឆ្នាំ២០០៧ នេះ ។ កំណើននេះ ជាចម្បងបណ្តាលមកពីការកើនឡើងនៃឥណទានចំពោះផ្នែកឯកជនចំនួន ២.១៧១,៤ពាន់លានរៀល (៥៥,៩%) ចំណែកឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលបានថយចុះចំនួន ៤២,៩ពាន់លានរៀល (២៥,៤%) ។ ទន្ទឹម

នេះដែរ ប្រាក់បញ្ញើរបស់បណ្តាធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជាបានកើនឡើងចំនួន ១.០២៦,៧ពាន់លានរៀល (៥៥,៩%) ចំណែកខ្ទង់ផ្សេងៗសុទ្ធបានថយចុះចំនួន ៥៣៣,២ពាន់លានរៀល (៣៤,៩%) ។ ការថយចុះនៃខ្ទង់ផ្សេងៗ(សុទ្ធ) ឆ្លុះបញ្ចាំងមួយផ្នែកពីការបង្កើនដើមទុនរបស់ធនាគារពាណិជ្ជមួយចំនួន និងដើមទុនរបស់ធនាគារទើបបើកថ្មីចំនួនបួនគឺ ធនាគារឯកទេសអភិវឌ្ឍន៍កម្ពុជា ធនាគារឯកទេសវិនិយោគរុងរឿង ធនាគារខេមខូ និងធនាគារស៊ិនហានខ្មែរ ។ ប្រាក់បញ្ញើជារូបិយប័ណ្ណរបស់និវាសជន ដែលជាធាតុផ្សំចម្បងនៃទ្រព្យអកម្មក្នុងស្រុកបានកើនឡើងចំនួន ៣.៦២៤,៩ពាន់លានរៀល (៦៩,៨%) ខណៈដែលប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ បានកើនឡើងចំនួន ១៦,៥ពាន់លានរៀល (១៨,៦%) និងប្រាក់បញ្ញើចរន្តបានកើនឡើងចំនួន ១១,៤ពាន់លានរៀល (២៧,៩%) ប៉ុណ្ណោះ ។

ទ្រព្យសកម្មបរទេសសុទ្ធរបស់បណ្តាធនាគារពាណិជ្ជបានកើនឡើងចំនួន ១.០៦៨,១ពាន់លានរៀល(៧១,៤%) ពោលគឺកើនពី ១.៤៩៥,៦ពាន់លានរៀល នៅខែធ្នូ ឆ្នាំ២០០៦ ដល់ ២.៥៦៣,៦ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៧ ។ កំណើននេះបណ្តាលមកពីការកើនឡើងនៃទ្រព្យសកម្មបរទេសចំនួន ១.៤៧៤,៨ពាន់លានរៀល (៧៦,៨%) ខណៈដែលទ្រព្យអកម្មបរទេសបានកើនឡើងតែ ៤០៦,៧ពាន់លានរៀល (៩៥,៥%) ប៉ុណ្ណោះ ។

## ២.២.៣. អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើ របស់ធនាគារពាណិជ្ជ

ផ្អែកលើគោលការណ៍នៃសេដ្ឋកិច្ចទីផ្សារ ធនាគារជាតិនៃកម្ពុជាមិនបានដាក់វិធានការរដ្ឋបាលណាមួយទៅលើអត្រាការប្រាក់ចំពោះប្រតិបត្តិការរបស់ធនាគារពាណិជ្ជ ធនាគារឯកទេស ឬមីក្រូហិរញ្ញវត្ថុឡើយ រួមទាំងការកំណត់ពិដានលើអត្រាការប្រាក់ទីផ្សារផងដែរ ។ ធនាគារជាតិនៃកម្ពុជាពុំមានចេតនានឹងបង្កឥទ្ធិពលដោយផ្ទាល់ទៅលើតម្លៃនៃឥណទាន ឬទៅលើការបែងចែកឥណទាននៅក្នុងសេដ្ឋកិច្ចទេ ។ ដូច្នេះ គ្រឹះស្ថានធនាគារទាំងឡាយមានសេរីភាពពេញលេញក្នុងការបែងចែកឥណទាន អាស្រ័យលើគោលនយោបាយឥណទាន និងការគ្រប់គ្រងហានិភ័យផ្ទាល់ ។

ក្នុងឆ្នាំ២០០៧ អត្រាការប្រាក់ឥណទាននិងប្រាក់បញ្ញើជារូបិយវត្ថុក្នុងស្រុក និងជាដុល្លារអាមេរិក ដែលវាស់ដោយកម្រិតមធ្យមថ្លឹងតាមទំហំនៃប្រតិបត្តិការធនាគារសម្រាប់រយៈពេល ៦ខែ មានការប្រែប្រួលច្រើនឬបន្តិចបន្តួចទៅតាមប្រភេទនៃរូបិយវត្ថុដែលខ្ចី ។ ជាក់ស្តែង អត្រាការប្រាក់ឥណទានជាប្រាក់ដុល្លារអាមេរិកបានថយចុះតិចតួចពី ១៧% នៅខែធ្នូ ឆ្នាំ២០០៦ មក ១៦,៩% នៅខែធ្នូ ឆ្នាំ២០០៧ ចំណែកឯអត្រាការប្រាក់ឥណទានជារៀលបានថយចុះគួរឱ្យចាប់អារម្មណ៍ពី ២៣% នៅចុងឆ្នាំ២០០៦ រហូតដល់ ១៨,៩% នៅដំណាច់ឆ្នាំនេះ ។ ទន្ទឹមនោះ អត្រាការប្រាក់បញ្ញើជាដុល្លារអាមេរិកបានកើនឡើងដល់ ៤,៣% ហើយអត្រាការប្រាក់បញ្ញើជារៀលបានកើនឡើងដល់ ៥,៩% នៅខែធ្នូ ឆ្នាំ២០០៧ ពីកម្រិត ៤,១% និង ៥,៤% រៀងគ្នានាដំណាច់ឆ្នាំមុន ។




## ៣. ជញ្ជីងទូទាត់

តាមទិន្នន័យប៉ាន់ស្មានដំបូងសម្រាប់ឆ្នាំ២00៧ នេះ ប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាបាន បង្ហាញថា សមតុល្យរួមមានអតិរេកចំនួន ២៩0លានដុល្លារអាមេរិក គឺបានកើនឡើង ៨៨លានដុល្លារអាមេរិក (៤៣,៦%) បើធៀបឆ្នាំ២00៦ ។ ការកើនឡើងអតិរេកសមតុល្យរួមនេះ ជាចម្បងគឺបណ្តាលមកពីការកើនឡើង នៃសមតុល្យគណនីដើមទុននិងហិរញ្ញវត្ថុចំនួន ៩៣,៩លានដុល្លារអាមេរិក (១២%) ស្របពេលដែលឱនភាពគណនី ចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) បានកើនឡើង ៤៦,២លានដុល្លារអាមេរិក (៨,៨%) ។ ក្នុងឆ្នាំ២00៧ នេះ ផលធៀបនៃឱនភាពគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) និងផលិតផលក្នុងស្រុកសរុបមានកម្រិត ៧,២% ។

### ៣.១. គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ)

ក្នុងឆ្នាំ២00៧ នេះ សមតុល្យគណនីចរន្តត្រូវបានប៉ាន់ស្មានថាមានឱនភាព ៥៧១,២លានដុល្លារអាមេរិក គឺបានកើនឡើង ៨,៨% ធៀបនឹងឆ្នាំ២00៦ ។ ការកើនឡើងឱនភាពជញ្ជីងពាណិជ្ជកម្មចំនួន ២0,៣% ជាមូលហេតុ សំខាន់នៃការកើនឡើងឱនភាពសមតុល្យគណនីចរន្ត ។ ឱនភាពគណនីចរន្តត្រូវបានផាត់ទាត់មួយចំណែកវិញ ដោយ ការកើនឡើងអតិរេកគណនីសេវាសុទ្ធប្រមាណ ២៧,១% និងការថយចុះឱនភាពគណនីប្រាក់ចំណូលសុទ្ធប្រមាណ ៤,៧% ។

ចំពោះការនាំចេញផលិតផលក្នុងស្រុកក្នុងឆ្នាំ២00៧ នេះ ត្រូវបានប៉ាន់ស្មានថាមានចំនួន ៣.៨៥៦,៨លាន ដុល្លារអាមេរិក គឺបានកើនឡើង ៣១៩,៦លានដុល្លារអាមេរិក (៩%) ធៀបនឹងឆ្នាំ ២00៦ ។ កត្តារួមចំណែកយ៉ាង សំខាន់ក្នុងកំណើននេះ គឺការកើនឡើងនៃការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌចំនួន ២៨៧.៨លាន ដុល្លារអាមេរិក (១0,៦%) ទោះបីជាមានការកើនឡើងភាពប្រកួតប្រជែងនៃវិស័យនេះពីប្រទេសចិន និងវៀតណាម ក៏ដោយ ក៏លក្ខខណ្ឌការងារ និងការចំណាយប្រតិបត្តិការរបស់ប្រទេសកម្ពុជានៅតែមានភាពប្រសើរ ។ ក្នុងឆ្នាំនេះ

ការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌមានសមាមាត្រ ៧៨,២% នៃការនាំចេញផលិតផលក្នុងស្រុក ។ ក្នុងអំឡុងពេលដដែលនេះ ការនាំចេញផលិតផលក្នុងស្រុកផ្សេងទៀតបានកើនឡើង ៣១,៨លានដុល្លារអាមេរិក (៤%) ក្នុងនោះរួមមាន ការកើនឡើងនៃការនាំចេញផលិតផលស្រូវ គ្រឿងសង្ហារិម និងផលិតផលកសិកម្មផ្សេងទៀត ។



ទិន្នន័យព្យាករណ៍

តម្លៃនៃការនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុក ត្រូវបានប៉ាន់ស្មានថាមានចំនួន ៥.១៤៣លានដុល្លារអាមេរិក គឺបានកើនឡើង ៥២៩,៤លានដុល្លារអាមេរិក (១១,៥%) ធៀបនឹងឆ្នាំ២០០៦ ។ កត្តាចម្បងរួមចំណែកក្នុងកំណើននេះ គឺការកើនឡើងការនាំចូលប្រេងឥន្ធនៈចំនួន ១៣២,៩លានដុល្លារអាមេរិក (១១,៨%) ។ តម្លៃនៃការនាំចូលប្រេងឥន្ធនៈក្នុងឆ្នាំនេះ មានសមាមាត្រ ២៤,៤% នៃការនាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុក ។ ចំណែកការនាំចូលទំនិញប្រើប្រាស់ក្នុងស្រុកផ្សេងទៀត ដូចជា ការនាំចូលវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់មានកំណើន ៨,៥% ហើយការនាំចូលទំនិញផ្សេងៗមានកំណើន ១៣% ។

ក្នុងអំឡុងពេលដដែលនេះ អតិរេកគណនីសេវាសុទ្ធត្រូវបានប៉ាន់ស្មានថាមានចំនួន ៦៤៣,៩លានដុល្លារអាមេរិក ពោលគឺបានកើនឡើង ១៣៧,៩លានដុល្លារអាមេរិក (២៧,១%) ធៀបនឹងឆ្នាំ ២០០៦ ។ ការកើនឡើងនៃអតិរេកនេះ ជាលទ្ធផលនៃកំណើនប្រាក់ចំណូលពីផ្នែកសេវាច្រើនលើសកំណើននៃការចំណាយទូទាត់ទៅឱ្យអនិវាសជន ។ ចំណូលពីសេវាធ្វើដំណើរ និងសេវាដឹកជញ្ជូន បានរួមចំណែកយ៉ាងសំខាន់ក្នុងកំណើននេះ ។ ក្នុងឆ្នាំនេះ ភ្ញៀវទេសចរបរទេសដែលចូលមកទស្សនាប្រទេសកម្ពុជាត្រូវបានប៉ាន់ស្មានកើនឡើងដល់ ២.០៣២.៧៥៤នាក់ ដែលចំនួននេះមានតែ ១.៧០០.០៤១នាក់ ក្នុងឆ្នាំ២០០៦ ដោយសារការកើនឡើងប្រជាប្រិយភាពនៃគោលដៅទេសចរណ៍របស់ប្រទេសកម្ពុជា ។ ចំពោះគណនីប្រាក់ចំណូលសុទ្ធត្រូវបានប៉ាន់ស្មានថា មានឱនភាពចំនួន ២៧៦,៧លានដុល្លារអាមេរិក គឺមានការថយចុះ ១៣,៧លានដុល្លារអាមេរិក (៤,៧%) ។ ការថយចុះនៃឱនភាពនេះ ជាពិសេសគឺដោយសារការថយ

ចុះនៃការផ្ទេរចេញប្រាក់ចំណូលពីភាគហ៊ុនទៅឱ្យអនិវាសជន ។ ចំណែកគណនីបង្វែរឯកជនសុទ្ធត្រូវបានប៉ាន់ស្មានថាមានអតិរេក ៣៣២លានដុល្លារអាមេរិក គឺបានកើនឡើង ១៦,៩លានដុល្លារអាមេរិក (៥,៤%) ។ កំណើននេះសំខាន់គឺត្រូវបានឆ្លុះបញ្ចាំងពីកំណើននៃការផ្ទេរប្រាក់ចូលមកប្រទេសកម្ពុជាដោយជនជាតិកម្ពុជាធ្វើការនៅក្រៅប្រទេស ។

## ៣.២_ គណនីដើមទុន និងហិរញ្ញវត្ថុ

ក្នុងឆ្នាំ២០០៧ នេះ សមតុល្យគណនីចរន្ត និងបង្វែរដើមទុនមានឱនភាព ១៥៥,៣លានដុល្លារអាមេរិក ធៀបនឹងឱនភាព ៧៥,៨លានដុល្លារអាមេរិក នាឆ្នាំកន្លងមក ។ លំហូរបង្វែរសុទ្ធត្រូវបានប៉ាន់ស្មានថា មានចំនួន ៤១៦លានដុល្លារអាមេរិក គឺបានថយចុះ ៣៣,២លានដុល្លារអាមេរិក (៧,៤%) ធៀបនឹងឆ្នាំ២០០៦ ។ គណនីបង្វែរផ្លូវការនេះបង្ហាញពីលំហូរហិរញ្ញប្បទានសហប្រតិបត្តិការ ដែលរាជរដ្ឋាភិបាលកម្ពុជាទទួលបានពីសហគមន៍អន្តរជាតិទាំងពហុភាគី និងទ្វេភាគី ក្នុងនោះរួមមាន ហិរញ្ញប្បទានសម្រាប់ទ្រទ្រង់ថវិកា ២១,៣លានដុល្លារអាមេរិក ហិរញ្ញប្បទានសម្រាប់ស្បៀងអាហារ ២៩,៤លានដុល្លារអាមេរិក ហិរញ្ញប្បទានសម្រាប់គម្រោង ១៨៦,៦លានដុល្លារអាមេរិក និងហិរញ្ញប្បទានសម្រាប់ជំនួយបច្ចេកទេស ១៧៩លានដុល្លារអាមេរិក ។ ទន្ទឹមនឹងនេះ លំហូរហិរញ្ញប្បទានជាប្រាក់កម្ចីផ្លូវការសុទ្ធ (មិនរាប់បញ្ចូលប្រាក់កម្ចីពីមូលនិធិរូបិយវត្ថុអន្តរជាតិ) ត្រូវបានប៉ាន់ស្មានថា មានចំនួន ១៧៣លានដុល្លារអាមេរិក គឺមានកំណើន ៤១% ធៀបនឹងឆ្នាំ២០០៦ ។ ក្នុងឆ្នាំនេះ លំហូរវិនិយោគផ្ទាល់បរទេសសុទ្ធត្រូវបានប៉ាន់ស្មានថាមានចំនួន ៧១១,២លានដុល្លារអាមេរិក ក្នុងនោះលំហូរវិនិយោគផ្ទាល់បរទេសផ្នែកសហគ្រាសមានចំនួន ៦១៨,១លានដុល្លារអាមេរិក ។ លំហូរវិនិយោគផ្ទាល់បរទេសផ្នែកសហគ្រាសនេះបានឆ្លុះបញ្ចាំងនូវកំណើនគម្រោងវិនិយោគផ្នែកកាត់ដេរសម្លៀកបំពាក់ និងទំនិញវាយនភ័ណ្ឌ ផ្នែកទូរគមនាគមន៍ ផ្នែកកសិកម្ម ផ្នែករមណីយដ្ឋាន ផ្នែកភេសជ្ជៈ ផ្នែកវេចខ្ចប់ ផ្នែកមន្ទីរពេទ្យ ផ្នែកផលិតស្បែកជើង និងផ្នែកសណ្ឋាគារ ។ល។




ទិន្នន័យព្យាករណ៍

ការកើនឡើងនៃគណនីដើមទុន និងហិរញ្ញវត្ថុដូចបានបង្ហាញខាងលើ មានលទ្ធភាពទ្រទ្រង់នឹងផាត់ទាត់ឱ្យឱនភាពគណនីចរន្តបានទាំងស្រុង ។ ជាលទ្ធផលនៃប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០០៧ នេះ សមតុល្យរួមមានអតិរេក ២៩០លានដុល្លារអាមេរិក ។ គិតដល់ចុងឆ្នាំ២០០៧ ទុនបម្រុងអន្តរជាតិអាចធានាឱ្យការទូទាត់ទំនិញនាំចូលបានប្រហែល ៣ខែ ។



ក្រាហ្វស្ថិតិ ១២ : លំហូរវិនិយោគបរទេស
(ឆ្នាំ២០០០-២០០៧)

ទិន្នន័យព្យាករណ៍

## ៤. ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

### ៤.១. ការងារវិនិយោគទុនបម្រុងអន្តរជាតិ

ទុនវិនិយោគដុលជារូបិយប័ណ្ណនៅបរទេសត្រូវបានធ្វើវិនិយោគក្រោមរូបភាពជា Overnight ជាការទិញប័ណ្ណរតនាគារអាមេរិក ជាប្រាក់បញ្ញើរយៈកាលខ្លី ជាឧបករណ៍រយៈកាលមធ្យម (MTI) និងជាសញ្ញាប័ណ្ណរយៈកាលវែងនៅប្រទេសបារាំង លុចហ្សំបួរ ស្វីស សហរដ្ឋអាមេរិក ហុងកុង សិង្ហបុរី និងជប៉ុន ។ គិតត្រឹមដំណាច់ឆ្នាំ២០០៧ ទុនវិនិយោគគិតជាប្រាក់ដុល្លារអាមេរិក (ដោយមិនរាប់បញ្ចូលមាស និង SDR) មានចំនួនសរុប ១.៧៦៦លានដុល្លារអាមេរិក គឺកើនឡើង ៥៦,៤% បើប្រៀបធៀបនឹងចុងខែធ្នូ ឆ្នាំ២០០៦ ដែលមានចំនួន ១.១២៩,២ លានដុល្លារអាមេរិក ។

ចំពោះប្រតិបត្តិការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) វិញ ក្នុងឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជាមានកាតព្វកិច្ចចំណាយសងលើ Net charge SDR និង Assessment SDR ចំនួន ៦៣៨.២១៦ SDRs ហើយកាតព្វកិច្ចនេះត្រូវបានផ្ទេរសងគ្រប់ចំនួនហើយ ។

នៅក្នុងឆ្នាំ២០០៧ អត្រាការប្រាក់ដុល្លារអាមេរិកត្រូវបានកាត់បន្ថយចំនួន ៣លើក ពី ៥,២៥% មក ៤,២៥% និងមានការព្យាករថា នឹងមានការកាត់បន្ថយទៀតនៅឆ្នាំក្រោយ ។ អត្រាការប្រាក់គោលអឺរ៉ូបានកើនពី ៣,៥០% ទៅ ៤% អត្រាការប្រាក់ផោនបានកើនពី ៥% ទៅ ៥,៥០% រីឯអត្រាការប្រាក់ ដុល្លារអូស្ត្រាលីបានកើនពី

៦,២៥% ទៅ ៦,៧៥% ។ កត្តានេះបណ្តាលឱ្យអត្រាការប្រាក់ Overnight ប្រែប្រួលពី ២,១៤% ទៅ ៥,២៩% អត្រាការប្រាក់ប័ណ្ណរតនាគារអាមេរិកប្រែប្រួលពី ៤,០៦% ទៅ ៥,៩៨% អត្រាការប្រាក់បញ្ញើរយៈកាលខ្លីជាប្រាក់ដុល្លារអាមេរិកប្រែប្រួលពី ៣,៩៤% ទៅ ៥,៦៣% អត្រាការប្រាក់អឺរ៉ូប្រែប្រួលពី ៣,៤៦% ទៅ ៤,៦៥% អត្រាការប្រាក់ផោនប្រែប្រួលពី ៥,៣២% ទៅ ៦,១៨% និងអត្រាការប្រាក់ដុល្លារអូស្រ្តាលីប្រែប្រួលពី ៦,១៨% ទៅ ៧,០០% ។ ថ្វីបើមានការកាត់បន្ថយអត្រាការប្រាក់ដុល្លារអាមេរិក ក៏ការវិនិយោគនៅតែទទួលបានលទ្ធផលល្អប្រសើរបើធៀបនឹងឆ្នាំ២០០៦ កន្លងមក ដោយសារការកាត់បន្ថយធ្វើនៅចុងឆ្នាំ និងទុនបម្រុងមានការកើនឡើង ។

### ៤.២. អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់

ក្នុងគោលបំណងសម្រួលឱ្យអត្រាប្តូរប្រាក់វិវត្តដោយរលូនតាមការវិវត្តនៃសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍ទិញនិងលក់ប្រាក់ដុល្លារអាមេរិកតាមសភាពការណ៍ជាក់ស្តែង ។

នៅក្នុងឆ្នាំ២០០៧ ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារអាមេរិកចំនួន ១០៧លើក ដែលមានចំនួនប្រាក់សរុប ២១០,៥៨លានដុល្លារអាមេរិក និងបានចំណាយប្រាក់រៀលអស់ចំនួន ៨៥៣,១៦ពាន់លានរៀល ។ ប្រការនេះបានរួមចំណែកនាំឱ្យបរិមាណទុនបម្រុងជារូបិយប័ណ្ណមានការកើនឡើងយ៉ាងច្រើនប្រៀបជាមួយឆ្នាំមុនៗ ។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានដាក់លក់ដេញថ្លៃប្រាក់ដុល្លារអាមេរិកតែ ១លើក ប៉ុណ្ណោះ ដែលមានចំនួន ៥០០ពាន់ដុល្លារអាមេរិក តាមអត្រា ៤.០៨៧រៀល ក្នុង ១ដុល្លារ ដោយស្រូបយកសាច់ប្រាក់រៀលពីទីផ្សារចំនួន ២.០៤៣,៥លានរៀល ។

### ៤.៣. ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់

ក្នុងឆ្នាំ២០០៧ នៅរាជធានីភ្នំពេញ ធនាគារជាតិនៃកម្ពុជាបានផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់មាសចំនួន ២៧៧ច្បាប់ និងអាជីវកម្មប្តូរប្រាក់ចំនួន ២៤ច្បាប់ និងក្រុមហ៊ុនចំនួន១ច្បាប់ ដូច្នេះសរុបទាំងអស់មានចំនួន ៣០២ច្បាប់ ។ នៅតាមសាខាធនាគារជាតិនៃកម្ពុជាខេត្តក្រុងទូទាំងប្រទេស ការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់ និងលក់មាស មានចំនួនសរុប ៣.៦៨៥ច្បាប់ ក្នុងនោះមាន អាជីវកម្មប្តូរប្រាក់ចំនួន ៧២២ច្បាប់ និងអាជីវកម្មលក់មាសចំនួន ២.៩៦៣ច្បាប់ ។

## ៥. សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

### ៥.១. ការត្រួតពិនិត្យធនាគារពាណិជ្ជ

ការបណ្តុះបណ្តាល ការកសាង និងការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីបុគ្គលិកត្រួតពិនិត្យ នៅតែជាអាទិភាព ក្នុងគោលបំណងបង្កលក្ខណៈឱ្យមន្ត្រីទាំងនោះអនុវត្តការងារប្រកបដោយប្រសិទ្ធភាព ដើម្បីពង្រឹងការត្រួតពិនិត្យលើឯកសារ ក៏ដូចជាការត្រួតពិនិត្យដល់ទីកន្លែងលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងត្រួតពិនិត្យតាមដានការអនុវត្ត

តាមប្រកាស បទបញ្ជា សារាចរណែនាំ ដែលបានចេញផ្សាយផងដែរ ។ នៅក្នុងកាលៈទេសៈដែលប្រព័ន្ធធនាគារកំពុងតែអភិវឌ្ឍកាន់តែស៊ីជម្រៅ និងស្មុគស្មាញនូវសកម្មភាពរបស់ខ្លួន តាមរយៈការបង្កើតឱ្យមាននូវផលិតផលសេវាថ្មីៗ ដូចជា ការដាក់ឱ្យប្រើប្រាស់យ៉ាងច្រើននូវម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ATM ប័ណ្ណឥណទាន ប័ណ្ណឥណពន្ធ សេវាកម្មធនាគារតាមអ៊ិនធើណែត និងទូរស័ព្ទ ការពង្រីកបណ្តាញសាខាយ៉ាងឆាប់រហ័សរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានទាមទារឱ្យមានការត្រួតពិនិត្យត្រូវតែបានពង្រឹងជារៀងរាល់ថ្ងៃ ដើម្បីការពារបាននូវហានិភ័យនៅក្នុងប្រព័ន្ធទាំងមូល ។ បច្ចុប្បន្នប្រព័ន្ធធនាគារមានម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិចំនួន ៨៦ កន្លែងនៅទូទាំងរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត-ក្រុងមួយចំនួន ។ ហើយចំនួនម៉ាស៊ីននេះនឹងត្រូវកើនឡើងថែមទៀតយ៉ាងឆាប់រហ័ស ។

ក្នុងឆ្នាំ២០០៧ នេះ ឥណទានសរុបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទៅលើវិស័យឯកជនមានការកើនឡើងពី ៣.៨៩២ពាន់លានរៀល ដល់ ៥.៤៣៨ពាន់លានរៀល ស្មើនឹង ៣៩% និងប្រាក់បញ្ញើសរុបកើនឡើងពី ៧.១៩៨ពាន់លានរៀល ដល់ ៩.១០០ពាន់លានរៀល ស្មើនឹងចំនួន ២៦% បើធៀបនឹងឆ្នាំ២០០៦ ។ គណនីប្រាក់បញ្ញើអតិថិជនបានកើនឡើងពី ២៨៥.៦៣៩គណនី ដល់ ៤៥៧.១៤៨គណនី ។ អនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារមានកម្រិតមធ្យមប្រមាណ ២៥% ខ្ពស់ជាងការតម្រូវដោយប្រកាសដែលកំណត់ត្រឹម ១៥% រីឯឥណទានមិនដំណើរការបានថយចុះពី ៩.៤៥% មកត្រឹម ៥.០១% ធៀបនឹងឆ្នាំ២០០៦ ។

ក្នុងឆ្នាំ២០០៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានផ្តល់ឥណទានសរុបចំនួនប្រមាណ ៦៩៥.៦៧៤លានរៀល កើនឡើងប្រមាណ ៨៦% បើប្រៀបធៀបនឹងឆ្នាំ២០០៦ ដែលមានឥណទានត្រឹមតែ ៣៧៤.០២១លានរៀល នឹងផ្តល់ដល់អតិថិជនប្រមាណ ៦៧៦.៩១៣នាក់ កើនឡើង ៤៤% ប្រៀបធៀបឆ្នាំមុន ដែលមានអតិថិជនប្រមាណ ៤៧១.០០៩នាក់ ។ ប្រាក់បញ្ញើសរុបមានចំនួនប្រមាណ ២២.៦៤៥លានរៀល កើនឡើង ៨៩% ប្រៀបធៀបនឹងឆ្នាំ២០០៦ ដែលមានត្រឹមតែ ១១.៩៥៤លានរៀល និងមានអ្នកដាក់ប្រាក់ផ្ញើចំនួនប្រមាណ ១៥២.៨៧៦នាក់ កើនឡើង ៣៥% ប្រៀបធៀបនឹងឆ្នាំ២០០៦ ដែលមានអ្នកដាក់ប្រាក់ផ្ញើចំនួន ១១៣.៣១៧នាក់ ។

ធនាគារជាតិនៃកម្ពុជាក៏បានចេញផ្សាយ "របាយការណ៍ត្រួតពិនិត្យធនាគារប្រចាំឆ្នាំ២០០៦" (Annual Report Banking Supervision 2006) ដែលបានបង្ហាញអំពីស្ថានភាពរបស់ប្រព័ន្ធធនាគារជារួម សម្រាប់ជាព័ត៌មានដល់សាធារណជន និងបង្ហាញអំពីមុខងារភារកិច្ចរបស់អាជ្ញាធរត្រួតពិនិត្យក្នុងកិច្ចការពារប្រព័ន្ធធនាគារឱ្យមានសុវត្ថិភាព និងសុខភាពល្អ ។

### ៥.១.១. ការត្រួតពិនិត្យលើឯកសារ

ក្នុងឆ្នាំ២០០៧ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់ប្រព័ន្ធនៃការតំឡើងរបាយការណ៍ BPR (Bank Performance Reports) និងរបាយការណ៍ COBRA (Cambodian Offsite Bank Reporting for prompt correctiveAction) ដោយស្វ័យប្រវត្តិ និងបានដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០០៧ នេះ ។ ប្រព័ន្ធ COBRA បានជួយ

សម្រួលការងារត្រួតពិនិត្យនិងវិភាគស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ ប្រព័ន្ធនេះបានផ្តល់នូវទិន្នន័យលំអិត ដែលឆ្លុះបញ្ចាំងអំពីស្ថានភាពរបស់ធនាគារនីមួយៗ ដូចជា ស្ថានភាពអនុបាតប្រុងប្រយ័ត្ន ស្ថានភាពដើមទុនផ្ទាល់ ឬស្ថានភាពចំណេញ-ខាត ដែលអាចនាំដល់ការធ្វើចំណាត់ថ្នាក់ធនាគារពាណិជ្ជផងដែរ ។

### ៥.១.២. ការត្រួតពិនិត្យដល់ទីកន្លែង

នៅក្នុងឆ្នាំ២០០៧ ធនាគារជាតិនៃកម្ពុជាបានធ្វើការត្រួតពិនិត្យដល់ទីកន្លែងពេញលេញចំពោះធនាគារពាណិជ្ជចំនួន ១២ និងធនាគារឯកទេសចំនួន ២ ព្រមទាំងការត្រួតពិនិត្យតាមមុខសញ្ញា ចំពោះធនាគារពាណិជ្ជចំនួន ២ និងធនាគារឯកទេសចំនួន ២ ។ ការត្រួតពិនិត្យពេញលេញត្រូវបានធ្វើឡើងស្របតាមផែនការដែលបានដាក់ចេញប្រចាំឆ្នាំ ការត្រួតពិនិត្យតាមមុខសញ្ញាត្រូវបានធ្វើឡើងតាមការចង្អុលបង្ហាញដោយការត្រួតពិនិត្យលើឯកសារ ។ រាល់ចំណុចខ្វះខាតដែលបានរកឃើញឆ្លងតាមការត្រួតពិនិត្យ ត្រូវបានផ្តល់ជាអនុសាសន៍ និងដាក់ចេញនូវវិធានការកែតម្រូវ ដើម្បីឱ្យសាម៉ីធនាគារអនុវត្តនិងធ្វើការកែតម្រូវទៅតាមស្ថានភាពនៃធនាគារនីមួយៗ ។

និយាយរួម ការងារត្រួតពិនិត្យលើឯកសារ និងការងារត្រួតពិនិត្យដល់ទីកន្លែង ជាការងារពីរដែលបំពេញឱ្យគ្នាទៅវិញទៅមក និងនាំមកនូវការឆ្លុះបញ្ចាំងអំពីស្ថានភាពពិតប្រាកដរបស់ធនាគារនីមួយៗ ។ ជាលទ្ធផល នៅក្នុងឆ្នាំ២០០៧ នេះ ធនាគារភាគច្រើនកាន់តែមានភាពប្រសើរឡើង ក្នុងការគោរពច្បាប់ និងបទបញ្ជា ក៏ដូចជាលទ្ធភាពរកចំណេញ ដោយសារតែភាពប្រសើរឡើងនៃការគ្រប់គ្រង និងដំណើរការអាជីវកម្ម ។

## ៥.២. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ក្នុងឆ្នាំ២០០៧ ធនាគារជាតិនៃកម្ពុជាបានចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីពិនិត្យសកម្មភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណចំនួន ៩ និងអង្គការសមាគមដែលបានចុះបញ្ជីចំនួន ៧ និងអង្គការសមាគមដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីជាប្រតិបត្តិករឥណទានជនបទចំនួន ៤ ។ លទ្ធផលនៃការត្រួតពិនិត្យបានបង្ហាញឱ្យឃើញពីស្ថានភាពល្អប្រសើរ ទាំងការគ្រប់គ្រង ប្រតិបត្តិការ និងលទ្ធភាពរកប្រាក់ចំណេញ ដើម្បីរក្សានិរន្តរភាព ។ គ្រឹះស្ថានមួយចំនួនអាចស្វែងរកដៃគូវិនិយោគ និងកម្ចីពីក្រៅប្រទេស ដើម្បីពង្រីកសកម្មភាពរបស់ខ្លួនឱ្យកាន់តែទូលំទូលាយឡើង ។ ក៏ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅតែមានតម្រូវការក្នុងការបណ្តុះបណ្តាលជាប្រចាំពង្រឹងខ្លួនឱ្យកាន់តែរឹងមាំ ដើម្បីឆ្លើយតបបាននឹងតម្រូវការសេវាមីក្រូហិរញ្ញវត្ថុដែលកាន់តែរីកធំឡើង ។

ក្នុងឆ្នាំ២០០៧ ដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារជាតិនៃកម្ពុជាបានរៀបចំសេចក្តីព្រាងប្រកាស ដើម្បីអនុញ្ញាតឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់អាចទទួលប្រាក់សន្សំពីសាធារណជនបាន និងកំពុងពិនិត្យឡើងវិញនូវប្លង់គណនីឯកភាព (Chart of Account) ដើម្បីឱ្យស៊ីចង្វាក់គ្នាជាមួយប្លង់គណនីឯកភាពរបស់ធនាគារពាណិជ្ជ ។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និសីទចំនួន២លើក គឺនៅទីរួមខេត្តកំពង់ចាម សហការជាមួយ APRACA និងទីក្រុងភ្នំពេញ សហការជាមួយ UNDP, IFC, ANZ Royal, និងសមាគមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានអ្នកចូលរួមប្រមាណ ១០០០នាក់ ក្នុងនោះ រួមមានអ្នកចូលរួមពីស្ថាប័នមីក្រូហិរញ្ញវត្ថុក្រៅប្រទេសផងដែរ ។ សន្និសីទនេះមានគោលបំណងផ្សព្វផ្សាយឱ្យសាធារណជន អាជ្ញាធរគ្រប់ជាន់ថ្នាក់ ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុទាំងអស់ឱ្យបានជ្រួតជ្រាបអំពីប្រតិបត្តិការ និងផលប្រយោជន៍នៃការប្រើប្រាស់សេវាហិរញ្ញវត្ថុជនបទផ្លូវការ ។ សន្និសីទក៏បានពិភាក្សាផ្លាស់ប្តូរយោបល់រវាងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ភាគទុនិក វិនិយោគិន និងអ្នកផ្តល់ជំនួយ ដើម្បីលើកយកបទពិសោធន៍នៃការអនុវត្តល្អៗពីអន្តរជាតិ និងឈានទៅរកការបង្កើតក្របខ័ណ្ឌយុទ្ធសាស្ត្រទំនាក់ទំនងរវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារពាណិជ្ជ អំពីការផ្តល់ទុនឥណទាន ។

## ៥.៣- ការជម្រះបញ្ជីធនាគារ

នៅឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជានៅតែបន្តអនុវត្តការជម្រះបញ្ជីធនាគារតាមរយៈការប្រមូលបំណុលរបស់ធនាគារសន្តិភាពពាណិជ្ជ ធនាគារក្រៅប្រទេសទី ១ ចំកាត់ ដោយទទួលបានលទ្ធផលល្អប្រសើរ ។

## ៥.៤- ការងាររៀបចំបទបញ្ញា

ក្នុងឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសថ្មីចំនួន ២ គឺ :

- ប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ប្រកាសស្តីពី អនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

និងធ្វើវិសោធនកម្មប្រកាសចំនួន ២ គឺ :

- ប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារ
- ប្រកាសស្តីពីស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

## ៥.៥- អាជ្ញាប័ណ្ណ និងការចុះបញ្ជី

បច្ចុប្បន្នប្រព័ន្ធធនាគារនៅកម្ពុជា រួមមានធនាគារពាណិជ្ជចំនួន ១៧ ធនាគារឯកទេសចំនួន ៧ មីក្រូហិរញ្ញវត្ថុចំនួន ១៧ និងបានផ្តល់វិញ្ញាបនប័ត្រជាប្រតិបត្តិករឥណទានជនបទចំនួន ២៥ ។ ទន្ទឹមនឹងនេះដែរ ក៏បានសម្រេចផ្តល់អាជ្ញាប័ណ្ណដល់សាខា ខេត្ត-ក្រុង របស់ធនាគារពាណិជ្ជ រួមមាន:

- ធនាគារកាណាឌីយ៉ា ក.អ ចំនួន ៤
- ធនាគារកម្ពុជាសាធារណៈ ចំនួន ៤
- ធនាគារ អេ អិន ហ្សេត រ៉ូយ៉ាល់ កម្ពុជា ចំនួន ៤
- សាជីវកម្មធនាគារសិង្ហបុរី ចំកាត់ ចំនួន ២

## ៥.៦. ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

### ៥.៦.១. សមាជិកភាព និងការវាយតម្លៃអញ្ញមញ្ញ

ប្រទេសកម្ពុជាបានក្លាយជាសមាជិកពេញសិទ្ធិនៃក្រុមអាស៊ីប៉ាស៊ីហ្វិកស្តីពីការសំអាតប្រាក់ (APG) កាលពីខែមិថុនា ឆ្នាំ២០០៥ បន្ទាប់ពីបានចូលរួមជាអ្នកសង្កេតការណ៍នៃ APG នៅខែកុម្ភៈ ឆ្នាំ១៩៩៧ ។ ក្នុងនាមជាសមាជិកនេះ ប្រទេសកម្ពុជាត្រូវអនុវត្តតាមអនុសាសន៍ ៤0 ស្តីពីការសំអាតប្រាក់ និងអនុសាសន៍ពិសេស ៩ ស្តីពីហិរញ្ញប្បទានភេរវកម្ម (អនុសាសន៍ ៤0+៩) របស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ។ ក្នុងនាមជាសមាជិក APG កម្ពុជាត្រូវទទួលរងការវាយតម្លៃអញ្ញមញ្ញពីធនាគារពិភពលោក និង APG ដូចជាសមាជិកដទៃទៀតដែរ ។

ការវាយតម្លៃអញ្ញមញ្ញលើប្រទេសកម្ពុជា ត្រូវបានធ្វើឡើងដោយធនាគារពិភពលោក និង APG កាលពីថ្ងៃទី ២៦ ខែកុម្ភៈ ដល់ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២00៧ ។ ការវាយតម្លៃនេះផ្តោតទៅលើការអនុវត្តតាមអនុសាសន៍ ៤0+៩ របស់ FATF ។ លទ្ធផលនៃរបាយការណ៍នេះត្រូវបានអនុម័តនៅក្នុងមហាសន្និបាតលើកទី ១0 ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ២៣-២៦ ខែកក្កដា ឆ្នាំ២00៧ ហើយប្រទេសកម្ពុជាបានទទួលការវាយតម្លៃថា អនុវត្តបានតាមផ្នែក (Partially Compliant) ចំនួន ១៣ អនុសាសន៍ ក្នុងចំណោមអនុសាសន៍ ៤0+៩ ។ ទោះបីជាកម្ពុជានៅខ្វះចន្លោះជាច្រើនក្នុងការអនុវត្តអនុសាសន៍ក៏ដោយ ក៏មហាសន្និបាតបានលើកសរសើរ និងលើកទឹកចិត្តដល់កម្ពុជាយើង អំពីកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតឱ្យមានក្របខ័ណ្ឌច្បាប់ និងបទបញ្ញាមួយចំនួន ក្នុងការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនេះ ។

### ៥.៦.២. ច្បាប់ និងបទប្បញ្ញត្តិ

ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២00៧ ។ ច្បាប់នេះបានដាក់ចេញនូវកាតព្វកិច្ចប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មសម្រាប់បុគ្គលរាយការណ៍ ដែលរួមមាន វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ការរក្សាទុកឯកសារកត់ត្រា ការត្រួតពិនិត្យប្រតិបត្តិការ ការរាយការណ៍ប្រតិបត្តិការសង្ស័យ និងប្រតិបត្តិការសាច់ប្រាក់ និង ការត្រួតពិនិត្យផ្ទៃក្នុងនិងតម្រូវការប្រតិបត្តិ ។ ច្បាប់នេះ បានផ្តល់សិទ្ធិសម្រាប់ការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ កំណត់នូវតម្រូវការត្រួតពិនិត្យ និងផ្តល់ជាក្របខ័ណ្ឌសម្រាប់កិច្ចសហប្រតិបត្តិការអំពីការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មទាំងក្នុងនិងក្រៅប្រទេសផងដែរ ។

ដើម្បីអនុវត្តច្បាប់នេះ ធនាគារជាតិនៃកម្ពុជា កំពុងពិនិត្យឡើងវិញលើប្រកាសស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលប្រកាសនេះនឹងជំនួសប្រកាសស្តីពីនីតិវិធីជាបទដ្ឋានសម្រាប់ការកំណត់អត្តសញ្ញាណនៃការសំអាតប្រាក់នៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងសារាចរណែនាំស្តីពីប្រតិបត្តិការសង្ស័យ និង

## ៦. ការផ្តត់ផ្គង់សេវាធនាគារកណ្តាល

### ៦.១. សេវាផ្នែកគណនី

ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងគណនីស្ថាប័នរដ្ឋ អង្គភាពរដ្ឋបាលកណ្តាល គណនីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្ម និងគណនីគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ។ សរុបគណនីទាំងអស់មានចំនួន ១.១៦៤គណនី ដែលជារូបិយវត្ថុជាតិ និងរូបិយប័ណ្ណដុល្លារអាមេរិក ។ ប្រតិបត្តិការសរុបក្នុងឆ្នាំ២០០៧ មានចំនួន ១៥៨.០៩៦ប្រតិបត្តិការ ពោលគឺមានការកើនឡើង ៦% បើធៀបទៅនឹងឆ្នាំ២០០៦ ដែលមានចំនួន ១៤៨.៧៥៥ប្រតិបត្តិការ ។

#### ៦.១.១. សេវាផ្នែកគណនីចំពោះស្ថាប័នរដ្ឋ

ធនាគារជាតិនៃកម្ពុជាក៏បានរួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើនប្រសិទ្ធភាពកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយទទួលបើកគណនីជូនស្ថាប័នរដ្ឋបាលកណ្តាលគ្រប់គ្រង និងចាត់សម្រួលសាច់ប្រាក់តាមរយៈការបង្វែរប្រាក់រតនាគារជាតិ និងបើកប្រាក់បៀវត្សជូនមន្ទីរ-ក្រសួង និងកងកម្លាំងប្រដាប់អាវុធ ។

ការបង់ពន្ធដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជាពីសំណាក់អ្នកបង់ពន្ធ បានប្រព្រឹត្តទៅដោយរលូនមានបរិមាណ ១.២៦៧ ពាន់លានរៀល (គិតទាំងចំណូលជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក) ។

#### ៦.១.២. សេវាផ្នែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

គណនីដែលធនាគារពាណិជ្ជបានបើកនៅធនាគារជាតិនៃកម្ពុជារួមមាន គណនីចរន្ត គណនីប្រាក់បញ្ញើមានកាលកំណត់ គណនីប្រាក់បញ្ញើធានាលើដើមទុន និងគណនីប្រាក់បម្រុងកាតព្វកិច្ច ។ នៅចុងឆ្នាំ២០០៧ នេះ សមតុល្យប្រាក់បញ្ញើមានកាលកំណត់រយៈពេល ១ខែ ៣ខែ និង៦ខែ មានចំនួនសរុប ៣៣៩លានដុល្លារអាមេរិក ។

### ៦.២. សេវាផាត់ទាត់

#### ៦.២.១. ការផាត់ទាត់មូលប្បទានប័ត្រជាប្រាក់រៀល

សភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់រៀលមានសមាជិកចំនួន ១៨ ដែលរួមមាន ធនាគារពាណិជ្ជចំនួន ១៥ រតនាគារជាតិ ធនាគារឯកទេស ១ និងធនាគារជាតិនៃកម្ពុជា ។

ក្នុងឆ្នាំ២០០៧ នេះការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀលបានដំណើរការចំនួន ២៤០ថ្ងៃ មានមូលប្បទានប័ត្រចំនួន ២៣.១៦០សន្លឹក ដែលមានប្រាក់សរុបចំនួន ៨៤៥.១៣០លានរៀល ។ សកម្មភាពផាត់ទាត់ក្នុងឆ្នាំ២០០៧ នេះ មានការកើនឡើងបន្តិចទាំងចំនួនមូលប្បទានប័ត្រ និងចំនួនប្រាក់ បើធៀបទៅនឹងឆ្នាំ២០០៦ ពោលគឺកើនពី ១៩.៨៧០សន្លឹក ទៅ ២៣.១៦០សន្លឹក (១៧%) និងចំនួនប្រាក់កើនពី ៦៧២ពាន់លានរៀល ទៅ ៨៤៥,១៣ពាន់លានរៀល (២៦%) ។

### ៦.២.២. ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារអាមេរិក

សភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិកមានសមាជិកចំនួន ២១ ដែលរួមមាន ធនាគារពាណិជ្ជចំនួន១៧ ធនាគារឯកទេស ៣ និងធនាគារជាតិនៃកម្ពុជា ។

សកម្មភាពនៃការផាត់ទាត់ក្នុងឆ្នាំ២០០៧ បានដំណើរការចំនួន ២៤០ថ្ងៃ ធ្វើការផាត់ទាត់លើមូលប្បទានប័ត្រចំនួន ៣២២.២៤០សន្លឹក មានចំនួនប្រាក់ ៤.៦៦០លានដុល្លារអាមេរិក ។ សកម្មភាពផាត់ទាត់មានការកើនឡើងទាំងចំនួនមូលប្បទានប័ត្រ និងចំនួនប្រាក់បើធៀបទៅនឹងឆ្នាំ២០០៦ ពោលគឺចំនួនមូលប្បទានប័ត្រកើនពី ២៥៩.៥០០សន្លឹក ទៅ ៣២២.២៤០សន្លឹក (២៦%) និងចំនួនប្រាក់កើនពី ២.៨៦០លានដុល្លារអាមេរិក ទៅ ៤.៦៦០លានដុល្លារអាមេរិក (៦៣%) ។

## ៦.៣. ការងារឥណទាន

ក្នុងឆ្នាំ២០០៧ ធនាគារជាតិនៃកម្ពុជាបានផ្តល់ឥណទាន និងប្រមូលបំណុល ដូចខាងក្រោម :

- គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ : សមតុល្យដើមគ្រា ៤៧.១២០លានរៀល ឱ្យខ្ចីក្នុងគ្រា ១២៨.៣២០លានរៀល ប្រមូលបំណុល ១០៥.០៤០លានរៀល សមតុល្យចុងគ្រា ៦៦.៨០០លានរៀល ។
- ឥណទានចំពោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់សងបំណុល ODA ជប៉ុន : ឱ្យខ្ចី ៤៧២,៥លានយ៉េន ប្រមូលបំណុល ៩៤,៥លានយ៉េន សមតុល្យចុងគ្រា ៣៧៨លានយ៉េន ។

## ៦.៤. ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរាជរដ្ឋាភិបាល

### ក. ហិរញ្ញប្បទានឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន

#### ក.១. ហិរញ្ញប្បទានឥតសំណងក្នុងគម្រោង

ក្នុងឆ្នាំ២០០៧នេះ រដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងបន្ថែមដល់រាជរដ្ឋាភិបាលកម្ពុជាចំនួន ៤ គម្រោង ហើយធនាគារជាតិនៃកម្ពុជាបានចេញ Authorization to Pay រួចហើយ រួមមាន :

១. គម្រោងសិក្សា និងគំនូរប្លង់ នៃគម្រោងការពារទឹកជំនន់ និងកែលំអប្រព័ន្ធប្រឡាយ លូ ក្នុងរាជធានីភ្នំពេញជំហានទី២ មានទឹកប្រាក់ចំនួន ៤៩លានយ៉េន ។

២. គម្រោងការពារទឹកជំនន់ និងកែលំអប្រព័ន្ធប្រឡាយ លូ ក្នុងរាជធានីភ្នំពេញ ជំហានទី ២ មានទឹកប្រាក់ចំនួន ២.៩៩៥លានយ៉េន ។

៣. គម្រោងការស្រាវជ្រាវ និងអភិវឌ្ឍសម្ភារៈបោសសម្អាតមីន ជំហានទី ២ មានទឹកប្រាក់ចំនួន ៤៨៤ លានយ៉េន ។

៤. គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស (Scholarship 0710) មានទឹកប្រាក់ ៣៦៤លានយ៉េន ។ ចំពោះគម្រោងដែលបានផ្តល់កាលពីឆ្នាំមុនៗ អនុវត្តមិនទាន់ចប់នៅឡើយ រួមមាន :

- គម្រោងកែលំអបរិក្ខារសន្តិសុខ និងសម្ភារៈ នៅកំពង់ផែអន្តរជាតិសំខាន់ៗ អនុវត្តរហូតដល់ខែមីនា ឆ្នាំ២០០៨
- គម្រោងធ្វើការសិក្សាសាងសង់វារីអគ្គិសនីធុនតូចសម្រាប់អគ្គិសនីភាវូបនីយកម្ម នៅជនបទដាច់ស្រយាល ខេត្តរតនគិរី អនុវត្តរហូតដល់ខែមីនា ឆ្នាំ២០០៨
- គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស (Scholarship 0609) អនុវត្តរហូតដល់ខែមីនា ឆ្នាំ២០១០
- គម្រោងពង្រីកផ្លូវជាតិលេខ ១ អនុវត្តរហូតដល់ខែមីនា ឆ្នាំ២០០៩
- គម្រោងស្តារស្ពានតាមដងផ្លូវសំខាន់ៗ អនុវត្តរហូតដល់ខែមីនា ឆ្នាំ២០០៨ ។

**ក.២- ហិរញ្ញប្បទានឥតសំណងក្រៅគម្រោង** (Non-Project)

ដើម្បីជួយសម្រាលបន្ទុកថវិកាជាតិ ឆ្នាំ២០០៧ នេះ រដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងក្រៅគម្រោងដល់រាជរដ្ឋាភិបាលកម្ពុជានូវទឹកប្រាក់ចំនួន ១.២០០លានយ៉េន ។ គម្រោងនេះអនុវត្តដោយ Japan International Cooperation System (JICS) សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។ ទឹកប្រាក់ហិរញ្ញប្បទានឥតសំណងខាងលើត្រូវបានបង្វែរចូលថវិកាជាតិ គ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយបានដាក់តំកល់នៅធនាគារជាតិនៃកម្ពុជា ។

**ក.៣- កម្ចីសម្បទានរបស់រាជរដ្ឋាភិបាលជប៉ុន**

នៅក្នុងឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជាបានចុះកិច្ចសម្រុបសម្រួលធនាគារលើទឹកប្រាក់កម្ចីសម្បទានថ្មីសម្រាប់គម្រោង ២ គឺ គម្រោងកាត់បន្ថយភាពក្រីក្រ មានទឹកប្រាក់ ១.០០០លានយ៉េន និងគម្រោងអភិវឌ្ឍន៍បណ្តាញថាមពលមហាតំបន់ទន្លេមេគង្គ មានទឹកប្រាក់ចំនួន ២.៦៣២លានយ៉េន ។

ចំពោះកម្ចីសម្បទានដែលបានផ្តល់កាលពីឆ្នាំមុនៗ ហើយកំពុងអនុវត្ត រួមមាន:

- គម្រោងពង្រីកកំពង់ផែក្រុងព្រះសីហនុ មានទឹកប្រាក់ចំនួន ៤.៣១៣លានយ៉េន ហើយនៅមានសមតុល្យចំនួន ២.៦២៩,៥លានយ៉េន

- គម្រោងអភិវឌ្ឍន៍កំពង់ផែក្រុងព្រះសីហនុ មានទឹកប្រាកចំនួន ៣១៨លានយ៉េន ហើយនៅមានសមតុល្យចំនួន ២៧៨លានយ៉េន
- គម្រោងទ្រទ្រង់បណ្តាញគមនាគមន៍មហាតំបន់ទន្លេមេគង្គ មានទឹកប្រាក់ចំនួន ៣.០២៩លានយ៉េន ហើយពុំទាន់ប្រើប្រាស់នៅឡើយ (តាមតួលេខពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ។

## ៧. ការគ្រប់គ្រងចរាចរណ៍ធនប័ត្រ

បច្ចុប្បន្នចរន្តលំហូរចូល-ចេញនៃសាច់ប្រាក់តាមរយៈប្រព័ន្ធគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឆ្លងកាត់បេឡាប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជាមានការកើនឡើងជាលំដាប់ ។ ជាក់ស្តែងក្នុងឆ្នាំ២០០៧ នេះ ចំណូលសាច់ប្រាក់តាមបេឡាប្រតិបត្តិការសរុបចំនួន ៥.៤៤៦,៣២ពាន់លានរៀល ។ បើប្រៀបធៀបជាមួយឆ្នាំ២០០៦ កើនឡើង ៥០,៧៥% ។ ក្នុងនោះ ចំណូលសាច់ប្រាក់បង់ពន្ធគ្រប់ប្រភេទបញ្ចូលក្នុងគណនីប្រាក់បញ្ញើចរន្តរបស់រតនាគារជាតិកើន ១៧,៤៨% ចំណូលសាច់ប្រាក់ពីប្រាក់បញ្ញើចរន្តនានាកើន ១៦៧,៧៦% ចំណូលសាច់ប្រាក់បង់ថ្លៃអគ្គិសនីកម្ពុជាកើន ១៩,៦៩% និងចំណូលសាច់ប្រាក់ផ្សេងៗទៀតកើន ៥១,៩៧% ។

ចំណែកឯសាច់ប្រាក់ចំណាយតាមបេឡាប្រតិបត្តិការសរុបវិញមានចំនួន ៥.៤៤៦,៣២ពាន់លានរៀល ។ បើប្រៀបធៀបនឹងឆ្នាំ២០០៦ កើនឡើង ៥០,៧៥% ។ ក្នុងនោះ សាច់ប្រាក់បើកឱ្យរតនាគារជាតិកើន ៤៤,១៨% លក់ប្រាក់រៀល (ទិញដុល្លារ) កើន ៣៥៦,៨១% ការដកប្រាក់បញ្ញើផ្សេងៗកើន ៨៥,៥៣% អគ្គិសនីកម្ពុជាកើន ១៩,៧៤% លើកលែងតែសាច់ប្រាក់ចំណាយផ្សេងៗបានថយចុះ ២៩,៦៩% ។

រីឯសកម្មភាពទទួលប្រាក់ដុល្លារអាមេរិកតាមបេឡាប្រតិបត្តិការវិញ មានចំនួន ១.៦៨៣,៤៥លានដុល្លារអាមេរិក ។ បើប្រៀបធៀបនឹងឆ្នាំ២០០៦ កើនឡើង ៣៤,១៣% ។ ចំណែកឯចំណាយតាមរយៈបេឡាប្រតិបត្តិការវិញ មានចំនួន ១.៦៨៣,២លានដុល្លារអាមេរិក ។ បើប្រៀបធៀបនឹងគ្រាដូចគ្នានៃឆ្នាំ២០០៦ កើនឡើង ៣៤,១៣% ។

ធនាគារជាតិនៃកម្ពុជាបានបញ្ចេញក្រដាសប្រាក់ថ្មីដើម្បីដូរយកក្រដាសប្រាក់ចាស់ៗខូចគុណភាពពីទីផ្សារមកវិញ ដើម្បីធ្វើឱ្យក្រដាសប្រាក់ក្នុងចរាចរណ៍មានលក្ខណៈថ្មីស្អាតល្អ និងកាន់តែជំរុញឱ្យសាធារណជនមានជំនឿមុតមាំមកលើប្រាក់រៀល ។

ក្រដាសប្រាក់ចាស់ៗដែលដូរបាន ធនាគារជាតិនៃកម្ពុជាបានធ្វើការរាប់-ស្រាល់ជ្រើសយ៉ាងហ្មត់ចត់ និងធ្វើការកាត់កម្ទេច និងដុតបំផ្លាញចោលតាមនីតិវិធីត្រឹមត្រូវ ។

ធនាគារជាតិនៃកម្ពុជាបានសហការជានិច្ចជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ការប្រើប្រាស់ក្រដាសប្រាក់ក្លែងក្លាយក្នុងចរាចរណ៍ ។

## II- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១. សកម្មភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជានាពេលបច្ចុប្បន្នមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| - ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| - លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិក |
| - ឯកឧត្តម អ៊ូន ព័ន្ធមុនីរ័ត្ន | តំណាងប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| - ឯកឧត្តម អ៊ីវ ថុង | តំណាងមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| - ឯកឧត្តម ជូ គីមឡេង | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - លោក ឡាយ ម៉េងស៊ុន | តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក |
| - លោកស្រី ម៉ៅ សុន | តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិក ។ |

ក្នុងឆ្នាំ២០០៧នេះ ក្រុមប្រឹក្សាភិបាលបានប្រជុំចំនួន ៦លើក ដើម្បីពិភាក្សា និងអនុម័តលើការងារមួយចំនួនដូចខាងក្រោម :

- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៦០ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជាសម្រាប់ការិយបរិច្ឆេទឆ្នាំ២០០៦
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៦១ នាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៧ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជា ឆ្នាំ២០០៦ និងផែនការថវិកាឆ្នាំ២០០៧
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៦២ នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០០៧ របស់ធនាគារជាតិនៃកម្ពុជា
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៦៣ នាថ្ងៃទី ៩ ខែសីហា ឆ្នាំ២០០៧ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ចំណូល-ចំណាយថវិកា ឆមាសទី១ ឆ្នាំ២០០៧ របស់ធនាគារជាតិនៃកម្ពុជា
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៦៤ នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៧ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងប្រកាសស្តីពីរចនាសម្ព័ន្ធ និងមុខងារភារកិច្ចរបស់នាយកដ្ឋានប្រតិបត្តិការ
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៦៥ នាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ឆ្នាំ២០០៧ និងទិសដៅការងារឆ្នាំ២០០៨ របស់ធនាគារជាតិនៃកម្ពុជា ។

## ២. ការអភិវឌ្ឍធនធានមនុស្ស

### ២.១. ស្ថិតិមន្ត្រីបុគ្គលិក

- មន្ត្រីបុគ្គលិកក្នុងក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជាទីស្នាក់ការកណ្ដាល ក្នុងឆ្នាំ២០០៧ នេះ មានចំនួន ៧៦២រូប (ប្រុស ៤៣០រូប ស្រី ៣៣២រូប) និងមន្ត្រីបុគ្គលិកក្រៅក្របខ័ណ្ឌមានចំនួន១៥រូប (ប្រុស ១៤រូប ស្រី ១រូប)
- មន្ត្រីរក្សាក្របខ័ណ្ឌមានចំនួន ៣រូប (ប្រុស ២រូប ស្រី ១រូប)
- មន្ត្រីបុគ្គលិកក្នុងក្របខ័ណ្ឌសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង មានចំនួន ៣៦២រូប (ប្រុស ២០៩ រូប ស្រី ១៥៣រូប) ។

សរុបក្របខ័ណ្ឌមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសក្នុងឆ្នាំ២០០៧ នេះ មានចំនួន ១១២៧ រូប (ប្រុស ៦៤១រូប ស្រី ៤៨៦រូប) បើប្រៀបធៀបជាមួយក្របខ័ណ្ឌចុងខែធ្នូ ឆ្នាំ២០០៦ ដែលមានចំនួន ១០៣២ រូប (ប្រុស ៥៨៧រូប ស្រី ៤៤៥រូប) មានការប្រែប្រួលដូចតទៅ:

- ទីស្នាក់ការកណ្ដាលកើនចំនួន ៥៩រូប (ចូល ៨០រូប ចេញ ២១រូប)
- សាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងកើនចំនួន ៣៥រូប (ចូល ៤៨រូប ចេញ ១៣រូប)

### ២.២. ការងារបណ្ដុះបណ្ដាល

នៅឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំវគ្គណែនាំប្រតិបត្តិការចំនួន ៣វគ្គ (មន្ត្រីបុគ្គលិក ចូលរួមចំនួន ៦៩រូប) វគ្គសុក្រឹតការចំនួន ១វគ្គ (មន្ត្រីបុគ្គលិក ចូលរួមចំនួន ៨២រូប) វគ្គបណ្ដុះបណ្ដាលភាសាអង់គ្លេសចំនួន ៨ថ្នាក់ និងភាសាថៃ ១ថ្នាក់ (មន្ត្រីបុគ្គលិកចូលរួមចំនួន ១១៥រូប) និងសិក្ខាសាលាចំនួន ៨លើក នៅធនាគារជាតិនៃកម្ពុជា (សរុបមន្ត្រីបុគ្គលិកចូល រួមចំនួន ៣៦៤រូប) ។

ធនាគារជាតិនៃកម្ពុជាក៏បានបញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមក្នុងសិក្ខាសាលា តាមការអញ្ជើញពីបណ្ដាក្រសួង-ស្ថាប័ននានាផងដែរ ក្នុងនោះមានសិក្ខាសាលាចំនួន ៦លើក មានមន្ត្រីបុគ្គលិកចូលរួមចំនួន ៥៥រូប ។

ម្យ៉ាងវិញទៀតធនាគារជាតិនៃកម្ពុជាក៏បានចាត់បញ្ជូនមន្ត្រីបុគ្គលិក ឱ្យទៅចូលរួមការបណ្ដុះបណ្ដាលរយៈពេលវែងចំនួន ៣លើក ដែលមានមន្ត្រីបុគ្គលិកចូលរួមចំនួន ៨រូប និងវគ្គបណ្ដុះបណ្ដាលនៅមជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការបណ្ដុះបណ្ដាល (ACE) សរុប ៤១រូប ។

ចំពោះការងារបណ្ដុះបណ្ដាលនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារក្នុងឆ្នាំ២០០៧ នេះ និស្សិតជំនាន់ទី ១៥ ដែលជាមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាចំនួន ១៥នាក់ បានបញ្ចប់ការសិក្សាថ្នាក់ប្រកាសនីយប័ត្រជាន់ខ្ពស់បច្ចេកទេសធនាគារ ដោយឡែក និស្សិតជំនាន់ទី ១៧ ត្រូវបានជ្រើសរើស ក្នុងនោះមាន មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាចំនួន ២១រូប ។

ទន្ទឹមនឹងការបណ្តុះបណ្តាលនៅក្នុងប្រទេស ធនាគារជាតិនៃកម្ពុជាក៏បានបន្តបង្កើនសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួននៅក្រៅប្រទេសផងដែរ តាមរយៈការចាត់បញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមវគ្គបណ្តុះបណ្តាល (ចំនួន ៥លើក, មន្ត្រីចូលរួម ៦រូប) សិក្ខាសាលា (ចំនួន ១០៦លើក មន្ត្រីចូលរួម ១៤៧រូប) និងទស្សនកិច្ចសិក្សា (ចំនួន ៥លើក មន្ត្រីចូលរួម ២១រូប) តាមការអញ្ជើញរបស់ស្ថាប័នអន្តរជាតិ ធនាគារកណ្តាលជាដៃគូ និងប្រទេសក្នុងតំបន់ ។

ក្រៅពីវគ្គសិក្សារយៈពេលខ្លី ធនាគារជាតិនៃកម្ពុជា ក៏បានចាត់បញ្ជូនមន្ត្រីបុគ្គលិក ឱ្យចូលរួមបន្តការសិក្សារយៈពេលវែងថ្នាក់អនុបណ្ឌិត (ចំនួន ៤លើក, មន្ត្រីចូលរួម ៨រូប) តាមរយៈកម្មវិធីអាហារូបករណ៍របស់ Japan-IMF, IMF-Australia, Ausaid និង JICA ។

## ៣~ ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

ក្នុងឆ្នាំ២០០៧នេះ ការងារពង្រឹងអគ្គាធិការដ្ឋាននៅតែបន្ត តាមរយៈការពង្រឹងការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចឱ្យមានប្រសិទ្ធភាពដោយបន្តរៀបចំលិខិតបទដ្ឋានចាំបាច់នានា ដូចជា ប្រកាសស្តីពីលក្ខន្តិកៈនៃគណៈ-កម្មការត្រួតពិនិត្យបញ្ជីគណនេយ្យរបស់ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ប្រកាសស្តីពីមុខងារភារកិច្ចរបស់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន សៀវភៅនីតិវិធីសវនកម្មសម្រាប់នាយកដ្ឋាន សាខា និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ។ នៅចុងឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសចំនួនពីរគឺ (១) ប្រកាសស្តីពីគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារជាតិនៃកម្ពុជា និង(២) ប្រកាសស្តីពីក្រមសីលធម៌សម្រាប់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ។

ទន្ទឹមនេះ ការងារបណ្តុះបណ្តាលក៏បានបន្តធ្វើជាប្រចាំ ដើម្បីបំពាក់បំប៉នសមត្ថភាពតាមរយៈការបណ្តុះបណ្តាលជាទ្រឹស្តី ការចុះហាត់ការងារ និងការបញ្ជូនទៅបណ្តុះបណ្តាលនៅក្រៅប្រទេស ។

សម្រាប់ការងារសវនកម្ម នាយកដ្ឋានដែលទទួលការធ្វើសវនកម្មមុនគេនៅឆ្នាំ២០០៦ ដើម្បីសាកល្បង និងហ្វឹកហាត់ការងារមន្ត្រីសវនករ គឺនាយកដ្ឋានប្រតិបត្តិការ (ការិយាល័យគ្រប់គ្រងគណនី) នាយកដ្ឋានបោះផ្សាយ និងឃ្លាំងបេឡា (ការិយាល័យបេឡា និងការិយាល័យគណនេយ្យជំនួយ) និងការចុះបញ្ជីនៅនាយកដ្ឋានគណនេយ្យ ព្រមទាំងសាខាធនាគារជាតិនៃកម្ពុជាខេត្តសៀមរាប ខេត្តបាត់ដំបង ក្រុងព្រះសីហនុ ខេត្តស្ទឹងត្រែង និងខេត្តកំពត នៅឆ្នាំ២០០៧ នេះ ។ បន្ទាប់ពីការធ្វើសវនកម្ម របាយការណ៍រួមជាមួយអនុសាសន៍មួយចំនួនត្រូវបានដាក់ចេញ ដើម្បីធ្វើការកែលំអ ។

ក្រោយពីបានចុះធ្វើសវនកម្មសាកល្បងនៅនាយកដ្ឋាន និងសាខាធនាគារជាតិនៃកម្ពុជាខាងលើរួចមក សៀវភៅនីតិវិធីសវនកម្មសម្រាប់នាយកដ្ឋានទាំងពីរ និងសាខាធនាគារជាតិនៃកម្ពុជា ត្រូវបានរៀបចំនិងកែសម្រួលជាបន្តបន្ទាប់ ដើម្បីធ្វើឱ្យនីតិវិធីទាំងនេះអាចតម្រូវតាមស្ថានភាពបច្ចុប្បន្ន និងឱ្យកាន់តែប្រសើរឡើងនូវប្រតិបត្តិការរបស់នាយកដ្ឋាន និងអង្គភាពទាំងនោះ ។ បន្ទាប់មក សៀវភៅនីតិវិធីប្រតិបត្តិការសម្រាប់នាយកដ្ឋានគ្រប់គ្រងការ

ប្តូរប្រាក់ និងនាយកដ្ឋានអង្គភាពផ្សេងៗទៀត នឹងត្រូវរៀបចំជាបន្តបន្ទាប់ ដើម្បីឈានទៅដល់ការមាននូវក្រឹត្យក្រម ច្បាស់លាស់សម្រាប់ធ្វើសវនកម្ម ។

ចំពោះការងារអធិការកិច្ចវិញ ក៏ត្រូវបានដំណើរការយ៉ាងមមាញឹកតាមរយៈការចុះឆ្នក់ត្រួតពិនិត្យដោយមិនជូនដំណឹងមុនចំនួន ១៤ លើក លើសាខាធនាគារជាតិនៃកម្ពុជាចំនួន ១៩ ដែលសាខាខ្លះបានពីរលើក សាខាខ្លះបានមួយលើក ហើយការត្រួតពិនិត្យបានផ្តោតជាសំខាន់លើការងារធានាសុវត្ថិភាពឃ្លាំង និងការងារគ្រប់គ្រងសាច់ប្រាក់ ។ ឯការងារជំនាញនានាក៏ត្រូវបានត្រួតពិនិត្យនិងកែលំអ ដើម្បីពង្រឹងគុណវុឌ្ឍិមន្ត្រីបុគ្គលិកនៅតាមសាខាឱ្យកាន់តែប្រសើរឡើង ។ ទន្ទឹមនឹងនោះដែរ អគ្គាធិការដ្ឋាននិងបណ្តានាយកដ្ឋានជំនាញ បានសហការធ្វើការកែសម្រួល និងដាក់ចេញសេចក្តីណែនាំថ្មីបន្ថែមចំនួន ៣ ដែលសង្កត់ធ្ងន់លើការកាន់កាប់ គ្រប់គ្រង ប្រើប្រាស់ និងថែរក្សាកូនសោឃ្លាំង និងការចុះកិច្ចបញ្ជិកាដែលពាក់ព័ន្ធនឹងការងារសាច់ប្រាក់ឱ្យបានសមស្រប មានតម្លាភាព តាមស្ថានភាពជាក់ស្តែងបច្ចុប្បន្ន ដើម្បីឱ្យសាខាទាំងអស់អនុវត្តឱ្យបានឯកភាពគ្នា ។

## ៤. ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា

នៅក្នុងឆ្នាំ២០០៧ ការងារសំខាន់ៗលើវិស័យនេះត្រូវបានបង្ហាញឱ្យឃើញតាមរយៈការយកចិត្តទុកដាក់របស់ធនាគារជាតិនៃកម្ពុជា ក្នុងការពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ និងគុណភាពសេវារបស់ធនាគារកណ្តាលនៅតាមតំបន់ ជូនអង្គភាពរដ្ឋបាលសាធារណៈ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីរួមចំណែកទ្រទ្រង់កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដោយបានធ្វើការជ្រើសរើស ការបណ្តុះបណ្តាល និងការផ្គត់ផ្គង់ធនធានមនុស្សជាបន្តបន្ទាប់ ។ ការចេញបទបញ្ជាណែនាំពីអភិបាលកិច្ចល្អលើគ្រប់មុខជំនាញ ការចាត់តាំងធ្វើអធិការកិច្ចទៀងទាត់ និងសវនកម្មដកពិសោធន៍ដល់សាខាមួយចំនួនត្រូវបានអនុវត្តដើម្បីធានាតម្លាភាព និងភាពត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ។ ទន្ទឹមនេះ ក៏មានការណែនាំឱ្យសាខាធនាគារជាតិនៃកម្ពុជាខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប ក្រុងព្រះសីហនុ និងស្វាយរៀង បើកគណនីជូនមន្ទីរប្រៃសណីយ៍ខេត្ត-ក្រុងទាំងនេះជាជំហានដំបូងរួចហើយ ដើម្បីត្រៀមសហប្រតិបត្តិការផ្តល់សេវាកម្មប្រាក់បញ្ញើអាណត្តិប្រៃសណីយ៍អន្តរជាតិ ។

## ៥. ការងារគណនេយ្យធនាគារជាតិនៃកម្ពុជា

ក្នុងឆ្នាំ២០០៧ នេះ ទ្រព្យសកម្មធនាគារជាតិនៃកម្ពុជាបានកើនឡើងជាង ៣.០០៨ពាន់លានរៀល គឺ ១៦,៣៤% ក្នុងនោះកំណើនដែលគួរឱ្យកត់សម្គាល់ គឺបរិមាណសាច់ប្រាក់ជារៀលនិងជារូបិយប័ណ្ណ ដែលមានកំណើនសរុប ១៦០ពាន់លានរៀល (៥១,៧២%) ហើយប្រាក់បញ្ញើជារូបិយប័ណ្ណនៅស្ថាប័នហិរញ្ញវត្ថុ និងធនាគារបរទេសមានកំណើនសរុប ១.៩៦៧ពាន់លានរៀល ពោលគឺកើន ៦៥,៣០% ក៏ប៉ុន្តែការវិនិយោគលើមូលប័ត្របានថយចុះ ២៦៧ពាន់លានរៀល ពោលគឺថយចុះ ១៦,៦៤% ។ ចំណែកផ្នែកទ្រព្យអកម្មវិញ រូបិយវត្ថុបានបោះផ្សាយមានកំណើន ២៩០ពាន់លានរៀល ពោលគឺកើន ១៩,៧៩% ហើយប្រាក់បញ្ញើរបស់រដ្ឋាភិបាលមានកំណើន ៦៥៧ពាន់លានរៀល គឺស្មើនឹង ៦០,៣៣% ។ ចំណែកប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជមានការកើនឡើងចំនួន ៨៥៣ពាន់លានរៀល គឺស្មើនឹង ៤៦,១៨% ។

# តារាងតុល្យការធនាគារជាតិនៃកម្ពុជា

ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០០៧

## ទ្រព្យសកម្ម

( ឯកតាលានរៀល)

| អត្ថាធិប្បាយ | ចំនួនទឹកប្រាក់<br>ថ្ងៃ ៣១ ខែធ្នូ ឆ្នាំ២០០៦ | ចំនួនទឹកប្រាក់<br>ថ្ងៃ ៣១ ខែតុលា ឆ្នាំ២០០៧ |
|---|---|---|
| សាច់ប្រាក់ជារៀល និងជារូបិយប័ណ្ណ | ៣០៩.៦២៨ | ៤៦៩.៧៦២ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ នៅធនាគារបរទេស | ៣.០១១.៦៩១ | ៤.៩៧៨.៣៨៩ |
| ប្រាក់ SDR នៅមូលនិធិរូបិយវត្ថុអន្តរជាតិ | ៧៦៣ | ១.៨៧៣ |
| ប្រាក់រៀលបង់ចូលជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិ | ៥២៧.២២៩ | ៥៩២.២៦៦ |
| វិនិយោគលើមូលប័ត្របរទេស | ១.៦០៤.០៩៥ | ១.៣៣៧.១៦០ |
| លោហធាតុមានតម្លៃ ផ្ញើនៅបរទេស | ១.០៣១.៩៥១ | ១.២៧៥.៦០៤ |
| ឱ្យខ្ចី និងបុរេប្រទាន | | |
| - ចំពោះធនាគារពាណិជ្ជ | ៤៣.៥២០ | ៦៥.៨០០ |
| - ចំពោះរដ្ឋាភិបាល | ២៧០.២៥៣ | ២៩៦.៤៦៦ |
| អចលនទ្រព្យ | ៤១០.៧៩១ | ៤៨៩.៧២៩ |
| ផ្សេង ៗ | ១.៩៩២.៣៩៤ | ២.៧៩២.៧៩៦ |
| **សរុប** | **៩.២០២.៣១៥** | **១២.២០៩.៤៤៤** |

## ទ្រព្យអកម្ម

( ឯកតាលានរៀល)

| អត្ថាធិប្បាយ | ចំនួនទឹកប្រាក់ | ចំនួនទឹកប្រាក់ |
|---|---|---|
| រូបិយវត្ថុបោះផ្សាយ | ១.៨៣៧.៣១១ | ២.១២៧.៤២៥ |
| ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ | ១.៨៤៧.១៨៩ | ២.៧០០.២២១ |
| បំណុលចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ | ៦២៨.៧២៤ | ៦៥២.៩០០ |
| ប្រាក់បញ្ញើរបស់រដ្ឋាភិបាល | ១.០៨៩.៥៤៨ | ១.៧៤៦.៩១៥ |
| ដើមទុន | ១០០.០០០ | ១០០.០០០ |
| ទុនបម្រុង | ១.៤០៩.៩៥៩ | ១.៦៨៦.៨៣៤ |
| វិលេសបង្គរទុក | ៧៨.០២៩ | ៥២.២៩០ |
| សវិធានធន | ១៤៥.៨៨៨ | ១៩៩.៣២៥ |
| ផ្សេង ៗ | ២.០៦៥.៦៦៧ | ២.៩០៣.៩៣៣ |
| **សរុប** | **៩.២០២.៣១៥** | **១២.២០៩.៤៤៤** |

## III. ទំនាក់ទំនងអន្តរជាតិ

### ១. ទំនាក់ទំនងពហុភាគី

#### ១.១. ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ

នៅក្នុងឆ្នាំ២០០៧នេះ បេសកកម្មពិគ្រោះយោបល់នៃមាត្រា IV របស់មូលនិធិរូបិយវត្ថុអន្តរជាតិបានធ្វើឡើងចំនួនបីលើក : លើកទី១ ពីថ្ងៃទី១៤ ដល់ថ្ងៃទី២១ ខែកុម្ភៈ លើកទី២ ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៥ ខែមិថុនា និងលើកទី៣ ពីថ្ងៃទី១២ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ ។ ជារួម បេសកកម្មទាំងនេះបានវាយតម្លៃខ្ពស់ចំពោះដំណើរការសេដ្ឋកិច្ចរបស់កម្ពុជានាពេលកន្លងមក ព្រមទាំងបានបញ្ជាក់ថា ការធ្វើកំណែទម្រង់បច្ចុប្បន្នរបស់រាជរដ្ឋាភិបាលកម្ពុជា រួមនិងកំណែទម្រង់ក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុផងដែរ កំពុងស្ថិតនៅលើគន្លងមួយដ៏ត្រឹមត្រូវ ហើយដូចនេះ មូលនិធិរូបិយវត្ថុអន្តរជាតិមានសេចក្តីសោមនស្ស និងសន្យាផ្តល់ការជួយទ្រទ្រង់ថែមទៀតតាមរយៈជំនួយបច្ចេកទេសនានា ទោះបីជាកម្មវិធីមួយថ្មីនៃ " ឥណទានកាត់បន្ថយភាពក្រីក្រនិងបង្កើនកំណើនសេដ្ឋកិច្ច " មិនទាន់អាចអនុម័តបានក្តី ។

ក្នុងឆ្នាំនេះ គណៈប្រតិភូជាន់ខ្ពស់នៃធនាគារជាតិនៃកម្ពុជាក៏បានចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំនៃមូលនិធិរូបិយ-វត្ថុអន្តរជាតិ/ធនាគារពិភពលោកដែរ ។ កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងជាចម្បង ផ្តល់នូវវេទិកាដើម្បីពិភាក្សាអំពីសភាពការណ៍បច្ចុប្បន្ននៃសេដ្ឋកិច្ចពិភពលោក និងស្ថានភាពក្នុងវិស័យហិរញ្ញវត្ថុ ក្នុងស្មារតីធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាដើម្បីពិភាក្សាអំពីសកម្មភាពនានារបស់មូលនិធិរូបិយវត្ថុអន្តរជាតិ/ធនាគារពិភពលោក សំដៅជួយទ្រទ្រង់ការអភិវឌ្ឍនៃប្រទេសជាសមាជិក ។ ក្នុងនោះក៏មានការពិភាក្សាផងដែរលើបញ្ហាដូចជា ការធ្វើកំណែទម្រង់កូតានិងសម្លេងឆ្នោត សហប្រតិបត្តិការវាងគ្រឹះស្ថានប្រ៊ីទិនវូតទាំងពីរ ព្រមទាំងអំពីទិសដៅនិងអាទិភាពនៃការកាត់បន្ថយភាពក្រីក្រ ។ល។

ចំពោះបញ្ហាជំនួយបច្ចេកទេសវិញ នៅក្នុងអំឡុងឆ្នាំ២០០៧នេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានទ្រទ្រង់ដល់ធនាគារជាតិនៃកម្ពុជាលើផ្នែកដូចតទៅ : ការពង្រឹងសវនកម្មផ្ទៃក្នុង ការត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជ ការលើកកម្ពស់គុណភាពស្ថិតិជញ្ជីងទូទាត់ដោយពង្រីកប្រភពទិន្នន័យ តាមរយៈការធ្វើអង្កេតលើទិន្នន័យវិនិយោគផ្ទាល់បរទេសនៅកម្ពុជា ទិន្នន័យចំណាយរបស់ទេសចរណ៍បរទេសនៅកម្ពុជា និងចំណាយរបស់ប្រជាជនកម្ពុជានៅបរទេសជាដើម ។ ទន្ទឹមនោះដែរ មូលនិធិរូបិយវត្ថុអន្តរជាតិបាន សហការជាមួយធនាគារជាតិនៃកម្ពុជារៀបចំវគ្គសិក្សាថ្នាក់ជាតិចំនួនពីរលើកអំពី "ការរៀបចំកម្មវិធីគោលនយោបាយហិរញ្ញវត្ថុ" និងអំពី "តារាងរបាយការណ៍ស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុគំរូថ្មី សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ " ។

ចំពោះប្រតិបត្តិការហិរញ្ញវត្ថុវិញ បច្ចុប្បន្នមានការទទួល និងសងការប្រាក់ ព្រមទាំងកម្រៃមួយចំនួន ចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ ដូចតទៅ ÷

- ការទទួលការប្រាក់ពីការរក្សា "សិទ្ធិដកពិសេស " (SDRs Holdings) ជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ មានចំនួន ១៥៣.៤៩៥ SDRs ស្មើនឹង ២៣៥.២៤៨ ដុល្លារអាមេរិក ។
- ការសងកម្រៃពាក់ព័ន្ធនឹងការបែងចែក "សិទ្ធិដកពិសេស " (SDRs allocations) មានចំនួន ៤៨២,៩៧២ SDRs ស្មើនឹង ៧៣៣.០២៣ ដុល្លារអាមេរិក ។

## ១.២. ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី

កម្មវិធីឥណទានរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់អនុវត្តកំណែទម្រង់ក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុបានឈានចូលដល់ដំណាក់កាលមួយថ្មីក្នុងឆ្នាំ ២០០៧ នេះ បន្ទាប់ពីធនាគារជាតិនៃកម្ពុជា និង ស្ថាប័នពាក់ព័ន្ធបានបញ្ចប់ការអនុវត្តកម្មវិធីឥណទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុលើកទី១ អនុកម្មវិធីទី៣ រួចមក ។ **"ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០"** ត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជា **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥"** ហើយត្រូវបានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧ ។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយស្ថាប័នពាក់ព័ន្ធ មានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម សម្រេចការចរចាដោយជោគជ័យ ជាមួយធនាគារអភិវឌ្ឍន៍អាស៊ីលើកម្មវិធីឥណទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុលើកទី២ ដែលកិច្ចព្រមព្រៀងឥណទាននោះត្រូវបានចុះហត្ថលេខាជាផ្លូវការរួចហើយ ។ កម្មវិធីឥណទានលើកទីពីរនេះ មានទឹកប្រាក់ចំនួន ៤០លានដុល្លារអាមេរិក និងត្រូវបែងចែកជា ៤ អនុកម្មវិធី ។ ឥណទាននៃអនុកម្មវិធីទី១ ក្រសោបទឹកប្រាក់ចំនួន ១០លានដុល្លារអាមេរិក ដែលក្នុងនោះទឹកប្រាក់ចំនួន ៣លានដុល្លារអាមេរិក ត្រូវបានគ្រោងថា នឹងប្រើប្រាស់សម្រាប់អភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យារបស់ធនាគារជាតិនៃកម្ពុជា ។

កំណែទម្រង់នៅក្នុងអនុកម្មវិធីទីមួយនេះ មានគោលដៅបន្តពង្រឹងមូលដ្ឋានគ្រឹះនៃក្របខ័ណ្ឌច្បាប់ និងស្ថាប័ន ដែលក្នុងនោះបានក្រសោបនូវកិច្ចការសំខាន់ៗមួយចំនួនដូចតទៅ :

- ការរៀបចំអនុស្សរណៈនៃការយោគយល់គ្នារវាងធនាគារជាតិនៃកម្ពុជានិងធនាគារពាណិជ្ជដើម្បីអនុម័តលើផែនទីវិថីសម្រាប់ធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់
- ការពង្រឹងការគោរពតាមលក្ខខណ្ឌនានានៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន
- ការបង្កើនសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការតាមដានទិន្នន័យម៉ាក្រូសេដ្ឋកិច្ច ដើម្បីវាយតម្លៃការអនុវត្តនៃវិស័យហិរញ្ញវត្ថុ
- ការកែលំអបទប្បញ្ញត្តិស្តីពីឥណទានធំៗរបស់ធនាគារពាណិជ្ជ
- ការអនុម័តប្រកាសថ្មីធ្វើវិសោធនកម្មលើការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ និងធនាគារឯកទេស
- ការកំណត់អាទិភាពនិងតម្រូវការកសាងសមត្ថភាពសម្រាប់ការងារត្រួតពិនិត្យធនាគារ
- ការពង្រឹងការតាមដាន និងការអនុវត្តវិធានការកែតម្រូវបន្ទាន់ ចំពោះគ្រឹះស្ថានធនាគារដែលមានការខ្វះខាតក្នុងការអនុវត្តច្បាប់និងបទប្បញ្ញត្តិប្រុងប្រយ័ត្ននានា

- ការដាក់ជូនសភាជាតិអនុម័តនូវសេចក្តីព្រាងច្បាប់ស្តីពីការចេញផ្សាយនិងការជួញដូរមូលប័ត្រមហាជនជាដើម ។

## ១.៣. ទំនាក់ទំនងជាមួយអាស៊ាន

ក្នុងសមត្ថកិច្ចជាអាជ្ញាធររូបិយវត្ថុរបស់ប្រទេស ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តការចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន និងអាស៊ាន+៣ (ចិន កូរ៉េ ជប៉ុន) ។ ក្នុងឆ្នាំ២០០៧នេះ ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងកិច្ចប្រជុំសំខាន់ៗបីគឺ កិច្ចប្រជុំថ្នាក់ទេសាភិបាលនៃធនាគារកណ្តាលអាស៊ានទាំង ១០ មួយលើក និងកិច្ចប្រជុំថ្នាក់ទេសាភិបាលរងនៃធនាគារកណ្តាលនិងអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន+៣ ចំនួនពីរលើក ។ ក្នុងឆ្នាំនេះ សហប្រតិបត្តិការក្នុងអាស៊ាន ១០ បានផ្តោតជាពិសេសលើការរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC Blueprint) ដែលមានទិសដៅប្រែក្លាយអាស៊ានឱ្យទៅជាតំបន់ដែលទំនិញ សេវា វិនិយោគ ពលកម្ម និងដើមទុន មានចលនាដោយសេរីនៅឆ្នាំ២០១៥ ។ ផែនការយុទ្ធសាស្ត្រនេះត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលនៃប្រមុខអាស៊ានលើកទី១៣ ដែលបានប្រព្រឹត្តទៅនៅប្រទេសសិង្ហបុរី នាខែវិច្ឆិកាកន្លងមក ។ ខ្លឹមសារដែលពាក់ព័ន្ធនឹងសហប្រតិបត្តិការវិស័យហិរញ្ញវត្ថុរួមមាន : ការអភិវឌ្ឍ និងសមាហរណកម្មទីផ្សារទុន ការធ្វើសេរីភាវូបនីយកម្មគណនីដើមទុន និងការធ្វើសេរីភាវូបនីយកម្មសេវាកម្មហិរញ្ញវត្ថុ ។ ទន្ទឹមនោះ ធនាគារកណ្តាល និងក្រសួងហិរញ្ញវត្ថុនៃអាស៊ានទាំង ១០ ក៏បានឯកភាពផ្តួចផ្តើមធ្វើការសិក្សារកយន្តការធ្វើហិរញ្ញប្បទានចំពោះហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅក្នុងប្រទេសសមាជិកផងដែរ ។

ដោយឡែក ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអាស៊ាន+៣ ការយកចិត្តទុកដាក់ត្រូវបានផ្តោតជាបឋមលើការជំរុញពហុកម្មអ្នកចូលរួមនៃគំនិតផ្តួចផ្តើមនៅឈៀងម៉ៃ (Multilateralization of Chiangmai Initiatives) ដែលនឹងផ្តល់លទ្ធភាពឱ្យមានឥណទានសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចពេលមានវិបត្តិហិរញ្ញវត្ថុ ក្រោមរូបភាពជាស្វប់ពហុភាគីក្នុងចំណោមអាស៊ាន+៣ ។ លើសពីនេះ មុខព្រួញការងារសំខាន់មួយទៀតនៃប្រទេសអាស៊ាន+៣ គឺការអនុវត្តគំនិតផ្តួចផ្តើមទីផ្សារសញ្ញាប័ណ្ណអាស៊ាន ដែលនឹងជួយជំរុញការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុនៅក្នុងប្រទេសអាស៊ានថ្មីៗ ខណៈបង្កើនសង្គតភាពរវាងទីផ្សារហិរញ្ញវត្ថុនៅក្នុងប្រទេសអាស៊ាន+៣ ឯទៀតដែលមានការអភិវឌ្ឍកម្រិតខ្ពស់មួយហើយ ។

## ១.៤. ទំនាក់ទំនងជាមួយ SEACEN

សមាជិកភាពរបស់ធនាគារជាតិនៃកម្ពុជានៅក្នុង SEACEN (South-East Asian Central Banks) ដែលត្រូវបានប្រកាសជាផ្លូវការនាខែមេសា ឆ្នាំ២០០៦ កន្លងទៅ បានផ្តល់ឱកាសជាច្រើនចំពោះធនាគារជាតិនៃកម្ពុជាក្នុងការបណ្តុះបណ្តាលធនធានមនុស្ស និងការចែករំលែកបទពិសោធន៍ទៅវិញទៅមករវាងបណ្តាធនាគារកណ្តាលទាំងឡាយជាសមាជិក ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនិងជំនឿទុកចិត្តលើប្រតិបត្តិការនៃធនាគារកណ្តាល ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ និងការពង្រឹងវិស័យធនាគារ ។

ក្នុងរយៈពេលប្រហាក់ប្រហែលគ្នានេះដែរ ចំនួនសមាជិករបស់ SEACEN ត្រូវបានពង្រីកបន្ថែមជាមួយនឹងការចូលរួមរបស់ធនាគារកណ្តាលវៀតណាម រីឯសហប្រតិបត្តិការក្នុង SEACEN ក៏មានដំណើរការយ៉ាងសកម្មផងដែរ ក្រោមរូបភាពជាកិច្ចប្រជុំគោលនយោបាយនិងបច្ចេកទេស វគ្គសិក្សានិងសិក្ខាសាលាផ្សេងៗ ។ ក្នុងនោះ កិច្ចប្រជុំសំខាន់ៗរួមមាន :

- សន្និសីទថ្នាក់ទេសាភិបាលនៃធនាគារកណ្តាល SEACEN ដែលមានភ្ជាប់នឹងការពិភាក្សាលើប្រធានបទ "**ការគ្រប់គ្រងអត្រាប្តូរប្រាក់ និងលំហូរដើមទុន**"
- កិច្ចប្រជុំលើកទី ៥ របស់គណៈកម្មការប្រតិបត្តិ ដែលពិភាក្សាលើកម្មវិធីសកម្មភាពរបស់មជ្ឈមណ្ឌល SEACEN សម្រាប់ឆ្នាំប្រតិបត្តិការ ២០០៦-២០០៧ កម្មវិធីបណ្តុះបណ្តាលដែលស្នើឡើងសម្រាប់ឆ្នាំប្រតិបត្តិការ ២០០៧-២០០៨ គម្រោងថវិកាឆ្នាំ២០០៧-២០០៨ និងបញ្ហាមួយចំនួនទៀតទាក់ទងនឹងកម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌល
- កិច្ចប្រជុំលើកទី២៩ នៃនាយកផ្នែកស្រាវជ្រាវនិងផ្នែកបណ្តុះបណ្តាល អំពីការងារស្រាវជ្រាវនិងបញ្ហាប្រឈមក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ។ ចំពោះការងារនេះ កន្លងមក ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងការសិក្សាអំពី "**ឥទ្ធិពលនៃការឡើងថ្លៃប្រេងមកលើសេដ្ឋកិច្ចនៃបណ្តាប្រទេស SEACEN និងផលប៉ះពាល់នយោបាយ**" និងអំពី "**បញ្ហាប្រឈមនៃការតាមដានស្ថានភាពសេដ្ឋកិច្ច**" ។
- កិច្ចប្រជុំស្តីពីប្រព័ន្ធទូទាត់ វឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធទូទាត់ និងការការពារហានិភ័យ ។

ម៉្យាងទៀត ក្នុងឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយ SEACEN រៀបចំសិក្ខាសាលាចំនួនពីរនៅខេត្តសៀមរាប : ទីមួយអំពី "**ប្រព័ន្ធទូទាត់ និងផាត់ទាត់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍**" និងទីពីរអំពី "**ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ**" ដោយមានការចូលរួមយ៉ាងកុះករពីសំណាក់សិក្ខាកាមមកពីធនាគារកណ្តាលនៃប្រទេសសមាជិកទាំង ១៦ ។

ក្រៅពីនេះ ក៏មានសហប្រតិបត្តិការផ្សេងៗទៀត រួមមាន ការដោះដូរព័ត៌មានសេដ្ឋកិច្ចនានា ដែលនៅក្នុងបរិបទនេះ ធនាគារជាតិនៃកម្ពុជាតែងផ្ញើរបាយការណ៍ស្តីពីការវិវត្តម៉ាក្រូសេដ្ឋកិច្ច កំណែទម្រង់វិស័យធនាគារ និងហិរញ្ញវត្ថុ និងអំពីសកម្មភាពរបស់ធនាគារជាតិនៃកម្ពុជាជារៀងរាល់ត្រីមាស ដល់មជ្ឈមណ្ឌល SEACEN សម្រាប់ធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

## ១.៥. ទំនាក់ទំនងជាមួយក្រុមអាស៊ីប៉ាស៊ីហ្វិក (APG) ដើម្បីប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

កម្ពុជាបានចូលជាសមាជិកក្រុមអាស៊ីប៉ាស៊ីហ្វិកនៅឆ្នាំ២០០៥ ដោយធនាគារជាតិនៃកម្ពុជាបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងឋានៈជាអ្នកទំនាក់ទំនងចម្បង (Primering contact point) រវាង APG ជាមួយ

ក្រសួង និងអង្គភាពពាក់ព័ន្ធនានានៅកម្ពុជា ជាពិសេសក្នុងការទទួលជំនួយបច្ចេកទេសពី APG លើការងារបណ្តុះបណ្តាល និងការត្រៀមខ្លួនសម្រាប់បង្កើតក្រុមស៊ើបការណ៍ហិរញ្ញវត្ថុ ។ នៅខែមីនា ឆ្នាំ២០០៧ ធនាគារពិភពលោក និង APG បានមកធ្វើការវាយតម្លៃអញ្ញមញ្ញ (Mutual Evaluation) ចំពោះប្រទេសកម្ពុជា ។ តាមរយៈសកម្មភាពនេះ យើងបានដឹងចំណុចខ្វះខាតផ្សេងៗដែលនឹងត្រូវជំនះជាបណ្តើរៗ ដើម្បីឆ្លើយតបចំពោះអនុសាសន៍ទាំង ៤០ និងអនុសាសន៍ពិសេស ៩ របស់ FATF ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

ក្នុងឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជាបានទទួលជំនួយបច្ចេកទេសសំខាន់ៗពី UNODC និងធនាគារពិភពលោក តាមរយៈការបណ្តុះបណ្តាល ការរៀបចំឯកសារស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឹក្សាផ្សេងពីបញ្ហាការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មទាំងក្នុងស្រុក និងក្រៅស្រុក ។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយមជ្ឈមណ្ឌលវិភាគនិងរាយការណ៍ប្រតិបត្តិការនៃប្រទេសអូស្ត្រាលី (AUSTRAC) រៀបចំធ្វើសិក្ខាសាលាជាច្រើន រួមមាន កាតព្វកិច្ចប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មសម្រាប់ផ្នែកកាស៊ីណូ អចលនទ្រព្យ អង្គការមិនស្វែងរកប្រាក់ចំណេញ និងសិក្ខាសាលាមួយស្តីពីប្រតិបត្តិការសង្ស័យសម្រាប់ប្រព័ន្ធធនាគារ ។ បន្ថែមលើនេះទៀត ដោយមានកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលនៃប្រទេសបារាំង សិក្ខាសាលាមួយស្តីពីការប្រឆាំងការសំអាតប្រាក់ត្រូវបានរៀបចំឡើងសម្រាប់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ធនាគារពាណិជ្ជ និងធនាគារឯកទេសទាំងអស់ ។

ដោយឡែកនៅកម្ពុជា ច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានប្រកាសឱ្យប្រើប្រាស់កាលពីថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលច្បាប់នេះកំណត់ពីកាតព្វកិច្ចប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងតម្រូវឱ្យមានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។

ទាក់ទិននឹងច្បាប់នេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយ UNODC និងធនាគារពិភពលោក ដើម្បីពិនិត្យសេចក្តីព្រាងប្រកាសស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងបានរៀបចំផែនការសម្រាប់បង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ដោយកំពុងរៀបចំបង្កើតក្រុមប្រឹក្សាភិបាលមួយ ដែលមានតួនាទីផ្តល់ការណែនាំដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនេះ ។

## ១.៦. ទំនាក់ទំនងជាមួយសមាគមឥណទានកសិកម្ម និងឥណទានជនបទអាស៊ីប៉ាស៊ីហ្វិក (APRACA)

ធនាគារជាតិនៃកម្ពុជាបានចូលជាសមាជិកសមាគមឥណទានកសិកម្ម និងឥណទានជនបទអាស៊ីប៉ាស៊ីហ្វិក (APRACA) នៅឆ្នាំ២០០០ ក្នុងទិសដៅពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងផ្លាស់ប្តូរបទពិសោធន៍ បច្ចេកវិទ្យាទៅវិញទៅមក តាមរយៈការបណ្តុះបណ្តាលផ្នែកឥណទានកសិកម្មជនបទ និងការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ក្នុងនាមជាសមាជិក ធនាគារជាតិនៃកម្ពុជាបានចូលរួមសកម្មភាពបណ្តុះបណ្តាលនានា ដែលរៀបចំដោយ APRACA ដើម្បីរួមចំណែកបង្កើនសមត្ថភាពត្រួតពិនិត្យរបស់អ្នកត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

## ២. ទំនាក់ទំនងទ្វេភាគី

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងទំនាក់ទំនងទ្វេភាគីជាមួយបណ្តាប្រទេសជាមិត្ត ទាំងនៅក្នុងតំបន់អាស៊ី ក៏ដូចជានៅអឺរ៉ុប លើគោលការណ៍នៃសហប្រតិបត្តិការជំនាញ ដូចជា ការសិក្សាអង្កេតរួមគ្នា ការផ្លាស់ប្តូរព័ត៌មាន និងការបណ្តុះបណ្តាលមន្ត្រីជាដើម ។

ឆ្នាំនេះ សហប្រតិបត្តិការទ្វេភាគីត្រូវបានពង្រីកថែមទៀតជាមួយនឹងធនាគារកណ្តាលកូរ៉េ តាមរយៈការចុះហត្ថលេខាលើអនុស្សរណៈស្តីពីការយោគយល់គ្នា អំពី "កិច្ចសហប្រតិបត្តិការ និងជំនួយបច្ចេកទេសរវាងធនាគារកណ្តាលកូរ៉េ និងធនាគារជាតិនៃកម្ពុជា" កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧ ដែលបានរៀបចំឡើងនៅខេត្តសៀមរាប ។

នៅក្នុងឆ្នាំ២០០៧នេះ ធនាគារជាតិនៃកម្ពុជាបានធ្វើការសិក្សាអង្កេតរួមគ្នាជាមួយធនាគារកណ្តាលថៃ លើប្រធានបទស្តីពី "ការធ្វើពាណិជ្ជកម្មឆ្លងដែន ការវិនិយោគ និងផ្លូវដឹកជញ្ជូនទំនិញនៅកម្ពុជា" ។ ការសិក្សានេះបានធ្វើឡើងនៅតាមបណ្តាខេត្ត និងតំបន់សេដ្ឋកិច្ចពិសេសមួយចំនួនក្នុងប្រទេសកម្ពុជា ។ ដោយឡែក មន្ត្រីធនាគារជាតិនៃកម្ពុជាក៏បានធ្វើទស្សនកិច្ចសិក្សានៅធនាគារកណ្តាលថៃ សាខាខេត្ត Khorkean វិញដែរ ដើម្បីស្វែងយល់ពីសកម្មភាពការងារប្រតិបត្តិការរបស់ធនាគារកណ្តាលថៃ សាខាខេត្ត Khorkean និតិវិធីរបស់ទីស្នាក់ការកណ្តាលក្នុងការត្រួតពិនិត្យសកម្មភាពរបស់សាខា និងអំពីសកម្មភាពរបស់សភាផាត់ទាត់តាមសាខា ជាដើម ។

លើសពីនេះ កិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលវៀតណាម ចិន និងឡាវ ក៏ត្រូវបានពង្រឹងថែមទៀត តាមរយៈទស្សនកិច្ចរបស់ទេសាភិបាលធនាគារកណ្តាលវៀតណាម ទេសាភិបាលរងធនាគារកណ្តាលចិន និងទេសាភិបាលរងធនាគារកណ្តាលឡាវ ។

## សន្និដ្ឋាន

សេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនក្នុងល្បឿនដ៏លឿនមួយគួរជាទីមោទនៈ ដែលត្រូវបានជំរុញជាពិសេស ដោយការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តកំណែទម្រង់ ការចូលរួមចំណែកពីវិស័យឯកជន និងការគាំទ្រយ៉ាងម៉ឺងម៉ាត់ពីសហគមន៍អន្តរជាតិ ។ ទំនាក់ទំនងទៅវិញទៅមករវាងកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ កំណែទម្រង់រចនាសម្ព័ន្ធ និងអភិបាលកិច្ចល្អ មានលក្ខណៈរឹងមាំគួរឱ្យកត់សម្គាល់ ។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច រួមនឹងកំណើនសេដ្ឋកិច្ចដ៏ខ្ពស់ជាបន្តបន្ទាប់នារយៈពេលប៉ុន្មានឆ្នាំមកនេះ បាននិងកំពុងជួយជំរុញការកាត់បន្ថយភាពក្រីក្រ ទន្ទឹមគ្នានឹងការបង្កើនការធ្វើវិនិយោគសំខាន់ៗផ្សេងៗសម្រាប់វិស័យសង្គមកិច្ច ។ កំណែទម្រង់រចនាសម្ព័ន្ធនៅក្នុងវិស័យផ្សេងៗមួយចំនួន ដោយរាប់បញ្ចូលទាំងវិស័យធនាគារនិងហិរញ្ញវត្ថុផង ជាដំណើរការដែលកំពុងអនុវត្តជាបន្ត ក្នុងគោលបំណងពង្រឹងមូលដ្ឋានគ្រឹះនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងលុបបំបាត់ចោលនូវកត្តារាំងស្ទះនានា ចំពោះមីក្រូសេដ្ឋកិច្ចដែលមានឥទ្ធិពលទៅលើវិស័យសេដ្ឋកិច្ចសំខាន់ៗ ហើយដូចនេះ នឹងត្រួសត្រាយផ្លូវសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាព ។

ជាការឆ្លុះបញ្ចាំងជំហរនៃគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជានៅក្នុងឆ្នាំកន្លងទៅ អត្រាកំណើនសេដ្ឋកិច្ចនៅតែរក្សាបាននូវកម្រិតមួយខ្ពស់ អត្រាការប្រាក់ឱ្យខ្ចីមានការធ្លាក់ចុះជាបណ្តើរៗ អតិផរណាត្រូវបានរក្សាក្នុងកម្រិតដែលអាចគ្រប់គ្រងបាន រីឯប្រាក់រៀលនៅតែបន្តស្ថិរភាពយ៉ាងល្អធៀបទៅនឹងរូបិយប័ណ្ណនៃដៃគូពាណិជ្ជកម្មចម្បងៗរបស់កម្ពុជា ខណៈដែលទុនបម្រុងអន្តរជាតិរបស់ប្រទេសបានរីកចម្រើននៅក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ ។

ការអភិវឌ្ឍនិងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ គឺជាទិសដៅស្នូលមួយទៀតរបស់ធនាគារជាតិនៃកម្ពុជា ដែលត្រូវបានខិតខំសម្រេចតាមរយៈការប្រឹងប្រែងលើកកម្ពស់កត្តាគន្លឹះបីគឺ ក្របខ័ណ្ឌគតិយុត្ត សមត្ថភាពស្ថាប័ន និងធនធានមនុស្ស ។ នៅក្នុងបរិបទនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់ជាប្រចាំទៅលើការធ្វើឱ្យប្រសើរឡើងនូវបញ្ញត្តិកម្ម និងការត្រួតពិនិត្យគ្រឹះស្ថានហិរញ្ញវត្ថុ ព្រមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ដែលរួមមាន ការបង្កើតប្រព័ន្ធផាត់ទាត់និងទូទាត់ជាតិ ការគ្រប់គ្រងប្រព័ន្ធចែករំលែកព័តិមានឥណទាន និងការតាមដានយ៉ាងហ្មត់ចត់ទៅលើការវិវត្តនៃវិស័យហិរញ្ញវត្ថុទាំងមូល ។

ផ្អែកលើគោលនយោបាយបើកច្រកទូលាយយ៉ាងសមស្របចំពោះការធ្វើអាជីវកម្មធនាគារ ដែលទ្រទ្រង់ដោយប្រព័ន្ធបទប្បញ្ញត្តិប្រកបដោយតម្លាភាព ស្របនឹងគោលនយោបាយហិរញ្ញវត្ថុដ៏ត្រឹមត្រូវមួយ ការប្រកួតប្រជែងនៅក្នុងប្រព័ន្ធធនាគារក៏ត្រូវបានជំរុញ និងកំពុងលើកទឹកចិត្តបន្ថែមទៀត ។ ជាលទ្ធផល សេវារបស់ធនាគារពាណិជ្ជក៏កាន់តែមានភាពសម្បូរបែប ហើយអាចបំពេញតម្រូវការជាច្រើនសណ្ឋានរបស់អ្នកដាក់ប្រាក់បញ្ញើ និងអ្នកវិនិយោគផ្សេងៗបានប្រសើរជាងមុន ខណៈដែលគុណភាពនៃសេវារបស់គេក៏បានកើនឡើងមួយកម្រិតផងដែរ ។

ទោះបីជាមានការខិតខំ និងការទទួលបាននូវលទ្ធផលគួរឱ្យចាប់អារម្មណ៍ក្តី ក៏នៅមានការងារយ៉ាងមមាញឹកផ្សេងៗជាច្រើនទៀត នៅក្នុងរបៀបវារៈរបស់ធនាគារជាតិនៃកម្ពុជា សំដៅសម្រេចបាននូវទស្សនវិស័យ និងគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ។ ផែនការយុទ្ធសាស្ត្រនេះជាលទ្ធផលនៃបច្ចុប្បន្នកម្មចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ដែលត្រូវបានធ្វើឡើងដោយការគិតពិចារណាទៅលើលក្ខខណ្ឌប្រែប្រួលយ៉ាងឆាប់រហ័សនៅក្នុងទីផ្សារ បម្រែបម្រួលនៃតម្រូវការជាក់ស្តែង និងអាទិភាពនៃកំណែទម្រង់នៅក្នុងប្រទេសដែលតម្រូវឱ្យមានការកំណត់លំដាប់លំដោយកម្មវិធីកំណែទម្រង់ឱ្យកាន់តែប្រសើរឡើងថែមទៀត ។

ជារួម អ្វីដែលសម្រេចបាន និងបានឃើញយ៉ាងប្រត្យក្សរហូតមកទល់ពេលនេះ បានចង្អុលបង្ហាញនូវសក្តានុពលនៃការរីកចម្រើនដ៏ធំធេងនៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ។ បច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាកំពុងស្ថិតនៅក្នុងតំណាក់កាលយ៉ាងសំខាន់មួយគឺ ត្រូវស្វែងយល់ពីចំណុចខ្លាំងនៃទីផ្សារ និងចាប់យកឱកាសសម្រាប់អភិវឌ្ឍក្នុងខណៈប្រឈមមុខនឹងចំណុចខ្សោយ ព្រមទាំងឧបសគ្គនានាដែលរារាំងផ្លូវឆ្ពោះទៅរកការបង្កើត ប្រព័ន្ធហិរញ្ញវត្ថុមួយដ៏រឹងមាំ និងប្រកបដោយចីរភាព បញ្ចៀសបាននូវហានិភ័យនានាដែលអាចកើតមានឡើង ។ ជាការពិត ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនជាគោលដៅចុងក្រោយបំផុតឡើយ ។ ធាតុពិត គោលបំណងចុងក្រោយ គឺដើម្បីគាំទ្រការកៀរគរធនធាន ការអភិវឌ្ឍវិស័យឯកជន ការបង្កើតភាពមានការងារធ្វើ និងការវិនិយោគផ្ទាល់ពីបរទេសជាដើម ហើយដូចនេះ គឺទ្រទ្រង់កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ។

ដូចជាករណីកន្លងមកដែរ ធនាគារជាតិនៃកម្ពុជាមានការជឿជាក់ថា ការគាំទ្រជាបន្តបន្ទាប់ពីមជ្ឈដ្ឋានក្នុងស្រុកផ្សេងៗ និងពីសំណាក់សហគមន៍អន្តរជាតិនានា នឹងរួមចំណែកជួយសម្រេចបាននូវគោលដៅដ៏ប្រឈមទាំងនោះ ។

# ខ. ទិសដៅការងារឆ្នាំ២០០៨

## ទិសដៅការងារឆ្នាំ២០០៨

មូលដ្ឋាននៃសមិទ្ធផលកន្លងមក និងការខិតខំអនុវត្តកំណែទម្រង់គ្រប់ជ្រុងជ្រោយរបស់រាជរដ្ឋាភិបាល ជាពិសេសគោលនយោបាយជំរុញដំណើរការនៃវិស័យឯកជន ការយកចិត្តទុកដាក់លើការបង្កើនប្រសិទ្ធភាពវិស័យឧស្សាហកម្ម ព្រមទាំងលើការពង្រឹងវិស័យកសិកម្មនិងកសិឧស្សាហកម្មត្រូវបានរំពឹងថា នឹងជួយទ្រទ្រង់ចំពោះខឿនសេដ្ឋកិច្ចកម្ពុជាទប់ទល់នឹងផលប៉ះពាល់អវិជ្ជមាននានាពីក្រៅប្រទេសចំពោះសេដ្ឋកិច្ចកម្ពុជា ។ អាស្រ័យហេតុនេះ នៅឆ្នាំ២០០៨ សេដ្ឋកិច្ចគ្រោងថា នឹងបន្តមានសន្ទុះកំណើនមួយសមរម្យ ក្នុងកម្រិតប្រមាណ ៧,៧% ដែលនឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចអនុវត្តការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច និងគោលនយោបាយកាត់បន្ថយភាពក្រីក្រដោយរលូនជាបន្តទៀត ។ ដោយឡែក ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុនិងប្តូរប្រាក់ប្រកបដោយភាពប្រុងប្រយ័ត្ននិងទន់ភ្លន់ទៅតាមការវិវត្តជាក់ស្តែងនៃសេដ្ឋកិច្ច ព្រមទាំងបន្តយកចិត្តទុកដាក់រក្សាការស៊ីចង្វាក់គ្នាជាមួយនឹងគោលនយោបាយសារពើពន្ធ សំដៅរក្សាចីរភាពនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ នៅក្នុងបរិការណ៍នេះ អត្រាអតិផរណាប្រចាំឆ្នាំត្រូវបានរំពឹងថា នឹងអាចរក្សាក្នុងកម្រិតប្រមាណ ៦% ខណៈដែលអត្រាប្តូរប្រាក់នឹងមានស្ថិរភាពសមស្រប ដែលជាអំណោយផលដល់សកម្មភាពសេដ្ឋកិច្ច ។ ធនាគារជាតិនៃកម្ពុជានឹងបន្តផ្តោតលើកំណែទម្រង់ចាំបាច់ផ្សេងៗជាអាទិភាព ដូចមានចែងក្នុង "ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" ហើយផ្អែកលើយុទ្ធសាស្រ្តរយៈកាលវែងនេះ កំណត់ទិសដៅការងារសម្រាប់ឆ្នាំ២០០៨ លើផ្នែកសំខាន់ៗ ដូចខាងក្រោម :

### ១_ ការងាររូបិយវត្ថុ (បម្រែបម្រួលជាភាគរយប្រចាំឆ្នាំ)

| | |
|---|---|
| - រូបិយវត្ថុទូទៅ (M2) | ២៩% |
| - រូបិយវត្ថុក្នុងចរាចរណ៍ | ១៧% |
| - ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៣២% |
| - ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា | - ៨% |
| - ឥណទានសុទ្ធចំពោះរដ្ឋាភិបាលពីវិស័យធនាគារ | - ២% |
| - ទុនបម្រុងផ្លូវការសុទ្ធ | ២០% |

### ២_ ការងារប្តូរប្រាក់

- បន្តតាមដានការវិវត្តនៃអត្រាប្តូររូបិយប័ណ្ណ និងស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិ
- បន្តសិក្សាស្វែងយល់អំពីសេវារក្សាមូលប័ត្រ និងការឱ្យខ្ចីមូលប័ត្រ
- បន្តរៀបចំសេចក្តីព្រាងប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតសម្រាប់សេវាប្តូររូបិយប័ណ្ណ
- ធ្វើការសិក្សាលទ្ធភាពវិនិយោគលើសញ្ញាប័ណ្ណរយៈពេលវែង ។

## ៣. ការងារអភិវឌ្ឍប្រព័ន្ធទូទាត់

- កែលំអប្រព័ន្ធសភាផាត់ទាត់
- បន្តអនុវត្តតាមផែនទីចង្អុលផ្លូវសម្រាប់អភិវឌ្ឍប្រព័ន្ធទូទាត់តាមលំដាប់លំដោយអាទិភាព
- បន្តពង្រឹងនិងបណ្តុះបណ្តាលមន្ត្រីបុគ្គលិកក្រុមការងារគោលនយោបាយទូទាត់ (Payment Policy Unit) ។

## ៤. ការងារត្រួតពិនិត្យ និងការងារប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

- ពង្រឹងការអនុវត្តច្បាប់ បទបញ្ញាប្រុងប្រយ័ត្ន
- បន្តការអនុវត្តត្រួតពិនិត្យដល់ទីកន្លែងលើគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ តាមវិសាលភាពពេញលេញ និងតាមមុខសញ្ញា
- បន្តជម្រះបញ្ជីធនាគារដែលបានបិទទ្វារ និងខិតខំប្រមែប្រមូលបំណុល ដើម្បីទូទាត់សងប្រាក់បញ្ញើអតិថិជន
- បង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ
- បង្កើនការផ្សព្វផ្សាយឱ្យសាធារណជនបានយល់ដឹងអំពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- អនុវត្តច្បាប់និងប្រកាសស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ជំរុញឱ្យមានសហប្រតិបត្តិការជាតិលើវិធានការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

## ៥. ការងារគណនេយ្យ

- បន្តអនុវត្តគម្រោងកំណែទម្រង់ការងារគណនេយ្យ និងកែសម្រួលកម្មវិធីគណនេយ្យក្នុងប្រព័ន្ធកុំព្យូទ័រដែលកំពុងប្រើប្រាស់ឱ្យកាន់តែល្អប្រសើរ
- បូកសរុប និងធ្វើការវិភាគរបាយការណ៍គណនេយ្យឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា ។

## ៦. ការងារប្រតិបត្តិការ

- ពង្រឹងនិងត្រួតពិនិត្យការអនុវត្តការងារផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក ដើម្បីធានាគុណភាពទូទាត់ក្នុងប្រព័ន្ធធនាគារទាំងមូល
- បង្កើនកិច្ចសហការជាមួយនាយកដ្ឋានពន្ធដារ ទីចាត់ការគយនិងរដ្ឋាករ រតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការងារប្រមូលចំណូលសារពើពន្ធនិងមិន

ឯកសារពើពន្ធពីអ្នកបង់ចំណូលដោយផ្ទាល់ និងការងារផ្សេងទៀតក្នុងក្របខ័ណ្ឌប្រព័ន្ធកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាព

- ធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រតិបត្តិការគ្រប់គ្រងគណនីតាមប្រព័ន្ធកុំព្យូទ័រឱ្យស្របតាមសំណូមពរការងារ និងរចនាសម្ព័ន្ធដែលបានកែសម្រួល ដើម្បីផ្តល់សេវាដល់អតិថិជនឱ្យបានកាន់តែឆាប់រហ័ស ។

## ៧. ការងារបោះផ្សាយ-ឃ្លាំងបេឡា

- ចុះត្រួតពិនិត្យសាច់ប្រាក់ និងណែនាំអំពីការងារគ្រប់គ្រងសាច់ប្រាក់ ការថែរក្សាការពារឃ្លាំងប្រាក់ព្រមទាំងតាមដានជាប្រចាំសមតុល្យសាច់ប្រាក់ និងតម្រូវការសាច់ប្រាក់របស់សាខាធនាគារជាតិនៃកម្ពុជា
- បន្តសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ ដើម្បីរាំងខ្ទប់នូវការក្លែងបន្លំចាយវាយប្រាក់ក្លែងក្លាយ
- ពង្រឹងការងាររាប់-ស្រាល់ជ្រើស ការងារកាត់កំទេច និងដុតបំផ្លាញចោលក្រដាសប្រាក់ចាស់ទក់រហែកតាមនីតិវិធីដែលបានកំណត់
- ពង្រឹងការងារដឹកជញ្ជូន សំដៅរក្សាការសម្ងាត់ និងធានាឱ្យបានសុវត្ថិភាពខ្ពស់ ។

## ៨. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

- ចុះធ្វើសវនកម្មនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា (ការិយាល័យរាប់ស្រាល់ជ្រើស ការិយាល័យឃ្លាំង) នាយកដ្ឋានរោងពុម្ព និងសាខាធនាគារជាតិនៃកម្ពុជាចំនួន ៦
- បន្តចុះពង្រឹងការងារ និងធ្វើអធិការកិច្ចនៅគ្រប់សាខាធនាគារជាតិនៃកម្ពុជា ។

## ៩. ការបណ្តុះបណ្តាល

- បន្តពង្រឹងគុណភាពមណ្ឌលសិក្សាតាមរយៈការពង្រឹងសមត្ថភាពមន្ត្រី-បុគ្គលិក សាស្ត្រាចារ្យ និងវិន័យដល់និស្សិតជាប្រចាំ
- រៀបចំស្រាវជ្រាវកម្មវិធីសិក្សា (ធ្វើទំនើបកម្មសៀវភៅតាមមុខវិជ្ជា)
- រៀបចំជ្រើសរើសនិស្សិតថ្មី ជំនាន់ទី១៨
- រៀបចំវគ្គវិក្រិតការចំនួន ២វគ្គ ។

✧✧✧✧✧✧✧✧

# ឧបសម្ព័ន្ធ

# តារាង ១ : ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវា

| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (គិតជាមធ្យម) | ២០០៥ | ២០០៦ | ២០០៧ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| **មុខទំនិញគ្រប់មុខ** | **១១៧,៧៣** | **១២១,៤៦** | **១២១,២៦** | **១២១,៥៨** | **១២២,២២** | **១២៣,២០** | **១២៤,០៩** | **១២៦,៤០** | **១២៩,៤៤** | **១២៩,៤៧** | **១៣១,៧៣** | **១៣៤,១៣** | | |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | ១២១,៣១ | ១២៤,១៦ | ១២៤,០៧ | ១២៤,៣៦ | ១២៥,៦៦ | ១២៧,៤៤ | ១២៩,០៥ | ១៣៤,៣៥ | ១៣៩,៤៥ | ១៤០,៥២ | ១៤៥,៩៧ | ១៥០,១៧ | | |
| សម្លៀកបំពាក់និងស្បែកជើង | ៩០,៨៣ | ៩៣,៦៩ | ៩៣,៨០ | ៩៥,២០ | ៩៥,៤៤ | ៩៥,៧២ | ៩៤,៨៩ | ៩៤,៧១ | ៩៥,៨២ | ៩៦,៥៤ | ៩៧,៥៨ | ៩៨,៤៥ | | |
| ផ្ទះសំបែង និងការប្រើប្រាស់ | ១១៦,៧៣ | ១២០,៦១ | ១២០,៧៩ | ១២០,៩០ | ១២០,៩៣ | ១២១,១៦ | ១២១,១៦ | ១២០,៦៣ | ១២១,២២ | ១២១,១៥ | ១២១,៣៧ | ១២១,៦៤ | | |
| គ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ | ៩៤,៨៨ | ៩៧,២០ | ៩៧,៣៩ | ៩៧,៥២ | ៩៧,៨៥ | ៩៨,៤១ | ៩៨,៥៥ | ៩៨,៤០ | ១០០,៤៤ | ១០០,៨៣ | ១០១,០៩ | ១០២,០៦ | | |
| ការថែទាំសុខភាព | ១០២,២២ | ១០៤,៦២ | ១០៤,៦៧ | ១០៤,៦៨ | ១០៤,៦៩ | ១០៤,៨០ | ១០៤,៩១ | ១០៦,២៣ | ១០៤,៨៤ | ១០៩,៧៤ | ១០៩,៣៤ | ១១០,០៥ | | |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ១២៦,៩៥ | ១៣៧,០៣ | ១៣៤,៤១ | ១៣៥,៧៦ | ១៣៦,៤៤ | ១៣៧,៨៣ | ១៤០,៣៨ | ១៤១,៧៨ | ១៤២,៩៨ | ១៤២,៣០ | ១៤២,១២ | ១៤៥,០០ | | |
| ការកំសាន្តនិងការអប់រំ | ១១០,៦៨ | ១១១,៧៥ | ១១១,៧៨ | ១១១,៧៨ | ១១១,៩២ | ១១១,៩២ | ១១១,៩២ | ១១២,៨០ | ១២២,១៤ | ១១២,៩៧ | ១១៣,៤៧ | ១១៤,៧៨ | | |
| ការថែទាំខ្លួននិងសេវាកម្មផ្ទាល់ខ្លួន | ១០៩,១១ | ១១៣,៧៦ | ១១៤,០២ | ១១៤,០៨ | ១១៤,៤០ | ១១៤,៦៤ | ១១៤,៧៣ | ១១៤,៣៣ | ១១៤ ។៣៦ | ១១៥,១១ | ១១៥,៣៩ | ១១៣,៤៩ | | |
| | | | **បម្រែបម្រួលភាគរយប្រចាំខែ** | | | | | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **៤,៤៩** | **១១,២៥** | **-០,១៦** | **០,២៦** | **០,៥៣** | **០,៨០** | **០,៧២** | **១,៨៦** | **២,៤១** | **០,០២** | **១,៧៥** | **១,៨២** | | |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | ៨,២៩ | ១១,៨៣ | -០,០៧ | ០,២៣ | ១,០៥ | ១,៤២ | ១,២៦ | ៤,១១ | ៣,៨០ | ០,៧៧ | ៣,៩៩ | ៣,១៦ | | |
| សម្លៀកបំពាក់និងស្បែកជើង | ២,៣១ | ៩,៣២ | ០,១២ | ១,៤៩ | ០,២៥ | ០,២៩ | -០,៨៧ | -០,១៩ | ១,១៧ | ០,៧៥ | ១,០៨ | ០,៨៩ | | |
| ផ្ទះសំបែង និងការប្រើប្រាស់ | ០,៦៦ | ៧,៥៩ | ០,១៥ | ០,០៩ | ០,០២ | ០,១៩ | ០,០០ | -០,៤៤ | ០,៤៩ | -០,០៦ | ០,១៨ | ០,២២ | | |
| គ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ | ០,៩២ | ១,៥៨ | ០,២០ | ០,១៣ | ០,៣៤ | ០,៥៧ | ០,១៤ | -០,១៥ | ២,០៧ | ០,៣៩ | ០,២៦ | ០,៩៦ | | |
| ការថែទាំសុខភាព | ០,០២ | ២,០៧ | ០,០៥ | ០,០១ | ០,០១ | ០,១១ | ០,១០ | ១,២៦ | -១,៣១ | ៤,៦៧ | -០,៣៦ | ០,៦៥ | | |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ៦,៧១ | ២៥,៧១ | -១,៩១ | ១,០០ | ០,៥០ | ១,០២ | ១,៨៥ | ១,០០ | ០,៨៥ | -០,៤៨ | -០,១៣ | ២,០៣ | | |
| ការកំសាន្តនិងការអប់រំ | ០,៦៥ | ២,២៤ | ០,០៣ | ០,០០ | ០,១៣ | ០,០០ | ០,០០ | ០,៧៩ | ៨,២៨ | -៧,៥១ | ០,៤៤ | ១,១៥ | | |
| ការថែទាំខ្លួននិងសេវាកម្មផ្ទាល់ខ្លួន | ២,៤៦ | ៨,៩៦ | ០,២៣ | ០,០៥ | ០,២៨ | ០,២១ | ០,០៨ | -០,៣៥ | ០,០៣ | ០,៦៦ | ០,២៤ | -១,៦៥ | | |
| **បម្រែបម្រួលជាភាគរយធៀបនឹងខែដូចគ្នានៃឆ្នាំមុន** | | | | | | | | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **៥,៥៦** | **៣,១២** | **២,៥៥** | **២,៨៩** | **៣,៤៦** | **៤,០២** | **៤,០៦** | **៥,៦០** | **៦,៤៦** | **៥,២០** | **៦,៤៥** | **៨,៦៧** | | |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | ៨,២៧ | ២,៣៥ | ២,០៧ | ២,៨១ | ៤,២៦ | ៥,៥១ | ៥,៥៩ | ៩,៨២ | ១១,២៧ | ៩,៨៦ | ១២,៨៤ | ១៦,៨៥ | | |
| សម្លៀកបំពាក់និងស្បែកជើង | ៤,៧២ | ៣,១៤ | ២,៥០ | ៤,១៨ | ៣,៧៥ | ៣,៣៧ | ២,៣៥ | ១,៥៥ | ២,៨៤ | ៣,១៦ | ២,៦៥ | ៣,១០ | | |
| ផ្ទះសំបែង និងការប្រើប្រាស់ | ២,៣៨ | ៣,៣២ | ៣,១២ | ២,៧៤ | ២,៥២ | ២,៧១ | ២,៥០ | ១,៦៧ | ១,២៤ | ០,៥៤ | ០,៦៦ | ០,៧៧ | | |
| គ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ | ០,៥៦ | ២,៤៤ | ១,៨៩ | ២,២៣ | ២,២៩ | ២,៦៣ | ២,៦៣ | ២,៤៤ | ៣,៨៦ | ៣,៩១ | ៣,៩៧ | ៥,១០ | | |
| ការថែទាំសុខភាព | ០,០៩ | ២,៣៥ | ២,៣៩ | ២,៤០ | ២,៣៨ | ២,៥០ | ២,៦១ | ១,៧២ | ០,៣៨ | ៥,៣០ | ៤,៩១ | ៥,៥៩ | | |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ១១,០២ | ៧,៩៤ | ៤,២៧ | ៥,៤៤ | ៥,៧៧ | ៥,១៣ | ៦,០២ | ៥,៨១ | ៤,៤៦ | ២,៨៩ | ២,០២ | ៥,៥៥ | | |
| ការកំសាន្តនិងការអប់រំ | ១,០៣ | ០,៩៦ | ០,៦៨ | ០,៦៨ | ០,៦០ | ០,៦០ | ០,៦០ | ១,៣១ | ៩,៦៧ | ១,៤៤ | ០,៩៣ | ២,០៩ | | |
| ការថែទាំខ្លួននិងសេវាកម្មផ្ទាល់ខ្លួន | ៣,៨៨ | ៤,២៦ | ១,៩៣ | ១,៦៨ | ១,១៩ | ១,៤៩ | ១,៤៤ | ០,៨៦ | ០,៩៦ | ១,៧១ | ១,៩៦ | ០,០៩ | | |
| **ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញមធ្យម ៣ខែ** | | | | | | | | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **១១៨,៣៧** | **១២២,៣៨** | **១២១,៦៦** | **១២១,៤៣** | **១២១,៦៩** | **១២២,៣៣** | **១២៣,១៧** | **១២៤,៥៦** | **១២៦,៦៤** | **១២៨,៤៤** | **១៣០,២១** | **១៣១,៧៨** | | |
| | ៦,៥៧ | ៣,៣៩ | ២,៨៦ | ២,៧៥ | ២,៩៧ | ៣,៤៦ | ៣,៨៥ | ៤,៥៦ | ៥,៣៨ | ៥,៧៥ | ៦,០៣ | ៦,៧៧ | | |
| **ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ១២ខែ** | | | | | | | | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **១១៥,២០** | **១២០,៦២** | **១២០,៨៧** | **១២១,១៦** | **១២១,៥០** | **១២១,៩០** | **១២២,៣០** | **១២២,៨៦** | **១២៣,៥១** | **១២៤,០៥** | **១២៤,៧១** | **១២៥,៦០** | | |
| | ៥,៧៨ | ៤,៧១ | ៤,៤០ | ៤,១៣ | ៣,៩៣ | ៣,៨៧ | ៣,៨០ | ៣,៩៥ | ៤,០៧ | ៤,០៨ | ៤,២៦ | ៤,៦៤ | | |

# តារាង ២ : សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ឆ្នាំ ២០០៣-២០០៧

( គ្រាគោល : កក្កដា - ធ្នូ ២០០០=១០០)

| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ | ធ្នូ ២០០៣ | ធ្នូ ២០០៤ | ធ្នូ ២០០៥ | ធ្នូ ២០០៦ | ធ្នូ ២០០៧ |
|---|---|---|---|---|---|
| **មុខទំនិញគ្រប់មុខ** | **១០៤,៨៧** | **១១០,៧៦** | **១១៨,១៤** | **១២១,៤៦** | **១៣៤,៥៧** |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | ១០០,៩១ | ១០៩,៥៤ | ១២១,៧៤ | ១២៤,១៦ | ១៤៨,៧១ |
| សម្លៀកបំពាក់និងស្បែកជើង | ៨៦,៩១ | ៨៧,០២ | ៩១,៣៦ | ៩៣,៦៩ | ៩៨,០១ |
| ផ្ទះសំបែង និងការប្រើប្រាស់ | ១១១,៦៧ | ១១៤,១៥ | ១១៦,៩៨ | ១២០,៦១ | ១២២,៩៨ |
| គ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ | ៩៥,៣១ | ៩៤,៣៩ | ៩៥,៣៩ | ៩៧,២០ | ១០២,៤៨ |
| ការថែទាំសុខភាព | ១០២,២៥ | ១០២,១៩ | ១០២,២៣ | ១០៤,៦២ | ១១០,៤ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ១០១,៩៦ | ១១៦,៩៨ | ១២៧,៥៨ | ១៣៧,០៣ | ១៥៤,៩១ |
| ការកំសាន្តនិងការអប់រំ | ១០៩,១២ | ១០៩,៧៣ | ១១០,៨៩ | ១១១,៧៥ | ១១២,៧១ |
| ការថែទាំខ្លួននិងសេវាកម្មផ្ទាល់ខ្លួន | ១០៣,៩០ | ១០៥,៧៦ | ១១២,១០ | ១១៣,៧៦ | ១១៤,១៨ |
| | **បម្រែបម្រួលភាគរយប្រចាំខែ** | | | | |
| **មុខទំនិញគ្រប់មុខ** | **-០,១០** | **-០,២៣** | **-០,២៤** | **-០,៦៥** | **០,៥០** |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | -០,២៥ | -០,៧៣ | -០,៤៧ | -១,៣៦ | ០,៤០ |
| សម្លៀកបំពាក់និងស្បែកជើង | ០,០៣ | -០,២៤ | ០,០៩ | -១,៤៩ | -០,៤៣ |
| ផ្ទះសំបែង និងការប្រើប្រាស់ | ០,០៣ | ០,០៧ | ០,០០ | ០,០១ | ០,៥៣ |
| គ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ | ០,០៩ | ០,១២ | ០,២១ | ០,០៨ | -០,៦៧ |
| ការថែទាំសុខភាព | -០,៣៨ | ០,១២ | ០,០២ | ០,០១ | ០,១៣ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | -០,១៧ | ០,៣៥ | -០,៥៤ | ០,១៤ | ១,៨៤ |
| ការកំសាន្តនិងការអប់រំ | ០,១៣ | ០,១៧ | ០,១២ | -០,៦០ | -០,៥៣ |
| ការថែទាំខ្លួននិងសេវាកម្មផ្ទាល់ខ្លួន | ០,៤៦ | ០,៤៣ | ០,៤៩ | ០,១៩ | ០,២៣ |
| | **បម្រែបម្រួលជាភាគរយធៀបនិងខែដូចគ្នានៃឆ្នាំមុន** | | | | |
| **មុខទំនិញគ្រប់មុខ** | **០,៤៦** | **៥,៦២** | **៦,៦៦** | **២,៨១** | **១០,៧៩** |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | -០,១៩ | ៨,៥៥ | ១១,១៤ | ១,៩៩ | ១៩,៧៧ |
| សម្លៀកបំពាក់និងស្បែកជើង | -០,៧០ | ០,១៣ | ៤,៩៩ | ២,៥៥ | ៤,៦១ |
| ផ្ទះសំបែង និងការប្រើប្រាស់ | ០,៥៦ | ២,២២ | ២,៤៨ | ៣,១០ | ១,៦៣ |
| គ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ | -០,៧៥ | -០,៩៧ | ១,០៦ | ១,៩០ | ៥,៤៣ |
| ការថែទាំសុខភាព | -២,៣១ | -០,០៦ | ០,០៤ | ២,៣៤ | ៥,៥២ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ៤,៩៦ | ១៤,៧៣ | ៩,០៦ | ៧,៤១ | ១៣,០៥ |
| ការកំសាន្តនិងការអប់រំ | ០,៦៦ | ០,៥៦ | ១,០៦ | ០,៧៨ | ០,៨៦ |
| ការថែទាំខ្លួននិងសេវាកម្មផ្ទាល់ខ្លួន | ០,៧៩ | ១,៧៩ | ៥,៩៩ | ១,៤៨ | ០,៣៧ |
| | **ការវិវត្តន៍នៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ៣ខែ** | | | | |
| **មុខទំនិញគ្រប់មុខ** | **១០៤,៩៨** | **១១១,០៧** | **១១៨,៣៧** | **១២២,៣៨** | **១៣៤,២០** |
| បំម្រែបម្រួលជាភាគរយប្រចាំឆ្នាំ | ០៥០ | ៥,៨០ | ៦,៥៧ | ៣,៣៩ | ៩,៦៦ |
| | **ការវិវត្តន៍នៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ១២ខែ** | | | | |
| **មុខទំនិញគ្រប់មុខ** | **១០៤,៨៤** | **១០៨,៩០** | **១១៥,២០** | **១២០,៦២** | **១២៧,៦៧** |
| បំម្រែបម្រួលជាភាគរយប្រចាំឆ្នាំ | ១,១៥ | ៣,៨៧ | ៥,៧៨ | ៤,៧១ | ៥,៨៤ |

## តារាង៣ : ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ

| រូបិយប័ណ្ណ | ២០០៦ | ២០០៧ | | | | | | | | | | | | បំរែបំរួល % ធ្នូ ២០០៧ ធៀប នឹង ធ្នូ ២០០៦ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
| អេសដេអ៊ែរ | **៦.១១៥** | ៦.០៦៨ | ៦.១១៣ | ៦.១៤២ | ៦.២០៤ | ៦.១៧០ | ៦.១៨៨ | ៦.២៤៧ | ៦.២៥១ | ៦.៣៤០ | ៦.៣៥៩ | ៦.៣៦៩ | ៦.៣១៩ | ៣,៣៤% |
| **អាស៊ី** | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ៣.២០៧ | ៣.១៣៧ | ៣.១៩២ | ៣.២៧៦ | ៣.៣៥៧ | ៣.៣៥៤ | ៣.៤៥៩ | ៣.៥០៧ | ៣.៣៣០ | ៣.៥៩០ | ៣.៧៣១ | ៣.៥៤៣ | ៣.៥១៨ | ៩,៧០% |
| ដុល្លារ-ហុងកុង | ៥២២ | ៥២០ | ៥១៩ | ៥១៩ | ៥១៩ | ៥២២ | ៥២២ | ៥២១ | ៥២៣ | ៥២៥ | ៥២២ | ៥១៤ | ៥១៣ | -១,៧២% |
| យ៉េន-ជប៉ុន | ៣៤,១០ | ៣៣,៤ | ៣៤,១៨ | ៣៤,៤ | ៣៣,៩៧ | ៣៣,៥៣ | ៣៣,១៤ | ៣៤,២៥ | ៣៥,២២ | ៣៥,២៦ | ៣៥,៣១ | ៣៦,៣៦ | ៣៥.៦៣ | ៤,៤៩% |
| វ៉ុន-កូរ៉េ | ៤,៣៦ | ៤,៣១ | ៤,៣១ | ៤,៣១ | ៤,៣៦ | ៤,៣៩ | ៤,៤០ | ៤,៤៣ | ៤,៣៤ | ៤,៤៤ | ៤,៤៥ | ៤,២៧ | ៤.២៧ | -២,០៦% |
| ដុល្លារ-ញ៉ូស៊ីឡែន | ២.៨៥៩ | ២.៧៩៣ | ២.៨៤១ | ២.៨៩២ | ២.៩៥៥ | ២.៩៧៤ | ៣.១៣៨ | ៣.១៤៣ | ២.៨៦១ | ៣.០៧៧ | ៣.១១៩ | ៣.១០៣ | ៣.១០៣ | ៨,៥៣% |
| ដុល្លារ-តៃវ៉ាន់ | ១២៤ | ១២៣ | ១២៣ | ១២៣ | ១២២ | ១២៣ | ១២៤ | ១២៤ | ១២៣ | ១២៤ | ១២៥ | ១២៣ | ១២៣ | -០,៨១% |
| **អាស៊ាន** | | | | | | | | | | | | | | |
| រូពី-ឥណ្ឌូណេស៊ី | ០,៤៤៩ | ០,៤៤៥ | ០,៤៤២ | ០,៤៤៤ | ០,៤៤៧ | ០,៤៦១ | ០,៤៤៩ | ០,៤៤៣ | ០,៤៣៣ | ០,៤៤៦ | ០,៤៤៤ | ០,៤២៦ | ០,៤២៥ | -៥,៣៥% |
| រីងហ្គិត-ម៉ាឡេស៊ី | ១.១៤៧ | ១.១៦០ | ១.១៥៦ | ១.១៧៣ | ១.១៨៧ | ១.២០០ | ១.១៨១ | ១.១៨០ | ១.១៦៥ | ១.១៩៣ | ១.២១១ | ១.១៨៩ | ១.២០៧ | ៥,២៣% |
| ប៉េសូ-ហ្វីលីពីន | ៨២,៦៤ | ៨២,៧២ | ៨៣,៤៤ | ៨៤,១៦ | ៨៥,៩៧ | ៨៧,៩៤ | ៨៨,០៥ | ៨៩,៦០ | ៨៧,០៩ | ៩០,១១ | ៩២,៣៦ | ៩៤,០៥ | ៩៦,៨៣ | ១៧,១៧% |
| ដុល្លារ-សាំងហ្គាពួរ | ២.៦៣៣ | ២.៦៤២ | ២.៦៥៣ | ២.៦៧៣ | ២.៦៧៤ | ២.៦៦៦ | ២.៦៦៣ | ២.៦៩៧ | ២.៦៧៨ | ២.៧៣៥ | ២.៧៨៦ | ២.៧៦៨ | ៣.៧៦៨ | ៥,១៣% |
| បាត-ថៃ | ១១២ | ១១៧ | ១១៩ | ១២៥ | ១២៣ | ១២៥ | ១២៨ | ១៣៨ | ១២៤ | ១២៨ | ១២៧ | ១៣០ | ១៣១ | ១៦,៩៦% |
| ដុង-វៀតណាម | ០,២៥៣ | ០,២៥៣ | ០,២៥៤ | ០,២៥៣ | ០,២៥៣ | ០,២៥៤ | ០,២៥៣ | ០,២៥២ | ០,២៥១ | ០,២៥៣ | ០,២៥២ | ០,២៤៩ | ០,២៤៩ | -១,៥៨% |
| **អឺរ៉ុប** | | | | | | | | | | | | | | |
| អឺរ៉ូ | ៥.៣៣០ | ៥.២៦៧ | ៥.៣៦១ | ៥.៤០៤ | ៥.៥៣៥ | ៥.៤៧៥ | ៥.៤៨៧ | ៥.៥៩២ | ៥.៥៧៥ | ៥.៧៦៧ | ៥.៨៣៣ | ៥.៩១១ | ៥.៨៩៣ | ១០,៥៦% |
| **ផ្សេងៗ** | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៧.៩៥៦ | ៧.៩៧២ | ៧.៩៦០ | ៧.៩៦០ | ៨.០៩៩ | ៨.០៥៦ | ៨.១៧២ | ៨.២៧៩ | ៨.២១៤ | ៨.២៦២ | ៨.៣៤០ | ៨.២៦៥ | ៧.៩៨៦ | ០,៣៨% |

# តារាង ៤ : ស្ថានភាពរូបិយវត្ថុ

( គិតជាលានរៀល )

| | ធ្នូ-២០០៣ | ធ្នូ-២០០៤ | ធ្នូ-២០០៥ | ធ្នូ-២០០៦ | ធ្នូ-២០០៧ |
|---|---|---|---|---|---|
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **៤.០២៧.២២៤** | **៤.៧៩៦.៥៦១** | **៥.៤៧៥.១២០** | **៧.២២៤.៣០៥** | **១០.៧៣៤.៧០៣** |
| ទ្រព្យសកម្មបរទេស | ៤.៧៤០.៧៩០ | ៥.៤៨១.៥២៧ | ៦.១២៤.១១៥ | ៧.៦៤៩.៩៩៧ | ១១.៨៩០.៣០៣ |
| ទ្រព្យអកម្មបរទេស | -៧១៣.៥៦៦ | -៦៨៤.៩៦៦ | -៦៦៦.៩៩៦ | -៤២៥.៦៩៣ | -១.១៥៥.៦០០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-៦៩៨.២៦៦** | **-៤៦៧.២៦៤** | **-៤៥០.២០៦** | **-២៨២.០៤៣** | **៥៧៥.៩៧៧** |
| **ឥណទានក្នុងស្រុក** | **១.២០៨.៧១៤** | **១.៦០៧.៨១៣** | **១.៩៧២.៤៨៩** | **២.៦៧៦.៨៦៩** | **៤.៥៧០.០៥៣** |
| **ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល** | **-១២៧.៩១៦** | **-២០៨.៦៨៩** | **-៤២១.១៦២** | **-៩៥៣.៣៤០** | **-១.៨១៥.៨៩៧** |
| ឥណទេយ្យរាជរដ្ឋាភិបាល | ៣៦០.១៩៨ | ៣៥៩.៩៤៧ | ៣២៦.៥០៩ | ២៨៦.៦៤៥ | ២៩៦.៩៦០ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | -៤៨៨.១១៣ | -៥៦៨.៦៦៣ | -៧៤៧.៦៧១ | -១.២៣៩.៩៨៥ | -២.១១២.៨៥៧ |
| **ឥណទានផ្នែកមិនមែនរាជរដ្ឋាភិបាល** | **១.៣៣៦.៦៣០** | **១.៨១៦.៥០២** | **២.៣៩៣.៦៥១** | **៣.៦២៩.៨០៩** | **៦.៣៨៥.៩៥០** |
| សហគ្រាសរដ្ឋ | ១៤ | ០ | ០ | ២.០៨៥ | ១.១៧៧ |
| ផ្នែកឯកជន | ១.៣៣៦.៦១៦ | ១.៨១៦.៥០២ | ២.៣៩៣.៦៥១ | ៣.៦២៧.៧២៤ | ៦.៣៨៤.៧៧៣ |
| ក្នុងនោះ : រូបិយប័ណ្ណបរទេស | ១.២១៣.៩៩៤ | ១.៦៩៧.៤១៨ | ២.២៧៥.៤៩៥ | ៣.៤៧៥.៨៨១ | ៦.១៦១.២៩៦ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-១.៩០៦.៩៨០** | **-២.០៧៥.០៧៧** | **-២.៤២២.៦៩៥** | **-២.៩៥៨.៥១២** | **-៣.៩៩៤.០៧៦** |
| ប្រាក់បញ្ញើហាមឃាត់ | -១០៨.៩០៤ | -១០១.៦២៩ | -១២២.៩៧៥ | -១៥៥.០២០ | -២៥២.៩៩៦ |
| មូលធននិងធនបម្រុង | -២.០៨៩.០៧៥ | -២.១៩១.៩០៦ | -២.៦៤០.៣៥៣ | -៣.២៤១.២២០ | -៤.៣១៣.៨៣៥ |
| ផ្សេងៗ | ២៩០.៩៩៩ | ២១៨.៤៥៨ | ៣៤០.៦៣៣ | ៤៣៧.៧២៨ | ៥៧២.៣៥៥ |
| **រូបិយវត្ថុទូទៅ (M2)** | **៣.៣២៨.៩៥៨** | **៤.៣២៩.២៩៨** | **៥.០២៤.៩១៤** | **៦.៩៤២.២៦២** | **១១.៣១០.៦៨១** |
| **រូបិយវត្ថុ (M1)** | ៩៣៧.៤៧០ | ១.១៥២.៨៧៦ | ១.៣២២.៧៨៨ | ១.៦៥៧.៦៨៦ | ២.០៥២.០០៨ |
| រូបិយវត្ថុក្រៅធនាគារ | ៩០៨.២២៣ | ១.១១៤.៧៥០ | ១.២៨២.១៤៤ | ១.៥៩៩.៥៥០ | ១.៩៨៩.៧៣៧ |
| ប្រាក់បញ្ញើចរន្ត | ២៩.២៤៧ | ៣៨.១២៦ | ៤០.៦៤៥ | ៥៨.១៣៦ | ៦២.២៧១ |
| **រូបិយវត្ថុផ្សេងៗ** | **២.៣៩១.៤៨៨** | **៣.១៧៦.៤២២** | **៣.៧០២.១២៦** | **៥.២៨៤.៥៧៦** | **៩.២៥៨.៦៧៣** |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ៨១.៨៥២ | ៩៧.៣២៨ | ១១២.៧០៩ | ៨៨.៦០៤ | ១២១.០២៣ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ២.៣០៩.៦៣៦ | ៣.០៧៩.០៩៣ | ៣.៥៨៩.៤១៧ | ៥.១៩៥.៩៧២ | ៩.១៣៧.៦៥០ |

# តារាង ៥ :  ស្ថានភាពរូបិយវត្ថុ

(បម្រែបម្រួលប្រចាំខែជាភាគរយ)

| | ធ្នូ-២០០៣ | ធ្នូ-២០០៤ | ធ្នូ-២០០៥ | ធ្នូ-២០០៦ | ធ្នូ-២០០៧ |
|---|---|---|---|---|---|
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **៧,៨** | **១៩,១** | **១៤,១** | **៣១,៩** | **៤៨,៥៩** |
| ទ្រព្យសកម្មបរទេស | ១០,៨ | ១៥,៦ | ១២,១ | ២៤,៥ | ៥៥,៤៣ |
| ទ្រព្យអកម្មបរទេស | ៣១,៦ | -៤,០ | -២,៦ | -៣៦,២ | ១៧១,៤៦ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **១៧,៧** | **៣៣,១** | **៣,៧** | **៣៧,៤** | **៣០៤,៥១** |
| **ឥណទានក្នុងស្រុក** | **២៨,៣** | **៣៣,០** | **២២,៧** | **៣៥,៧** | **៧០,៧២** |
| **ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល** | **-៧,៤** | **-៦៣,១** | **-១០១,៨** | **-១២៦,៤** | **-៩០,៤៨** |
| ឥណទេយ្យរាជរដ្ឋាភិបាល | ១៦,២ | -០,១ | -៩,៣ | -១២,២ | ៣,៦០ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | ១៣,៨ | ១៦,៥ | ៣១,៥ | ៦៥,៨ | ៧០,៣៩ |
| **ឥណទានផ្នែកមិនមែនរាជរដ្ឋាភិបាល** | **២៦,០** | **៣៥,៩** | **៣១,៨** | **៥១,៦** | **៧៥,៩៣** |
| សហគ្រាសរដ្ឋ | -៩៩,៣ | -១០០,០ | ០,០ | ០,០ | -៤៣,៥៥ |
| ផ្នែកឯកជន | ២៦,២ | ៣៥,៩ | ៣១,៨ | ៥១,៦ | ៧៦,០០ |
| ក្នុងនោះ : រូបិយប័ណ្ណបរទេស | ២១,៩ | ៣៩,៩ | ៣៤,១ | ៥២,៨ | ៧៧,២៦ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-៦,៥** | **-៨,៨** | **-១៦,៨** | **-២២,១** | **-៣៥,០០** |
| ប្រាក់បញ្ញើហាមឃាត់ | ១៤,០ | ៦,៧ | ២១,០ | ២៦,១ | ៦២,៩៤ |
| មូលធននិងធនបម្រុង | ៧,៥ | ៤,៩ | ២០,៥ | ២២,៨ | ៣៣,០៩ |
| ផ្សេងៗ | ១៧,៣ | -២៤,៩ | ៥៥,៥ | ២៨,៥ | ៣០,៧៦ |
| **រូបិយវត្ថុទូទៅ (M2)** | **១៥,៣** | **៣០,០** | **១៦,១** | **៣៨,២** | **៦២,៩៣** |
| **រូបិយវត្ថុ (M1)** | **១៥,៣** | **២៣,០** | **១៤,៧** | **២៥,៣** | **២៣,៧៩** |
| រូបិយវត្ថុក្រៅធនាគារ | ១៨,៦ | ២២,៧ | ១៥,០ | ២៤,៨ | ២៤,៣៩ |
| ប្រាក់បញ្ញើចរន្ត | -៣៨,២ | ៣០,៤ | ៦,៦ | ៤៣,០ | ៧,១១ |
| **រូបិយវត្ថុផ្សេងៗ** | **១៥,២** | **៣២,៨** | **១៦,៦** | **៤២,៧** | **៧៥,២០** |
| ប្រាក់បញ្ញើមានកាលកំនត់និងសន្សំ | ១០,២ | ១៨,៩ | ១៥,៨ | -២១,៤ | ៣៦,៥៩ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ១៥,៤ | ៣៣,៣ | ១៦,៦ | ៤៤,៨ | ៧៥,៨៦ |

# តារាង ៦ : តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា

| | ធ្នូ-២០០៣ | ធ្នូ-២០០៤ | ធ្នូ-២០០៥ | ធ្នូ-២០០៦ | ធ្នូ-២០០៧ |
|---|---|---|---|---|---|
| | (គិតជាលានរៀល ) | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **៣.៤៩៤.៣៥២** | **៤.១១៤.៣១៥** | **៤.៤៣៣.៧២៩** | **៥.៧២៨.៧២០** | **៨.៥៧៩.១១៩** |
| ទ្រព្យសកម្មបរទេស | ៣.៩០៦.១៥៥ | ៤.៥០៦.៤៣៩ | ៤.៧៦៧.៧២០ | ៥.៧២៨.៧២០ | ៨.៥៧៩.១១៩ |
| ទ្រព្យអកម្មបរទេស | -៤១១.៨០៣ | -៣៩២.១២៤ | -៣៣៣.៩៩១ | - | - |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-១.៣៤៤.៣៩៩** | **-១.៤៤៩.៨១១** | **-១.៧៩៦.៥៨០** | **-២.៣៤៥.៩៣៣** | **-៣.៥៦០.៩២៩** |
| **ឥណទានសុទ្ធរាជរដ្ឋាភិបាល** | **-២១៨.៦៥៦** | **-២៥៥.៨២៨** | **-៤០៦.៧៣៨** | **-៨០៦.៩៣៧** | **-១.៦៣១.៩៩៦** |
| ឥណទានឲ្យរាជរដ្ឋាភិបាល | ២៦៩.៣៨៩ | ២៦៩.៧៧៧ | ២៧០.៤០៩ | ២៨៦.៤៤៥ | ២៩៦.៧៦០ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | -៤៨៨.០៤៥ | -៥២៥.៦០៥ | -៦៧៧.១៤៧ | -១.០៩៣.៣៨២ | -១.៩២៨.៧៥៦ |
| **ឥណទានចំពោះធនាគារពាណិជ្ជ** | **-៩០.៣៨៣** | **-៨៣.៩០៤** | **-១០១.២៤២** | **-៩២.០៦០** | **-១៤៩.៤៩២** |
| **ឥណទានចំពោះផ្នែកឯកជន** | ០ | **២.៩៣៦** | **២.៤០៤** | **២.១១៩** | **២.០៤៩** |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-១.០៣៥.៣៦០** | **-១.១១២.៦១៤** | **-១.២៩១.០០៤** | **-១.៤៤៩.០៥៦** | **-១.៧៧៩.៤៨៦** |
| **រូបិយវត្ថុបម្រុង** (Reserve Money) | **២.១៤៩.៩៥៣** | **២.៦៦៤.៥០៤** | **២.៦៣៧.១៤៩** | **៣.៣៨២.៧៨៧** | **៥.០១៨.១៩០** |
| រូបិយវត្ថុក្រៅធនាគារ | ៩០៨.២២៣ | ១.១១៤.៧៥០ | ១.២៨២.១៤៤ | ១.៥៩៩.៥៥០ | ១.៩៨៩.៧៣៧ |
| បេឡាធនាគារពាណិជ្ជ | ៥៩.៥៧៨ | ២៦.០៣២ | ២៦.៨៦៨ | ២៩.៧១៨ | ៤៧.១៧៩ |
| **ប្រាក់បញ្ញើធនាគារ** | **១.១៨២.១៥៣** | **១.៥១៨.៧១៣** | **១.៣២១.៩៤១** | **១.៧៣៦.២៥៤** | **២.៩៦៨.៤៦៦** |
| ប្រាក់បម្រុងកាតព្វកិច្ច | ១៩៣.៣៦៣ | ២៤៤.១៩៧ | ៣០២.២៥៦ | ៤២៧.៩៦១ | ៧៧៧.៦៦០ |
| ប្រាក់បញ្ញើផ្សេងៗ | ៩៨៨.៧៩០ | ១.២៧៤.៥១៦ | ១.០១៩.៦៨៦ | ១.៣០៨.២៩៣ | ២.១៩០.៨០៦ |
| **ផ្សេងៗ** | ០.០០០ | **៥.០០៩** | **៦.១៩៦** | **១៧.២៦៤** | **១២.៨០៨** |
| | (បំរែបំរួលប្រចាំឆ្នាំជាភាគរយ ) | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **៨,៥** | **១៧,៧** | **៧,៨** | **២៩,២** | **៤៩,៧** |
| ទ្រព្យសកម្មបរទេស | ៨.៦ | ១៥.៤ | ៥.៨ | ២០.២ | ៤៩.៧ |
| ទ្រព្យអកម្មបរទេស | ៨.៧ | -៤.៨ | -១៤.៨ | -១០០.០ | ០.០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-៨,៥** | **-៧,៨** | **-២៣,៩** | **-៣០,៦** | **-៥១,៨** |
| **ឥណទានសុទ្ធរាជរដ្ឋាភិបាល** | **-៣៦.៦** | **-១៧.០** | **-៥៩.០** | **-៩៨.៤** | **-១០២.៣** |
| ឥណទានឲ្យរាជរដ្ឋាភិបាល | ០.១ | ០.១ | ០.២ | ៥.៩ | ៣.៦ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | ១៣.៧ | ៧.៧ | ២៨.៨ | ៦១.៥ | ៧៦.៤ |
| **ឥណទានចំពោះធនាគារពាណិជ្ជ** | **១១.៧** | **-៧.២** | **២០.៧** | **-៩.១** | **៦៤.៦** |
| **ឥណទានចំពោះផ្នែកឯកជន** | ០.០ | ០.០ | **-៥.២** | **-១១.៨** | **-១៤.៩** |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-៣.៧** | **-៧.៥** | **-១៦.០** | **-១២.២** | **-២២.៨** |
| **រូបិយវត្ថុបម្រុង** (Reserve Money) | **៨,៥** | **២៣,៩** | **-១,០** | **២៨,៣** | **៤៨,៣** |
| រូបិយវត្ថុក្រៅធនាគារ | ១៨.៦ | ២២.៧ | ១៥.០ | ២៤.៨ | ២៤.៤ |
| បេឡាធនាគារពាណិជ្ជ | ៧៩.៨ | -៥៦.៣ | ៣.២ | ១០.៦ | ៥៨.៨ |
| **ប្រាក់បញ្ញើធនាគារ** | ០.១ | **២៨.៥** | -១៣.០ | ៣១.៣ | **៧២** |
| ប្រាក់បម្រុងកាតព្វកិច្ច | ១៤.៦ | ២៦.៣ | ២៣.៨ | ៤១.៦ | ៨១.៧ |
| ប្រាក់បញ្ញើផ្សេងៗ | -២.៤ | ២៨.៩ | -២០.០ | ២៨.៣ | ៦៧.៥ |
| **ផ្សេងៗ** | ០.០ | ០.០ | **២៤.០** | **១៧៨.៦** | **-២៥.៨** |

# តារាង ៧ : តារាងគណនីវិភាគធនាគារពាណិជ្ជ

| | ធ្នូ-២០០៣ | ធ្នូ-២០០៤ | ធ្នូ-២០០៥ | ធ្នូ-២០០៦ | ធ្នូ-២០០៧ |
|---|---|---|---|---|---|
| | (គិតជាលានរៀល) | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **៥៣២.៨៧២** | **៦៨២.២៤៦** | **១.០៤១.៣៥០** | **១.៤៩៥.៥៨៤** | **២.១៥៥.៥៨៤** |
| ទ្រព្យសកម្មបរទេស | **៨៣៤.៦៣៦** | **៩៧៥.០៨៨** | **១.៣៧៤.៣៩៩** | **១.៩២១.២៧៧** | **៣.៣១១.១៨៤** |
| ទ្រព្យអកម្មបរទេស | **-៣០១.៧៦៤** | **-២៩២.៨៤២** | **-៣៣៣.០៤៩** | **-៤២៥.៦៩៣** | **-១.១៥៥.៦០០** |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៥៥៨.១៣៤** | **៩៥៨.១៥៤** | **១.២៧៥.១៣៣** | **១.៩៦២.២៤៦** | **៤.០២០.២៧៨** |
| **ឥណទានក្នុងស្រុកសុទ្ធ** | **១.៣៦៩.១១០** | **១.៨៦៩.៣៨៣** | **២.៣៨៥.២៧៥** | **៣.៤៨៩.៦២៦** | **៦.១៦០.០០៤** |
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | ៩០.៧៤០ | ៤៧.១៤០ | -១៤.៤២៤ | -១៤៦.៤០៣ | -១៨៣.៩០០ |
| ឥណទានចំពោះសហគ្រាសរដ្ឋ | ១៤ | ០ | ០ | ២.០៨៥ | ១.១៧៧ |
| ឥណទានចំពោះផ្នែកឯកជន | ១.៣៣៦.៦១៦ | ១.៨១៣.៩៦៦ | ២.៣៩១.២៤៧ | ៣.៦២៥.៦០៥ | ៦.៣៨២.៧២៧ |
| ឥណទានសុទ្ធចំពោះធនាគារជាតិនៃកម្ពុជា | -៥៨.២៦០ | ៨.២៧៨ | ៨.៤៥២ | ៨.៣៣៩ | -៤០.០០០ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-៨១០.៩៧៦** | **-៩១១.២២៩** | **-១.១១០.១៤៣** | **-១.៥២៧.៣៨០** | **-២.១៣៩.៧២៦** |
| **ទុនបម្រុង** | **១.៣២៩.៧២៩** | **១.៥៦៩.១៣៨** | **១.៤២០.០៥១** | **១.៨៦៧.៦១៦** | **៣.១៣២.២៧៣** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | ៥៩.៥៧៨ | ២៦.០៣២ | ២៦.៨៦៨ | ២៩.៧១៨ | ៤៧.១៧៩ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | ១.២៧០.១៥១ | ១.៥៤៣.១០៦ | ១.៣៩៣.១៨៣ | ១.៨៣៧.៨៩៨ | ៣.០៨៥.០៩៤ |
| **ប្រាក់បញ្ញើ (ទ្រព្យអកម្មក្នុងស្រុក)** | **២.៤២០.៧៣៥** | **៣.២០៩.៥៣៨** | **៣.៧៣៦.៥៧៤** | **៥.៣២៥.៤៤៧** | **៩.៣០៨.១៣៥** |
| ប្រាក់បញ្ញើចរន្ត | ២៩.២៤៧ | ៣៣.១១៦ | ៣៤.៤៤៩ | ៤០.៨៧១ | ៤៩.៤៦២ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៨១.៨៥២ | ៩៧.៣២៨ | ១១២.៧០៩ | ៨៨.៦០៤ | ១២១.០២៣ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ២.៣០៩.៦៣៦ | ៣.០៧៩.០៩៣ | ៣.៥៨៩.៤១៧ | ៥.១៩៥.៩៧២ | ៩.១៣៧.៦៥០ |
| **ទ្រព្យសកម្មសរុប = ទ្រព្យអកម្មសរុប** | **៣.៨៧៧.៦៨៨** | **៤.៧០៦.២០២** | **៥.៥៧៩.១៦៤** | **៧.៩៦៣.១៣២** | **១៣.៥៤២.៥៣៦** |
| | (បម្រែបម្រួលជាភាគរយប្រចាំឆ្នាំ) | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **៣,០** | **២៨,០** | **៥២,៦** | **៤៣,៦** | **៤៤,១** |
| ទ្រព្យសកម្មបរទេស | ២២.៦ | ១៦.៨ | ៤១.០ | ៣៩.៨ | ៧២,៣ |
| ទ្រព្យអកម្មបរទេស | ៨៤.៥ | -៣,០ | ១៣.៧ | ២៧.៨ | ១៧១,៥ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៦៧,០** | **៧១,៧** | **៣៣,១** | **៥៣,៩** | **១០៤,៩** |
| **ឥណទានក្នុងស្រុក** | **២៤.១** | **៣៦,៥** | **២៧.៦** | **៤៦,៣** | **៧៦.៥** |
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | ១២១.៨ | -៤៨.០ | -១៣០.៦ | ៩១៥.០ | ២៥.៦ |
| ឥណទានចំពោះសហគ្រាសរដ្ឋ | -៩៩.៣ | -១០០.០ | ០.០ | ១០០.០ | -៤៣.៥ |
| ឥណទានចំពោះផ្នែកឯកជន | ២៦.២ | ៣៥.៧ | ៣១.៨ | ៥១.៦ | ៧៦.០ |
| ឥណទានសុទ្ធចំពោះធនាគារជាតិនៃកម្ពុជា | (-) | -១១៤.២ | ២.១ | -១.៣ | -៥៧៩.៧ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-៥.៥** | **-១២.៤** | **-២១.៨** | **-៣៧.៦** | **-៤០.១** |
| **ទុនបម្រុង** | **៤,៦** | **១៨,០** | **-៩,៥** | **៣១,៥** | **៦៧,៧** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | ៧៩.៨ | -៥៦.៣ | ៣.២ | ១០.៦ | ៥៨.៨ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | ២.៦ | ២១.៥ | -៩.៧ | ៣១.៩ | ៦៧.៩ |
| **ប្រាក់បញ្ញើ (ទ្រព្យអកម្មក្នុងស្រុក)** | **១៤,១** | **៣២,៦** | **១៦,៤** | **១៥,៨** | **៧៤,៨** |
| ប្រាក់បញ្ញើចរន្ត | -៣៨.២ | ១៣.២ | ៤.០ | ១៨.៦ | ២១.០ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១០.១ | ១៨.៩ | ១៥.៨ | -២១.៤ | ៣៦.៦ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ១៥.៤ | ៣៣.៣ | ១៦.៦ | ៤៤.៨ | ៧៥.៩ |
| **ទ្រព្យសកម្មសរុប = ទ្រព្យអកម្មសរុប** | **១៥,៥** | **២១,៤** | **១៨,៥** | **៤២,៧** | **៧០,១** |

## តារាង ៨ : ឥណទានចំណាត់ថ្នាក់តាមមុខរបរ

( មិនគិតបញ្ចូលសាខាខេត្តរបស់ធនាគារជាតិនៃកម្ពុជា)

( ឯកតា : លានរៀល)

| | ធ្នូ-២០០៣ | ធ្នូ-២០០៤ | ធ្នូ-២០០៥ | ធ្នូ-២០០៦ | ធ្នូ-២០០៧ |
|---|---|---|---|---|---|
| **កសិកម្ម** | ៤៣.៩៤៧ | ៦៤.៧៧៤ | ៦៩.២៨៧ | ១៤៨.៧១៧ | ៣០៥.២៤៥ |
| **កម្មន្តសាលកម្ម** | ១៨៧.៥៦៣ | ២៦៩.១៨៧ | ២៥៨.៧៥៦ | ៤១០.៩៧៩ | ៦២៥.៩៨៥ |
| **សំណង់** | ៨៣.១៥៤ | ៩៧.៩៧២ | ១៤៤.៩៥៧ | ២៦៩.០៦៧ | ៦៤០.៦៨៥ |
| **លក់ដុំ និង លក់រាយ** | ២២៥.៥៦៤ | ៣៦៣.០៤៩ | ៥៣២.៤៥០ | ៧៨៣.៤៧៩ | ១.៣៧១.០៧៧ |
| **នាំចេញ** | ១១៧.៤៧១ | ៧៧.៦១៥ | ៣៧.៥០៧ | ២៦.២០៩ | ១៣.៧២៨ |
| **នាំចូល** | ៨១.៣៥៦ | ១១០.៩៧៣ | ១៦៨.០៤៦ | ១៤២.៦៤២ | ២២៩.៦៦៣ |
| **ហិរញ្ញវត្ថុ** | ១០២.១៤៨ | ១០០.០៦៨ | ២៦.៤៨៥ | ២៤.០០៤ | ៣៦.៤៩៥ |
| **អចលនវត្ថុ និង ការប្រើប្រាស់សាធារណៈ** | ៦៦.៣៩២ | ៥០.៣២៩ | ១៤៧.៥៥៥ | ២៩៨.៨៨៦ | ៤៩៥.៤៤៧ |
| **សេវាកម្ម** | ៤៧៨.៤៤០ | ៦៧៥.៦៣៤ | ៦៦៧.៤៧៣ | ១.១៤៦.១៦០ | ១.៨០២.៣៥០ |
| **ផ្សេងៗ** | ៣៤.៥៦៩ | ១០២.៥៦៨ | ២៣៩.៩២៥ | ២២២.៣៨៨ | ៧៣៩.៤២២ |
| **សរុប** | **១.៤២០.៦០៤** | **១.៩១២.១៦៩** | **២.២៩២.៤៤២** | **៣.៤៧២.១៣០** | **៦.២៥៩.៦៩៧** |

## តារាង ៩ : សរុបប្រតិបត្តិការប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ

( មិនគិតបញ្ចូលសាខាខេត្តរបស់ធនាគារជាតិនៃកម្ពុជា)

( ឯកតា : លានរៀល)

| | ធ្នូ-២០០៣ | ធ្នូ-២០០៤ | ធ្នូ-២០០៥ | ធ្នូ-២០០៦ | ធ្នូ-២០០៧ |
|---|---|---|---|---|---|
| **ប្រាក់បញ្ញើជារៀល** | | | | | |
| ប្រាក់បញ្ញើចរន្ត | ៣០.៧៩៩ | ៣៧.៨៩១ | ៤០.៧១២ | ៤៩.៩៩១ | ៥៣.៥៦០ |
| ប្រាក់បញ្ញើសន្សំ | ៤១.១១៩ | ៤៩.១៦៩ | ៦២.៧៩៧ | ៩១.៦៨៨ | ១៣៥.០៨៧ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៤០.៨១៨ | ៤០.៣៧៣ | ៤១.៦៤៣ | ៤២.៦៧៩ | ៤៩.៦៤៩ |
| ប្រាក់បញ្ញើផ្សេងៗ | ០ | ២.៤២១ | ២.៤៣៨ | ១.៣៦០ | ១.២២១ |
| សរុប | **១១២.៧៣៦** | **១២៩.៨៥៥** | **១៤៧.៥៩០** | **១៨៥.៧១៩** | **២៣៩.៥១៧** |
| **ប្រាក់បញ្ញើជារូបិយប័ណ្ណ** | | | | | |
| ប្រាក់បញ្ញើចរន្ត | ៦៨៧.២៣០ | ៧៩២.៤៦៦ | ៩៥៨.៨០៤ | ១.៣៩៣.៥៣៣ | ២.៣១២.៧៤២ |
| ប្រាក់បញ្ញើសន្សំ | ១.០៦៧.៣២៩ | ១.៤៧៨.០០៧ | ១.៧០៣.១៥៣ | ២.២២៤.៥៩៤ | ៤.៥១៨.២៥៧ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៧៤០.១១៥ | ៨៨១.៦៤៤ | ១.០៧១.៨៦៣ | ១.៨១៣.២៧៩ | ២.៧៦៣.០៦១ |
| ប្រាក់បញ្ញើផ្សេងៗ | ២.៣៨៦ | ៤៥.៨១៦ | ៤៥.៨១១ | ៦៩.៩១០ | ៨៨.៨៩៤ |
| សរុប | **២.៤៩៧.០៦១** | **៣.១៩៧.៩៣៣** | **៣.៧៧៩.៦៣១** | **៥.៥០១.៣១៦** | **៩.៦៨២.៩៥៥** |
| **សរុបរួម** | **២.៦០៩.៧៩៦** | **៣.៣២៧.៧៨៨** | **៣.៩២៧.២២១** | **៥.៦៨៧.០៣៥** | **៩.៩២២.៤៧២** |

# ជញ្ជីងទូទាត់ប្រទេសកម្ពុជា
## ឆ្នាំ២០០៤-២០០៧

(គិតជាលានដុល្លារអាមេរិក )

| | ២០០៤ | ២០០៥ | ២០០៦ | ២០០៧[ព] |
|---|---|---|---|---|
| **ជញ្ជីងពាណិជ្ជកម្ម** | **-៦៨០,៦** | **-១០១៧,៦** | **-១០៥៦,១** | **-១.២៧០,៤** |
| **នាំចេញ** (FOB) | **២.៥៨៨,៩** | **២.៩១០,៣** | **៣.៦៩៣,១** | **៤.០៩១,២** |
| នាំចេញផលិតផលក្នុងស្រុក | ២.៤៥៤,៥ | ២.៧៧២,៨ | ៣.៥៣៧,២ | ៣.៨៥៦,៨ |
| នាំចេញតាមប្រព័ន្ធ GSP ( រាប់បញ្ចូល សំលៀកបំពាក់) | ២.០៧៨,៥ | ២.២៦០,៧ | ២.៧២៦,៨ | ៣.០១៤,៥ |
| នាំចេញផលិតផលក្នុងស្រុកផ្សេងៗ | ៣៧៥,៩ | ៥១២,២ | ៨១០,៥ | ៨៤២,៣ |
| នាំចេញបន្ត | ១៣៤,៤ | ១៣៧,៤ | ១៥៥,៨ | ១៨៤,៤ |
| **នាំចូល** (FOB) | **-៣.២៦៩,៥** | **-៣.៩២៧,៨** | **-៤.៧៤៩,២** | **-៥.៣១១,៥** |
| នាំចូលសំរាប់ប្រើប្រាស់ក្នុងស្រុក | -៣.១៦៦,២ | -៣.៨០៩,៩ | -៤.៦១៣,៦ | -៥.១៤៣,០ |
| សំលៀកបំពាក់ | -១.០១០,១ | -១.១០២,៣ | -១.២៩៧,៧ | -១.៤០៨,៦ |
| ប្រេងឥន្ធនៈ | -៦០៩,៩ | -៨៤១,៦ | -១.១២៣,៤ | -១.២៥៦,២ |
| នាំចូលសំរាប់ប្រើប្រាស់ក្នុងស្រុកផ្សេងៗ | -១.៥៤៦,២ | -១.៨៦៦,១ | -២.១៩២,៥ | -២.៤៧៨,១ |
| នាំចូលសំរាប់នាំចេញបន្ត | -១០៣,៣ | -១១៧,៨៩ | -១៣៥,៦ | -១៦៨,៦ |
| **សេវា (សុទ្ធ)** | **២៩០,៥** | **៤៧១,១** | **៥០៦,៥** | **៦៤៣,៩** |
| **ចំណូល** | **៨០៤,៩** | **១.១១៨,១** | **១.២៩៦,៣** | **១.៥៤៦,៥** |
| សេវាដឹកជញ្ជូន | ១០៤,៨ | ១២៦,៩ | ១៦៦,៨ | ២០១,២ |
| សេវាធ្វើដំណើរ | ៦០៣,៥ | ៨៣៩,៥ | ៩៦៣,២ | ១.១៤៩,៤ |
| សេវាផ្សេងៗ | ៩៦,៧ | ១៥១,៦ | ១៦៦,៣ | ១៩៥,៩ |
| **ចំណាយ** | **-៥១៤,៤** | **-៦៤៧,១** | **-៧៨៩,៨** | **-៩០២,៦** |
| សេវាដឹកជញ្ជូន | -២៩៨,៤ | -៣៦០,៣ | -៤៣៦,០ | -៤៩៦,១ |
| សេវាធ្វើដំណើរ | -៤៧,៦ | -៩៦,៩ | -១២២,២ | -១៣៦,១ |
| សេវាផ្សេងៗ | -១៦៨,៤ | -១៨៩,៩ | -២៣១,៧ | -២៧០,៥ |
| **ប្រាក់ចំណូល (សុទ្ធ)** | **-២២១,០** | **-២៥៤,០** | **-២៩០,៤** | **-២៧៦,៧** |
| **ចំណូល** | **៤៨,៦** | **៦៧,៧** | **៩០,០** | **១១១,១** |
| **ចំណាយ** | **-២៦៩,៦** | **-៣២១,៨** | **-៣៨០,៤** | **-៣៨៧,៨** |
| **បង្វែរឯកជន (សុទ្ធ)** | **១៧៥,៨** | **២០៩,៣** | **៣១៥,១** | **៣៣២,០** |
| **សមតុល្យគណនីចរន្ត** ( មិនរាប់បញ្ចូលបង្វែរផ្លូវការ) | -៤៣៥,៣ | -៥៩១,៣ | -៥២៥,០ | -៥៧១,២ |
| **បង្វែរផ្លូវការ** | **៣២០,៥** | **៣២៥,៧** | **៤៤៩,១** | **៤១៥,៩** |
| **ចំណូល** | **៣២០,៨** | **៣២៦,០** | **៤៤៩,៤** | **៤១៦,២** |
| ក្នុងនោះ : ជំនួយទ្រទ្រង់ថវិការ | ៦,៤ | ២,៧ | ៧,០ | ២១,៣ |
| ជំនួយជាស្បៀងអាហារ | ២០,២ | ១៧,១ | ២០,១ | ២៩,៤ |
| ជំនួយតាមគំរោង | ១៥៨,៩ | ១៦៣,៤ | ២៥៤,៥ | ១៨៦,៦ |
| ជំនួយបច្ចេកទេស | ១៣៥,៣ | ១៤២,៨ | ១៦៧,៨ | ១៧៨,៩ |
| **ចំណាយ** | **-០,៣** | **-០,៣** | **-០,៣** | **-០,៣** |
| **សមតុល្យគណនីចរន្ត និងបង្វែរដើមទុន** | -១១៤,៨ | -២៦៥,៦ | -៧៥,៨ | -១៥៥,៣ |
| **គណនីហិរញ្ញវត្ថុ** | ២១៩,១ | ៣៣៤,៩ | ៣២៣,៨ | ៤៥០,៩ |
| **ឥណទេយ្យផ្លូវការ** ( មិនរាប់បញ្ចូល IMF) សុទ្ធ* | **១៥៤,៤** | **១៤៤,០** | **១២២,៧** | **១៧៣,០** |
| **ដកប្រាក់** | **១៦២,៧** | **១៥៣,៣** | **១៣១,៧** | **១៨៤,០** |
| **ទូទាត់** | -៨,៣ | -៩,៣ | -៩,០ | -១១,១ |
| **វិនិយោគមិនផ្លូវការ** | **៦៤,៧** | **១៩០,៩** | **២០១,១** | **២៧៧,៩** |
| **វិនិយោគផ្ទាល់** ( សុទ្ធ)* | **១២១,២** | **៣៧៤,៩** | **៤៧៤,៨** | **៧១១,២** |
| **វិនិយោគលើផលប័ត្រ** ( សុទ្ធ)* | -៨,០ | -៧,២ | -១២,១ | **-១២,៤** |
| **វិនិយោគផ្សេងទៀត** ( សុទ្ធ)* | **-៤៨,៥** | **-១៧៦,៨** | **-២៦១,៦** | **-៤២០,៩** |
| **កំហុស និង រំលង** | **-៤៥,៨** | **-៥,១** | **-៤៦,១** | **-៥,៧** |
| **សមតុល្យរួម** | ៥៨,៥ | ៧៤,៤ | ២០១,៩ | ២៨៩,៩ |
| **ហិរញ្ញប្បទាន** | **-៥៨,៥** | **-៧៤,៤** | **-២០១,៩** | **-២៨៩,៩** |
| ទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិ * | -៧១,៣ | -៨៧,១ | -២២០,៧ | -៣០២,៧ |
| បំរែបំរួលទ្រព្យសកម្មជាទុនបំរុង | -៦១,០ | -៧៨,៤ | -១៣៨,៦ | -៣០២,៧ |
| ការប្រើប្រាស់ឥណទានរបស់ IMF | -១០,៣ | -៨,៨ | -៨២,១ | ០,០ |
| **ហិរញ្ញប្បទានពិសេស** | **១២,៨** | **១២,៨** | **១៨,៨** | **១២,៨** |

* តម្លៃវិជ្ជមានតំណាងអោយកំណើនទ្រព្យអកម្មបរទេស ឬថយចុះទ្រព្យសកម្មបរទេស និងតម្លៃអវិជ្ជមានតំណាងអោយកំណើនទ្រព្យសកម្មបរទេស ឬការថយចុះទ្រព្យអកម្មបរទេស

**ប្រភព** : ទិន្នន័យត្រូវបានផ្តល់ដោយអាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិ

**កំណត់សំគាល់** : - ទិន្នន័យបណ្តោះអាសន្នសំរាប់ឆ្នាំ២០០៤-២០០៦ (ទិន្នន័យទាំងនេះអាចនឹងកែលំអឡើងវិញក្នុងពេលអនាគត)

- ព = ព្យាករណ៍ទិន្នន័យសំរាប់ឆ្នាំ២០០៧